ខមមីត

ការសម្របសម្រួលគំនិតផ្តួចផ្តើមថ្នាក់រដ្ឋមន្ត្រីប្រឆាំងការជួញដូរមនុស្សនៅមហាអនុតំបន់មេគង្គ




UNIAP
United Nations Inter-Agency
Project on Human Trafficking
( យូ អេន អាយ អេ ភី )


# សទ្ទានុក្រម

## ស្តីពីការជួញដូរមនុស្ស និងចិត្តវិទ្យា

# GLOSSARY OF ENGLISH-KHMER ON HUMAN TRAFFICKING AND PSYCHOLOGY


បោះពុម្ពលើកទី២ ខែកញ្ញា ឆ្នាំ២០១៣

# អារម្ភកថា

អំពើជួញដូរមនុស្សនិងការកេងប្រវ័ញ្ចលើមនុស្សបាននិងកំពុងកើតឡើង និងរីកសាយភាយពាសពេញពិភពលោក នៅខណៈពេលដែលការយល់ដឹងពីអំពើទាសភាពសម័យទំនើបនេះនៅមានកម្រិតនៅឡើយក្នុងស្រទាប់មហាជន និងអ្នកអនុវត្តច្បាប់។ នាពេលថ្មីៗនេះ របាយការណ៍ប្រចាំឆ្នាំ ២០១៣ ស្តីពីការជួញដូរមនុស្ស ដែលចេញផ្សាយដោយក្រសួងការបរទេសសហរដ្ឋអាមេរិក បានធ្វើការប៉ាន់ប្រមាណថាផ្អែកតាមការស្រាវជ្រាវរបស់អ្នកវិទ្យាសាស្ត្រសង្គម ជនរងគ្រោះដោយសារអំពើជួញដូរមនុស្សនៅលើពិភពលោកក្នុងអំឡុងឆ្នាំ ២០១២-២០១៣ មានចំនួនប្រហែល ២៧ លាននាក់ ( ទាំងបុរស ស្ត្រី និងកុមារ ) ក៏ប៉ុន្តែផ្អែកតាមព័ត៌មានដែលផ្តល់ដោយរដ្ឋាភិបាលនានា ជនរងគ្រោះចំនួនប្រហែល ៤០.០០០ នាក់ តែប៉ុណ្ណោះ ដែលត្រូវបានកំណត់អត្តសញ្ញាណ និង/ឬ ត្រូវបានជួយគាំទ្រនៅក្នុងរយៈពេលដដែលនេះ។

ដើម្បីឆ្លើយតបទៅនឹងបរិបទនេះ គោលនយោបាយ យុទ្ធសាស្ត្រ និងផែនការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស និងការធ្វើអាជីវកម្មកេងប្រវ័ញ្ចលើមនុស្ស ត្រូវបានរៀបចំ ចងក្រង ផ្សព្វផ្សាយ និងអនុវត្តយ៉ាងសស្រាក់សស្រាំទាំងក្នុងក្របខ័ណ្ឌជាតិ អនុតំបន់ តំបន់ និងលើពិភពលោក។

ដោយឡែកសម្រាប់ព្រះរាជាណាចក្រកម្ពុជា ក្រៅពីការបង្កើតឱ្យមានផែនការ និងយន្តការថ្នាក់ជាតិក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សដែលមានដូចជាគណៈកម្មាធិការជាតិដឹកនាំ ប.ជ.រ.ព.ភ. និងក្រុមការងារ ខមមីត កម្ពុជា រាជរដ្ឋាភិបាលក៏បាននិងកំពុងបន្តសហការយ៉ាងជិតស្និទ្ធជាមួយអង្គការជាតិ អង្គការអន្តរជាតិ ទីភ្នាក់ងារអង្គការសហប្រជាជាតិ និងជាពិសេសជាមួយកម្មវិធីអន្តរទីភ្នាក់ងារអង្គការសហប្រជាជាតិប្រឆាំងនឹងអំពើជួញដូរមនុស្ស ( ហៅកាត់ថា UNIAP ) ក្នុងការអនុវត្តផែនការសកម្មភាពផ្សេងៗតួយ៉ាងដូចជាផែនការសកម្មភាពមហាអនុតំបន់មេគង្គជំហានទីមួយ ( SPA I: ២០០៥-២០០៧ ) ជំហានទីពីរ ( SPA II: ២០០៨-២០១០ ) និងជំហានទីបី ( SPA III: ២០១១-២០១៣ ) ជាដើម។ ក្នុងនោះចំណុចដៅទី ៤.៣ នៃ SPA III បច្ចុប្បន្ន

បានគូសបញ្ជាក់យ៉ាងច្បាស់អំពីការសម្រេចឱ្យបាននូវការលើកកម្ពស់ការយល់ដឹងជាសាធារណៈ និងឱ្យមានលក្ខណៈទូលំទូលាយពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំងការជួញដូរ និងការធ្វើអាជីវកម្មកេងប្រវ័ញ្ចលើមនុស្ស ។

ឆ្លើយតបទៅនឹងចំណុចដៅខាងលើ និងដើម្បីបំពេញកង្វះខាតឯកសារពន្យល់ជាភាសាខ្មែរ និងការចូលរួមសម្រួលដល់ការយល់ដឹង និងការប្រើប្រាស់ពាក្យសំខាន់ៗឱ្យបានត្រឹមត្រូវផងនោះ ក្រុមការងារ ខមមីត កម្ពុជា ក្រោមការជួយឧបត្ថម្ភពីកម្មវិធីអន្តរទីភ្នាក់ងារអង្គការសហប្រជាជាតិប្រឆាំងនឹងអំពើជួញដូរមនុស្ស បានដកស្រង់និងរៀបចំ "**សទ្ទានុក្រមស្តីពីការជួញដូរមនុស្ស និងចិត្តវិទ្យា**" នេះឡើង ដើម្បីផ្សព្វផ្សាយដល់ស្ថាប័នឬអ្នកពាក់ព័ន្ធទាំងឡាយ ដូចជាអ្នកធ្វើគោលនយោបាយ មន្ត្រីអនុវត្តច្បាប់ អ្នកគ្រប់គ្រងកម្មវិធី អ្នកស្រាវជ្រាវ សាស្ត្រាចារ្យ និស្សិត អ្នកសារព័ត៌មាន និងសាធារណជនជាដើម សម្រាប់យកទៅប្រើប្រាស់ជាឯកសារជំនួយស្មារតីនិងបង្កើនការយល់ដឹងបន្ថែមមួយកម្រិតទៀតទៅលើការជួញដូរនិងការធ្វើអាជីវកម្មកេងប្រវ័ញ្ចលើមនុស្ស ការរត់ពន្ធមនុស្ស ការធ្វើចំណាកស្រុក និងបញ្ហាចិត្តសង្គមពាក់ព័ន្ធនឹងការជួញដូរមនុស្ស។

ក្នុងការរៀបចំចងក្រងសទ្ទានុក្រមនេះ ពាក្យពេចន៍និងខ្លឹមសារមួយចំនួនត្រូវបានដកស្រង់ចេញពី ច្បាប់ជាតិ អនុសញ្ញា-ពិធីសារអន្តរជាតិ វចនានុក្រមផ្សេងៗ និងឯកសារផ្សព្វផ្សាយរបស់អង្គការ-ស្ថាប័នដែលធ្វើការងារពាក់ព័ន្ធក្នុងវិស័យនេះ។

ខ្ញុំមានជំនឿថាសទ្ទានុក្រមនេះនឹងក្លាយជាជំនួយការដ៏មានប្រយោជន៍សម្រាប់ ទ្រង់ ឯកឧត្តម លោកជំទាវ អស់លោកលោកស្រី អ្នកនាង-កញ្ញាទាំងអស់ ក្នុងការបំពេញភារកិច្ចនៅក្នុងវិស័យរៀងៗខ្លួនដើម្បីទប់ស្កាត់ បង្ក្រាប ផ្តន្ទាទោស ហើយនិងកាត់បន្ថយ និងឈានដល់ការលុបបំបាត់អំពើជួញដូរមនុស្ស ព្រមទាំងដើម្បីការពារជនងាយរងគ្រោះទាំងឡាយឱ្យចាកផុតពីឧក្រិដ្ឋកម្មទាសភាពបែបទំនើបនេះ។

**សាន្ត អរុណា**

រដ្ឋលេខាធិការ ក្រសួងកិច្ចការនារី

និងជាប្រធានក្រុមការងារ ខមមីត កម្ពុជា

# « ច្បាប់ស្តីពីការបង្រ្កាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ »

(ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២០៨/០០៥ ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០៨)

## មាត្រា ១៣.- និយមន័យនៃអំពើលក់-ដូរមនុស្ស

- **អំពើលក់-ដូរមនុស្ស** មានន័យថា ប្រគល់ឱ្យដោយខុសច្បាប់នូវការគ្រប់គ្រងលើជនណាម្នាក់ទៅជនដទៃ ឬ ទទួលយកដោយខុសច្បាប់នូវការប្រគល់ការគ្រប់គ្រងលើជនណាម្នាក់ពីជនដទៃ ដោយផ្តោះប្តូរទៅនឹងរបស់មានតម្លៃអ្វីមួយ ដោយរាប់បញ្ចូលទាំងសេវានិងមនុស្សផង ។

អំពើធ្វើជាភ្នាក់ងារកណ្តាលនៃការលក់-ដូរមនុស្ស ត្រូវផ្តន្ទាទោសដូចគ្នានឹងអំពើលក់-ដូរមនុស្សដោយផ្ទាល់ ។

# « ពិធីសារស្តីពីការទប់ស្កាត់ បង្ក្រាប និងដាក់ទណ្ឌកម្មការជួញដូរមនុស្ស ជាពិសេស ស្ត្រី និងកុមារ ដែលបំពេញបន្ថែមលើអនុសញ្ញារបស់ អង្គការសហប្រជាជាតិស្តីពី ការប្រឆាំងបទឧក្រិដ្ឋកម្មឆ្លងដែន ដែលមានអង្គការចាត់តាំង » ហៅកាត់ថា ពិធីសារប៉ាឡឺម៉ូ

(អនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ នៅថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០០០ ប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ នស/រកម/០១០៦/០០៤ ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០០៦)

## មាត្រា ៣.  ការប្រើប្រាស់វាក្យសព្ទ

- ❖ **អំពើជួញដូរមនុស្ស** គឺសំដៅទៅលើការជ្រើសរើស ការដឹកជញ្ជូន ការផ្ទេរ ការផ្តល់កន្លែងលាក់ខ្លួន ឬការទទួលយកមនុស្ស ដោយប្រើប្រាស់មធ្យោបាយគំរាមកំហែង ការប្រើកម្លាំង ឬ ទម្រង់ផ្សេងៗនៃការបង្ខិតបង្ខំ ការចាប់ពង្រត់ ការឆបោក ការបញ្ឆោត ការបំពានដោយអំណាច ការរំលោភលើភាពងាយរងគ្រោះ ឬការផ្តល់ឬទទួលយកកម្រៃឬអត្ថប្រយោជន៍ណាមួយដើម្បីទទួលបានការយល់ព្រមពីសំណាក់បុគ្គលណាម្នាក់ ដែលមានអំណាចគ្រប់គ្រងលើបុគ្គលម្នាក់ទៀត ក្នុងគោលបំណងដើម្បីកេងប្រវ័ញ្ច។ គោលបំណងកេងប្រវ័ញ្ចនេះមានដូចជាការកេងប្រវ័ញ្ចលើពេស្យាកម្មជនដទៃ ឬ ទម្រង់ផ្សេងៗទៀតនៃការធ្វើអាជីវកម្មផ្លូវភេទ ពលកម្មឬសេវាដោយបង្ខំ ទាសភាពឬការអនុវត្តស្រដៀងគ្នានឹងទាសភាព សេវភាព ឬ ការដកហូតសរីរាង្គ។

# ខាងក្រោមនេះគឺជាតារាងសង្ខេបអំពីនិយមន័យនៃការជួញដូរមនុស្ស តាមពិធីសារប៉ាឡឺម៉ូ

| ការជួញដូរមនុស្ស៖ ធាតុផ្សំទាំងបី ( សម្រាប់ជនរងគ្រោះជាមនុស្សពេញវ័យ ) | | |
|---|---|---|
| សកម្មភាព | មធ្យោបាយ (វិធីសាស្ត្រ) | គោលបំណង |
| តើមានភស្តុតាងអំពី ការជ្រើសរើស ការដឹកជញ្ជូន ការផ្ទេរ ការផ្តល់កន្លែងឬការទទួលយកមនុស្សដែរឬទេ ? | តើមានភស្តុតាងអំពីការគំរាមកំហែង ការប្រើកម្លាំងឬទម្រង់ផ្សេងទៀត នៃការបង្ខិតបង្ខំ ការចាប់ពង្រត់ ការបោកបញ្ឆោត ការបំពានដោយអំណាចឬស្ថានភាពងាយរងគ្រោះ ឬការផ្តល់ឬទទួលកម្រៃដើម្បីទទួលបាន ការយល់ព្រមពីមនុស្សម្នាក់ ដែលមានការត្រួតត្រាលើមនុស្សម្នាក់ទៀតដែរឬទេ ? | តើមានភស្តុតាងបញ្ជាក់ថាគោលបំណងនៃការប្រព្រឹត្តអំពើនោះធ្វើឡើង ដើម្បីកេងប្រវ័ញ្ចលើមនុស្សដែរឬទេ ? |

| ការជួញដូរកុមារ ( មនុស្សអាយុក្រោម ១៨ ឆ្នាំ )៖ ធាតុផ្សំមានតែពីរ | |
|---|---|
| សកម្មភាព | គោលបំណង |
| តើមានភស្តុតាងអំពី ការជ្រើសរើស ដឹកជញ្ជូន ផ្ទេរ ផ្តល់កន្លែង ឬទទួលយកកុមារដែរឬទេ ? | តើមានភស្តុតាងបញ្ជាក់ថាគោលបំណងនៃការប្រព្រឹត្តអំពើនោះធ្វើឡើង ដើម្បីកេងប្រវ័ញ្ចលើកុមារដែរឬទេ ? |

# សទ្ទានុក្រម ស្តីពី ការជួញដូរមនុស្ស

# GLOSSARY ON HUMAN TRAFFICKING



| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Abduction | ការចាប់ជំរិត | Abduct | Kidnapping | ការគំរាមតាមគ្រប់រូបភាព តាមមធ្យោបាយណា ក៏ដោយដើម្បី កំណត់ឱ្យប្រគល់ជាប្រាក់ ឬជាទ្រព្យសម្បត្តិ ក្នុងបំណងដែលជនល្មើសចង់បាន ។ (ច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ) |
| Abuse | ការរំលោភ<br>ការបំពាន | Abuse | Defilement, harm, injury, malevolence, maltreatment, violation, aggression | សំដៅលើការប្រើប្រាស់ ឬការប្រព្រឹត្តលើអ្វីមួយ (មនុស្ស វត្ថុ ខ្លឹមសារ គំនិត ឬ វាក្យសព្ទ) ដែលធ្វើឱ្យអន្តរាយ ។ វាអាចចែកចេញជាក្រុមទៅតាមគោលដៅនៃការរំលោភបំពាន ឬ ជំពូកនៃការរំលោភបំពាន ។ |
| Abuse of power | ការរំលោភអំណាច<br>ការបំពានដោយអំណាច | N/A | N/A | ជាស្ថានការណ៍មួយដែលមន្ត្រីសាធារណៈប្រើប្រាស់តួនាទីរបស់ខ្លួន ឬ ឆ្លៀតយកប្រយោជន៍ពីតួនាទីរបស់ខ្លួនដើម្បីប្រព្រឹត្តអំពើខុសច្បាប់ ។ ជាញឹកញាប់ ការរំលោភអំណាចនេះ ត្រូវបានប្រើប្រាស់ដើម្បីកេងប្រវ័ញ្ចលើមនុស្សម្នាក់ឬច្រើននាក់ ដែលកំពុងស្ថិតក្នុងកាលៈទេសៈងាយទទួលរងគ្រោះ ក្នុងគោលដៅធ្វើឱ្យជនរងគ្រោះជឿធ្វើអ្វីមួយ ។ |
| Abuse of vulnerability | ការរំលោភលើ<br>ភាពងាយរងគ្រោះ | N/A | N/A | ជាការរំលោភទៅលើស្ថានភាពមួយដែលក្នុងនោះបុគ្គលម្នាក់មិនមានជម្រើសពិតប្រាកដនិងអាចទទួលយកបាន ហើយធ្លាក់ខ្លួនទៅក្នុងការរំលោភបំពានផ្សេងៗ ។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Accession | ការចូលជាសមាជិក<br>ការយល់ព្រមទទួលយក<br>ជាផ្លូវការ | N/A | N/A | *អំពើដែលរដ្ឋមួយទទួលយកសំណើ ឬ ឱកាសដើម្បីក្លាយជាភាគីមួយនៃសន្ធិសញ្ញា ដែលបានចរចា ឬចុះហត្ថលេខាដោយរដ្ឋដទៃទៀតរួចមកហើយ។ វាមានអានុភាពខាងផ្លូវច្បាប់ ដូចគ្នានឹងការផ្តល់សច្ចាប័នដែរ។ តាមធម្មតា ការចូលជាសមាជិកកើតឡើង នៅក្រោយពេលដែលសន្ធិសញ្ញានេះ បានចូលជាធរមានរួចទៅហើយ។ លក្ខខណ្ឌនៅក្រោមការចូលជាសមាជិកនេះ និងនីតិវិធីដែលពាក់ព័ន្ធអាចខុសគ្នា ដោយអាស្រ័យទៅលើបទប្បញ្ញត្តិដែលមានចែងនៅក្នុងសន្ធិសញ្ញានោះ។ សន្ធិសញ្ញាខ្លះអាចចែងអំពីការអនុញ្ញាតឱ្យរដ្ឋដទៃទៀតទាំងអស់ ចូលជាសមាជិក ឬ សម្រាប់តែរដ្ឋមួយចំនួនតូច ឬ តាមចំនួនកំណត់ប៉ុណ្ណោះ។ នៅក្នុងករណី មិនមានចែងបែបនេះ ការចូលជាសមាជិកអាចធ្វើបានតែកាលណារដ្ឋទាំងអស់ ដែលចូលរួមក្នុងការចរចាបង្កើត សន្ធិសញ្ញាយល់ព្រម ឬ ផ្តល់ការយល់ព្រមជាបន្តបន្ទាប់ទៅលើការចូលជាសមាជិករបស់រដ្ឋដែលស្នើសុំ។* |
| Accomplice | អ្នកសមគំនិត | N/A | Abettor | *បុគ្គលដែលជួយសម្រួលដោយចេតនា ដល់ការប៉ុនប៉ង ឬការសម្រេចបទល្មើស ដោយផ្តល់ជាជំនួយ ឬ ការឧបត្ថម្ភរបស់ខ្លួន។* |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Accountable | ដែលមានគណនេយ្យភាព<br>ដែលមានការទទួលខុសត្រូវ | N/A | Responsible<br>Answerable | ដែលទទួលខុសត្រូវលើលទ្ធផលនៃចំណាត់ការរបស់ខ្លួន និងមានឆន្ទៈរាយការណ៍ បកស្រាយ ឬ ទទួលការទិតៀនទៅលើលទ្ធផលនៃចំណាត់ការទាំងនោះ ។ |
| Accusation | ការចោទប្រកាន់ | Accuse | Charge, allegation | សេចក្ដីចោទប្រកាន់ជនណាម្នាក់ដែលសង្ស័យថាបានប្រព្រឹត្តបទល្មើសណាមួយ ឬបានប្រព្រឹត្តខុសលើអ្វីមួយ ។ |
| Accused | ជនជាប់ចោទ | Accuse | N/A | បុគ្គល ឬក្រុមមនុស្ស ដែលត្រូវបានចោទប្រកាន់ជាផ្លូវការនៅក្នុងតុលាការអំពីបទល្មើសព្រហ្មទណ្ឌណាមួយ ។ |
| Act of selling/buying or exchanging a human being | អំពើលក់-ដូរមនុស្ស | N/A | N/A | អំពើនៃការប្រគល់ឱ្យដោយខុសច្បាប់នូវការគ្រប់គ្រងលើ ជនណាម្នាក់ទៅជនដទៃឬទទួលយកដោយខុសច្បាប់នូវការប្រគល់ការគ្រប់គ្រងលើជនណាម្នាក់ពីជនដទៃ ដោយផ្ដោះប្ដូរទៅនឹងរបស់មានតម្លៃអ្វីមួយ ដោយរាប់បញ្ចូលទាំងសេវា និង មនុស្សផង ។ |
| Ad hoc | ពិសេស<br>បណ្ដោះអាសន្ន | N/A | N/A | មិនបានគ្រោងទុក ដោយគ្រាន់តែរៀបចំចាត់ចែង ឬ ធ្វើឡើងក្នុងករណីចាំបាច់ ។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Adjudication | ការវិនិច្ឆ័យ | Adjudicate | Decision, determination, finding, pronouncement, ruling, verdict | នៅក្នុងបរិបទនៃការធ្វើទេសន្តរប្រវេសន៍ ពាក្យនេះសំដៅលើសេចក្តីសម្រេចមួយ ដែលកំណត់ថា អ្នកដាក់ពាក្យសុំណាម្នាក់អាចមានគុណសម្បត្តិគ្រប់គ្រាន់ ដើម្បីទទួលបានទិដ្ឋាការចេញចូល, ឋានៈជាជនភៀសខ្លួន ឬទទួលបានឋានៈជាជនអន្តោប្រវេសន៍ផ្សេងៗទៀត។ |
| Admission | ការអនុញ្ញាតឱ្យចូល | Admit | Acceptance | គឺជាការផ្តល់សិទ្ធិឱ្យចូលទៅក្នុងរដ្ឋណាមួយ។ ជនបរទេសមួយរូបត្រូវបាន"អនុញ្ញាតឱ្យចូល" ប្រសិនបើគាត់បានឆ្លងកាត់ច្រកឆែកឆេរមួយ (តាមផ្លូវអាកាស ផ្លូវគោក ឬ តាមផ្លូវទឹក) និងត្រូវបានមន្ត្រីត្រួតពិនិត្យតាមច្រកព្រំដែនអនុញ្ញាតឱ្យចូល។ ជនបរទេសដែលបានចូលដោយលួចលាក់មិនត្រូវបានចាត់ទុកថាបានទទួលការអនុញ្ញាតឱ្យចូលនោះឡើយ។ |
| Adolescent | ក្មេងជំទង់ | N/A | Teenage | ក្មេងជំទង់ ឬ យុវជនដែលមានវ័យគ្រប់ការ។ |
| Adoption | ការអនុម័ត | Adopt | Acquisition, acceptance | អំពើនៃការចាប់ផ្តើមប្រើប្រាស់ជាអាទិ៍ ផែនការ វិធីសាស្ត្រ ឬ របៀបនិយាយណាមួយ ។ល។ នៅក្នុងច្បាប់អន្តរជាតិ ពាក្យនេះ ត្រូវបានប្រើប្រាស់ ដើម្បីសំគាល់ការព្រមព្រៀងរវាងរដ្ឋភាគីនានាទៅលើដំណើរការនៃអត្ថបទសន្ធិសញ្ញា ដែលបានស្នើឡើង។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Adoption (Child) | សុំកូន | N/A | N/A | យោងតាមច្បាប់កម្ពុជា សុំកូនត្រូវបានបែងចែកជាពីរករណី គឺសុំកូនពេញលេញ និងសុំកូនធម្មតា។ "សុំកូនពេញលេញ" សំដៅដល់ការសុំកូនដែលមានអានុភាពបង្កើតនូវទំនាក់ទំនងអចិន្ត្រៃយ៍ជាឪពុកម្តាយនិងកូន រវាងឪពុកម្តាយចិញ្ចឹម ឬ ឪពុកចិញ្ចឹម ឬ ម្តាយចិញ្ចឹម និងកូនសុំ និង បញ្ចប់សិទ្ធិនិងកាតព្វកិច្ចរវាងកូននិងឪពុកម្តាយបង្កើតឬអ្នកអាណាព្យាបាល សម្រាប់អនីតិជនរបស់ខ្លួន (ដកស្រង់ចេញពី មាត្រា ៤ នៃច្បាប់ស្តីពី សុំកូនអន្តរប្រទេស)។ "សុំកូនធម្មតា" ជាការសុំកូនមួយបែបដែលតាមរយៈនោះ ញាតិភាពរវាងកូនសុំ និង ឪពុកម្តាយបង្កើតត្រូវបន្តអត្ថិភាព ហើយកូនសុំ និង ឪពុកម្តាយបង្កើតមានសិទ្ធិធ្វើសន្តតិកម្ម (ការផ្ទេរមរតក) គ្នាទៅវិញទៅមក។ (មាត្រា ១០២៦ នៃក្រមរដ្ឋប្បវេណី) |
| Advocate (1) | តស៊ូមតិ<br>កៀរគរការគាំទ្រ | Advocate | Lobby | ព្យាយាមបង្កើតឱ្យមានឥទ្ធិពលទៅលើការសម្រេចរបស់រដ្ឋាភិបាល ឬស្ថាប័នដទៃទៀត។ |
| Advocate (2) | អ្នកតស៊ូមតិ<br>អ្នកកៀរគរការគាំទ្រ<br>អ្នកគាំទ្រ អ្នកនិយាយការពារ | Advocate | Supporter, proponent, backer | អ្នកដែលនិយាយក្នុងនាមអ្នកណាម្នាក់ និងផ្តល់ការគាំទ្រ ឬ ធ្វើជាជំនួសដល់បុគ្គលនោះ។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Affidavit | លិខិតធានា<br>លិខិតផ្តល់សក្ខីកម្ម<br>ឬលិខិតថ្លែងសច្ចា | N/A | N/A | *លិខិតធានាគឺជាឯកសារដែលបានបញ្ជាក់តាមផ្លូវច្បាប់ ដែលតាមធម្មតាត្រូវបានចុះហត្ថលេខា ដោយអ្នកធានា ដើម្បីធានារ៉ាប់រងលើថ្លៃចំណាយទាំងមូលសម្រាប់ជនចំណាកស្រុក ទទួលបានការផ្តល់សិទ្ធិចូលក្នុងប្រទេសណាមួយ (ជាញឹកញាប់ គឺជាលក្ខខណ្ឌចាំបាច់សម្រាប់ ជនចំណាកស្រុកដែលជាមនុស្សចាស់ និងអ្នកដែលមានជំងឺ និងមិនអាចការពារខ្លួន។ លិខិតផ្តល់សក្ខីកម្ម ឬលិខិតថ្លែងសច្ចាសំដៅលើសេចក្តីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរនិងដោយស្ម័គ្រចិត្តធ្វើឡើងក្រោមសម្បថ នៅចំពោះមុខមន្ត្រីមានសមត្ថកិច្ចឬមន្ត្រីតុលាការ។* |
| After care | ការថែរក្សានៅក្រោយពេលវិបត្តិ | N/A | N/A | *សេវាគាំទ្រភ្លាមៗ និងរយៈពេលខ្លី ដែលផ្តល់ដោយបុគ្គលិក ឬភ្នាក់ងារផ្នែកសង្គមកិច្ច សម្រាប់ជនរងគ្រោះដែលទើបនឹងរួចផុតពីស្ថានភាពជួញដូរ។* |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Aggression | អំពើឈ្លានពាន<br>ការរំលោភបំពាន | Aggress | N/A | អំពើឈ្លានពានសំដៅលើអាកប្បកិរិយាដែលប្រព្រឹត្តិក្នុងចន្លោះកម្រិតនៃការប៉ុនប៉ង និងការបង្កឱ្យមានការឈឺចាប់ ឬ ខូចខាត។ អំពើឈ្លានពានកើតមានតាមទម្រង់ខុសៗគ្នា និងអាចជាអំពើឈ្លានពាន ខាងផ្លូវកាយ ផ្លូវចិត្ត ឬ តាមរយៈពាក្យសំដី។ លក្ខន្តិកៈក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ បានកំណត់ថាអំពើឈ្លានពានរបស់រដ្ឋ មួយគឺជាឧក្រិដ្ឋកម្មអន្តរជាតិ ពោលគឺសំដៅលើអំពើរបស់រដ្ឋមួយដែលប្រើប្រាស់កងកម្លាំងប្រដាប់អាវុធប្រឆាំងនឹងអធិបតេយ្យភាព បូរណភាពទឹកដី ឬឯករាជភាពរបស់រដ្ឋមួយទៀត ឬធ្វើឡើងក្នុងលក្ខណៈណាមួយដែលផ្ទុយនឹងធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ។ |
| Agreement | កិច្ចព្រមព្រៀង | Agree | Accord, consent, concurrence | ការយោគយល់គ្នាទៅវិញទៅមក (ជាលាយលក្ខណ៍អក្សរ ឬមិនមែនជាលាយលក្ខណ៍អក្សរ) រវាងភាគីពីរ ឬច្រើនដែលមានបំណងចងសម្ព័ន្ធភាពជាមួយគ្នាតាមផ្លូវច្បាប់ ដើម្បីបង្កើត កែប្រែ ឬមិនបំពេញនូវសិទ្ធិនិងកាតព្វកិច្ចអ្វីមួយ។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| AIDS | ជំងឺអេដស៍ | N/A | Acquired immune deficiency syndrome | គឺជារោគសញ្ញាមួយឈុត និងការកើតជំងឺ ដោយសារតែការខូចខាតប្រព័ន្ធបន្សាំនៅលើរាងកាយរបស់មនុស្ស ដែលបង្កដោយវីរុស ដែលជាភ្នាក់ងារធ្វើឱ្យបាត់បង់ប្រព័ន្ធបន្សាំលើសរីរាង្គ របស់មនុស្ស (HIV) ។ លក្ខខណ្ឌនេះ ធ្វើឱ្យមានការថយចុះជាបន្តបន្ទាប់នូវប្រសិទ្ធភាពនៃប្រព័ន្ធបន្សាំ និងធ្វើឱ្យបុគ្គលនោះងាយរងជំងឺឱកាសនិយម និងរោគមហារីក ។ |
| Alcoholism | រោគញៀនសុរា | N/A | Alcohol addiction, alcohol dependence, dipsomania | ជំងឺម្យ៉ាង និងភាពញៀន ដែលនាំឱ្យមានការសេពគ្រឿងស្រវឹងជាប់ជាប្រចាំ បើទោះជាបានទទួលផលអវិជ្ជមាន ហើយក៏ដោយ ។ |
| Alias | ឈ្មោះហៅក្រៅ | N/A | Nickname, pseudonym, AKA | ឈ្មោះដែលត្រូវបានប្រើប្រាស់ខុសពីឈ្មោះពិតដែលប្រើក្នុងឯកសារផ្លូវការ ។ |
| Alien | ជនបរទេស | N/A | Foreigner | បុគ្គលដែលមិនមានសញ្ជាតិរបស់រដ្ឋមួយ ដែលខ្លួនកំពុងស្នាក់នៅ ។ |
| Amnesty | ការលើកលែងទោស | N/A | Absolution, dispensation, forgiveness, reprieve, pardon | ការអត់ឱនទោស ជាទូទៅ មួយដែលត្រូវបានយកមកប្រើក្នុងន័យស្របគ្នានឹងពាក្យ "ការធ្វើឱ្យមានលក្ខណៈស្របច្បាប់" ហើយអាចប្រើបានចំពោះតែបុគ្គលណា ដែលមាននិវេសនដ្ឋាននៅក្នុងប្រទេស ដែលផ្តល់ការលើកលែងទោសប៉ុណ្ណោះ បើទោះជានិវេសនដ្ឋាននោះមិនមានលក្ខណៈស្របច្បាប់ក៏ដោយ ។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Amendment | វិសោធនកម្ម<br>ការកែប្រែ | Amend | Adjustment, alteration, modification, revision, change | ការកែប្រែ ការកែលម្អ ឬ ការបន្ថែម ដែលបានធ្វើឡើងនៅក្នុងច្បាប់ ឬឯកសារនានា ឬ ក្នុងដំណើរការរៀបចំតាក់តែងច្បាប់ ឬឯកសារទាំងនោះ ។ |
| Ancestry based settlers | អ្នកតាំងទីលំនៅ<br>បន្តពីបុព្វបុរសរបស់ខ្លួន | N/A | N/A | ជនបរទេស ដែលបានអនុញ្ញាតដោយប្រទេសមួយក្រៅពីប្រទេសរបស់ខ្លួន ដោយសារតែប្រវត្តិនៃចំណងទាក់ទងជាតិពន្ធុ ឬ ចំណងទាក់ទងផ្សេងទៀតជាមួយប្រទេសនោះ និងដោយសារតែចំណងទាក់ទងបែបនេះ បុគ្គលរូបនោះត្រូវបានទទួលសិទ្ធិភ្លាមៗ ដើម្បីស្នាក់នៅរយៈពេលវែងនៅក្នុងប្រទេសនោះ ឬដោយសារតែមានសិទ្ធិទទួលបានសញ្ជាតិនៅក្នុងប្រទេសនោះ បុគ្គលរូបនោះបានទទួលសញ្ជាតិនៅក្នុងពេលយ៉ាងឆាប់ ក្រោយពីបានទទួលការអនុញ្ញាតឱ្យចូលក្នុងប្រទេសនោះ ។ |
| Anonymity | អនាមិកភាព | N/A | Namelessness | ស្ថានភាពដែលគេមិនដឹង ឬ ដែលមិនមានអ្នកស្គាល់ ។ |
| Appeal | បណ្ដឹងឧទ្ធរណ៍ | Appeal | N/A | នីតិវិធីមួយដែលធ្វើឡើងដើម្បីពិនិត្យឡើងវិញលើសេចក្ដីសម្រេចមួយ ដោយដាក់ជូនទៅអាជ្ញាធរថ្នាក់ខ្ពស់ជាង ។ ពាក្យនេះត្រូវបានប្រើជាញឹកញាប់ក្នុងការសំដៅលើការដាក់សេចក្ដីសម្រេចរបស់តុលាការជាន់ទាប ឬ របស់ស្ថាប័នមួយ ជូនទៅតុលាការជាន់ខ្ពស់ ដើម្បីពិនិត្យឡើងវិញ និងដើម្បីអាចកែប្រែសេចក្ដីសម្រេចនោះ ។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Applicant | អ្នកដាក់ពាក្យសុំ | Apply | Appellant, aspirant, candidate, claimant | បុគ្គលម្នាក់ដែលស្នើសុំជាផ្លូវការឱ្យមានចំណាត់ការ ដោយរដ្ឋាភិបាល ឬ ចំណាត់ការខ្លះៗតាមផ្លូវច្បាប់ ដូចជា ការផ្តល់សិទ្ធិជាជនភៀសខ្លួន ការផ្តល់ទិដ្ឋាការ ឬ អាជ្ញាប័ណ្ណធ្វើការងារ ។ |
| Application | ពាក្យសុំ | Apply | Request | សំណើមួយ(តាមធម្មតាជាលាយលក្ខណ៍អក្សរ) ដែលដាក់ជូនដោយបុគ្គលម្នាក់ ឬ អង្គការមួយទៅរដ្ឋាភិបាល ដើម្បីស្នើសុំឱ្យរដ្ឋាភិបាលអនុវត្តចំណាត់ការណាមួយ ។ |
| Arbitrary | ដែលរំលោភ<br>ដែលចំពាន | N/A | Discretionary | (តាមរយៈឥរិយាបថគ្មានសមហេតុផល) ដែលមានលក្ខណៈទាក់ទងនឹងគំនិតអយុត្តិធម៌ ការមិនគិតទុកជាមុន ភាពមិនសមហេតុផល និងការផ្លាស់ប្តូរចិត្តគំនិតភ្លាមៗ ។ |
| Arrival/departure card | ប័ណ្ណចេញ/ចូល | N/A | N/A | ប័ណ្ណមួយ ដែលបំពេញដោយបុគ្គលណាម្នាក់ មុននឹង ឬ នៅពេលមកដល់ប្រទេសមួយ ដែលជាគោលដៅ និងដែលត្រូវបង្ហាញជូន (រួមជាមួយលិខិតឆ្លងដែន និង ប្រសិនបើមានការស្នើសុំ ត្រូវភ្ជាប់ជាមួយទិដ្ឋាការ) ទៅឱ្យមន្ត្រីនានានៅច្រកត្រួតពិនិត្យ ។ |
| Article | មាត្រា (ដែលមានចែងក្នុងច្បាប់ ឬ បទប្បញ្ញត្តិផ្សេងៗ) | N/A | N/A | ផ្នែកមួយនៃច្បាប់ ឬ កិច្ចព្រមព្រៀងតាមផ្លូវច្បាប់ ដែលកំណត់អំពីចំណុចជាក់លាក់ណាមួយ ។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Assault | ការវាយប្រហារ ឬការបៀតបៀនលើរូបរាងកាយ/ផ្លូវភេទ | Assault | N/A | ជាបទល្មើសប្រើហិង្សាប្រឆាំងបុគ្គលណាម្នាក់។ វាអាចជាអំពើហិង្សាខាងផ្លូវភេទ (ការរំលោភសេពសន្ថវៈ ការរំលោភបំពានលើកុមារ) ឬ មិនមែនផ្លូវភេទ (ឃាតកម្ម ការបង្កឱ្យមានរបួសធ្ងន់ធ្ងរលើរាងកាយ)។ |
| Assessment | ការប៉ាន់ប្រមាណ | Assess | N/A | ជាដំណើរការពិនិត្យ និងវាយតម្លៃករណីជាក់លាក់ដូចជា ការប៉ាន់-ប្រមាណសុខភាព ការប៉ាន់ប្រមាណករណីបឋម និងការប៉ាន់-ប្រមាណគ្រួសារ និងសហគមន៍ ដើម្បីឈានដល់ការដោះស្រាយបញ្ហារបស់ជនរងគ្រោះ ការស្តារនីតិសម្បទា និងការធ្វើសមាហរណកម្មជនរងគ្រោះ។ ការប៉ាន់ប្រមាណត្រូវបានធ្វើឡើងជាច្រើនលើកដើម្បីតាមដានវិវឌ្ឍន៍របស់ជនរងគ្រោះ ហើយវាផ្តល់មកវិញនូវការយល់ដឹងស្តីអំពីជោគជ័យនៃកិច្ចអន្តរាគមន៍ និងធ្វើឱ្យគេអាចកំណត់នូវអាទិភាពប្រែប្រួលនានា ឬតម្រូវការដែលគួរតែដាក់បញ្ចូលទៅក្នុងផែនការករណី។ ការប៉ាន់ប្រមាណក៏សំដៅផងដែរទៅលើសកម្មភាពមួយឈុត ដែលចាំបាច់ត្រូវធ្វើឡើង ដើម្បីស្វែងយល់អំពីស្ថានភាពណាមួយ ដោយមានការប្រមូលធ្វើបច្ចុប្បន្នភាព និង វិភាគទិន្នន័យស្តីពី ចំនួនមនុស្សឬរបស់ទូទៅដែលត្រូវសិក្សា (ដូចជា តម្រូវការ សមត្ថភាព ធនធាន ។ល។) និងទិន្នន័យស្តីពី ស្ថានភាព ហេដ្ឋារចនាសម្ព័ន្ធនិងលក្ខខណ្ឌសេដ្ឋកិច្ច-សង្គម ទូទៅនៅក្នុងទីកន្លែងឬតំបន់ណាមួយ។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Assets forfeiture | ការរឹបអូសទ្រព្យសម្បត្តិដែលមានការពាក់ព័ន្ធនឹងឧក្រិដ្ឋកម្ម | N/A | N/A | *ការដកហូតដោយរដ្ឋាភិបាលនូវទ្រព្យ ដោយសារតែការពាក់ព័ន្ធនៃទ្រព្យនោះ ឬម្ចាស់ទ្រព្យនោះ នៅក្នុងបទល្មើស ដូចជាការបង្ខាំងទុករថយន្តដែលត្រូវបានប្រើប្រាស់នៅក្នុងអំពើរត់ពន្ធ ឬការជួញដូរជនបរទេសចូលមកក្នុងរដ្ឋណាមួយ ។* |
| Assimilation | ការសម្របខ្លួនរស់នៅក្នុងទីកន្លែងណាមួយ | Assimilate | Adaptation, acclimatization, conformity, acculturation, orientation, settling in, familiarization | *ការសម្របខ្លួនរបស់ក្រុមជនជាតិដើម ឬ សហគមន៍ណាមួយ (ដែលតាមធម្មតាគឺជាជនជាតិភាគតិច) ជាមួយនឹងក្រុមផ្សេងទៀត ។ ការសម្របខ្លួននេះមានន័យថា ជាការស្រូបបញ្ចូលនូវភាសា ប្រពៃណី គុណតម្លៃ អាកប្បកិរិយា ឬ ផលប្រយោជន៍ដែលជាមូលដ្ឋានគ្រឹះសំខាន់បំផុត និង ការកែប្រែនូវចិត្តគំនិតទៅលើរបស់ផ្សេងៗដែលខ្លួនមាន ។* |
| Assistance | ជំនួយ<br>ការជួយ | Assist | N/A | *ជំនួយផ្តល់ឱ្យ ដើម្បីដោះស្រាយតម្រូវការខាងរូបវន្ត សម្ភារ និងផ្លូវច្បាប់របស់បុគ្គលនានាដែលពាក់ព័ន្ធ ។ ជំនួយនេះ អាចរាប់បញ្ចូល ចំណីអាហារ សម្ភារពេទ្យ សម្លៀកបំពាក់ ជម្រកស្នាក់នៅ គ្រាប់ពូជ និងឧបករណ៍ ក៏ដូចជា ការផ្តល់ហេដ្ឋារចនាសម្ព័ន្ធ ដូចជា សាលារៀន និងផ្លូវថ្នល់ផងដែរ ។ "ជំនួយមនុស្សធម៌" សំដៅលើជំនួយ ដែលផ្តល់ដោយអង្គការមនុស្សធម៌ សម្រាប់គោលបំណងមនុស្សធម៌ (ពោលគឺមិនទាក់ទងនឹងនយោបាយ ពាណិជ្ជកម្ម និង មិនទាក់ទងនឹងយោធាឡើយ) ។* |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Assisted migration | ការធ្វើចំណាកស្រុក ដោយមានការគាំពារ | N/A | N/A | បន្លាស់ទីរបស់ជនចំណាកស្រុកដែលសម្រេចបាន ដោយមានជំនួយពីរដ្ឋាភិបាលមួយឬច្រើន ឬអង្គការអន្តរជាតិមួយ ដែលខុសពីការធ្វើចំណាកស្រុកដោយឯកឯងនិង ដោយគ្មានការជួយគាំទ្រ ។ |
| Assisted voluntary return | ការបញ្ជូនត្រឡប់ធ្វើឡើងដោយស្ម័គ្រចិត្ត និងដោយមានការឧបត្ថម្ភគាំទ្រ | N/A | N/A | ការគាំទ្រខាងភ័ស្តុភារ និងហិរញ្ញវត្ថុដល់អ្នកស្វែងរកសិទ្ធិជ្រកកោន ដែលត្រូវបានគេបដិសេធ, ជនចំណាកស្រុក ដោយសារការជួញដូរ, និស្សិតតែលតោល, ជនបរទេសដែលមានគុណ-វុឌ្ឍិគ្រប់គ្រាន់ និងជនចំណាកស្រុកផ្សេងទៀតដែលមិនអាច ឬមិនមានបំណងបន្តស្នាក់នៅក្នុងប្រទេស ដែលខ្លួនកំពុងស្នាក់នៅ ហើយដែលប្រទេសនេះស្ម័គ្រចិត្តបញ្ជូនត្រឡប់ពួកគេទៅកាន់ប្រទេសដើមកំណើតវិញ ។ |
| Asylum (diplomatic) | ការផ្តល់សិទ្ធិជ្រកកោន (នៅក្រៅដែនដី) | N/A | Refuge, harborage, sanctuary, shelter | ជម្រកដែលរដ្ឋនានាអាចផ្តល់ឱ្យជនណាម្នាក់នៅក្រៅដែនដីរបស់ខ្លួននៅពេលដែលជននោះ ស្វះស្វែងរកកិច្ចការពារបញ្ចៀសផុតពីអាជ្ញាធរណាមួយដែលចង់ធ្វើទុក្ខបុកម្នេញ ឬទាមទារឱ្យប្រគល់ខ្លួន ។ ជម្រកនេះអាចផ្តល់ជូននៅកន្លែង ដែលទទួលបានអភ័យឯកសិទ្ធិពិសេស រួចផុតពីដែនយុត្តាធិការរបស់រដ្ឋជាម្ចាស់ផ្ទះ ដូចជា នៅតាមស្ថានបេសកកម្មការទូតនិងលំនៅដ្ឋានឯកជនរបស់ប្រធានបេសកកម្មការទូត នាវាចំបាំង ឬ យន្តហោះ ប៉ុន្តែមិនមែននៅក្នុងបរិវេណរបស់អង្គការអន្តរជាតិ ឬ ស្ថានកុងស៊ុលឡើយ ។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Asylum | ការផ្តល់សិទ្ធិជ្រកកោន (នៅក្នុងដែនដី) | N/A | Refuge, harborage, sanctuary, shelter | កិច្ចការពារដែលផ្តល់ដោយ រដ្ឋមួយទៅឱ្យជនបរទេសនៅលើដែនដីរបស់ខ្លួន ដើម្បីឱ្យជននោះគេចផុតពីយុត្តាធិការនៃរដ្ឋជាប្រទេសដើមរបស់ខ្លួន និងនាំឱ្យជននោះទទួលបានការប្រើប្រាស់សិទ្ធិមួយចំនួន ដែលទទួលស្គាល់ដោយអន្តរជាតិ ដោយផ្អែកលើគោលការណ៍នៃការមិនបញ្ជូនជនភៀសខ្លួនត្រឡប់ទៅវិញ។ |
| Asylum seeker | អ្នកស្វែងរកសិទ្ធិជ្រកកោន | N/A | N/A | បុគ្គលដែលស្វែងរកការអនុញ្ញាតឱ្យចូលទៅក្នុងប្រទេសមួយក្នុងនាមជាជនភៀសខ្លួន និងរង់ចាំការសម្រេចលើពាក្យសុំរបស់ខ្លួនដើម្បីទទួលឋានៈជាជនភៀសខ្លួន ស្របតាមបទប្បញ្ញត្តិច្បាប់អន្តរជាតិ និងជាតិ។ នៅក្នុងករណីមានការសម្រេចបដិសេធ ពួកគេត្រូវចាកចេញពីប្រទេសនោះ និងអាចត្រូវបណ្តេញចេញដូចជនបរទេសដែលស្ថិតក្នុងស្ថានភាពល្មើសច្បាប់ដទៃទៀតផងដែរ លើកលែងតែមានការអនុញ្ញាតឱ្យបន្តស្នាក់នៅដោយផ្អែកលើគោលការណ៍មនុស្សធម៌ ឬ មូលហេតុពាក់ព័ន្ធដទៃទៀត។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Backstopped (re)integration | សមាហរណកម្ម ដែលមានការជួយគាំទ្រ | N/A | N/A | ជាប្រភេទសមាហរណកម្មដែលរៀបចំឡើងដើម្បីសម្រួលដល់ជនរងគ្រោះក្នុងការចូលទៅរស់នៅក្នុងសហគមន៍វិញ តាមរយៈការបន្តជួយគាំទ្រ និងការលើកទឹកចិត្តផ្សេងៗ ។ |
| Bargaining | ការចរចា ការតថ្លៃ | Bargain | Negotiation | ការពិភាក្សាគ្នាដើម្បីឈានដល់ការព្រមព្រៀងទៅលើការលក់អ្វីមួយ ឬ ការចុះកិច្ចសន្យាណាមួយ ។ល។ |
| Basic needs | តម្រូវការមូលដ្ឋាន | Need | N/A | ស្របតាមទ្រឹស្តីពីរ៉ាមីតរបស់លោក អាប្រាហាម ម៉ាស្លូ តម្រូវការរបស់មនុស្សនៅខាងបាតពីរ៉ាមីតគឺជាតម្រូវការមូលដ្ឋានដែលរួមបញ្ចូលនូវតម្រូវការផ្លូវកាយ (ដូចជា អាហារ ទឹក ជម្រក សម្លៀកបំពាក់ អនាម័យ ការអប់រំ និងការថែរក្សាសុខភាព), ការគោរពឬការឱ្យតម្លៃ, សុវត្ថិភាព និង មិត្តភាព និងសេចក្តីស្រឡាញ់ ។ ក្នុងករណីមិនអាចបំពេញតាមតម្រូវការទាំងនេះទេ ខ្លួនមនុស្សយើងនឹងលែងមានលក្ខណៈរស់រវើក ហើយអារម្មណ៍ច្រាស់ច្រាល់ និងតឹងតែងនឹងកើតមានឡើង ។ |
| Beneficiary | អត្ថគាហក (អ្នកទទួលផល) | Benefit | Recipient, receiver | ជនណាម្នាក់ដែលទទួលបានផលប្រយោជន៍ពីសកម្មភាព ឬ ពីការផ្លាស់ប្តូរណាមួយ ។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Best interests of the victim | ឧត្តមប្រយោជន៍របស់ជនរងគ្រោះ | N/A | N/A | សំដៅលើប្រយោជន៍ផ្សេងៗដែលផ្តល់ដោយផ្ទាល់និងជាលក្ខណៈបុគ្គលដល់ជនរងគ្រោះ ដែលរួមមានការបំពេញតម្រូវការមូលដ្ឋាន, តម្រូវការជាក់លាក់ផ្សេងៗផ្នែករូបរាងកាយអារម្មណ៍ និងអប់រំ ទាំងពេលបច្ចុប្បន្ន និង អនាគត, និងការឆ្លើយតបទៅនឹងគ្រោះថ្នាក់ឬហានិភ័យផ្សេងៗដែលកើតមាន ឬនឹងអាចកើតមាន ។ |
| Best practices | បទពិសោធន៍ល្អៗ ឬបទពិសោធគំរូ | N/A | N/A | មធ្យោបាយ ដើម្បីជម្រុញការអនុវត្តនិយាម និងគោលការណ៍នានាដែលមានស្រាប់ ទាំងនៅថ្នាក់អន្តរជាតិ និងថ្នាក់ជាតិ ។ បទពិសោធន៍ល្អៗអាចបម្លែងទៅជាសេចក្តីណែនាំអនុវត្ត ក្រមអនុវត្ត ឬ រូបភាពផ្សេងៗរបស់ច្បាប់ ។ ក៏ប៉ុន្តែការបម្លែងនេះមិនគួរធ្វើឱ្យចុះខ្សោយ ឬ លុបចោលនូវច្បាប់វិជ្ជមានឡើយ ។ បទពិសោធន៍ល្អៗមានលក្ខណៈជាការបង្កើតថ្មី, ជាការបង្កើតឱ្យមានដំណោះស្រាយបែបច្នៃប្រឌិត, ជាការបង្ហាញឥទ្ធិពលវិជ្ជមានមកលើកម្រិតនៃការអនុវត្តសិទ្ធិរបស់ជនចំណាកស្រុក, ជាការបង្កើតឱ្យមានឥទ្ធិពលចិរកាល ជាពិសេសពាក់ព័ន្ធនឹងជនចំណាកស្រុកខ្លួនឯងផ្ទាល់ និងការបង្កើតជាសក្តានុពលសម្រាប់យកជាគំរូ ។ |
| Bilateral | ទ្វេភាគី (ពីរភាគី) | N/A | Two-sided | ការពាក់ព័ន្ធជាមួយភាគីពីរ ឬ រដ្ឋចំនួនពីរ ។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
| --- | --- | --- | --- | --- |
| Bind | ជាប់កាតព្វកិច្ច | Bind | N/A | ប្រសិនបើអ្នកជាប់នៅក្នុងកិច្ចព្រមព្រៀងមួយ ឬ កិច្ចសន្យាណាមួយ ។ល ។ អ្នកត្រូវធ្វើអ្វីដែលអ្នកបានឯកភាពថានឹងធ្វើ ឬដែលបានសន្យាថាត្រូវធ្វើ ។ |
| Birth certificate | សំបុត្រកំណើត | N/A | N/A | ឯកសារដើម តាមធម្មតាចេញដោយអាជ្ញាធររដ្ឋាភិបាល ឬអាជ្ញាធរសាសនា ដែលអាចមានចែងអំពីពេលវេលា និងទីកន្លែងដែលមនុស្សណាម្នាក់កើត ។ |
| Black market | ទីផ្សារខុសច្បាប់ (ទីផ្សារងងឹត) | N/A | Bootleg market, gray market, illegal sales, underground market | ការលក់-ទិញទំនិញមិនស្របច្បាប់ ឬ ទំនិញតាមថ្លៃ ឬតាមបរិមាណមិនស្របច្បាប់ (ពោលគឺ ថ្នាំក្លែងក្លាយ អាវុធ មនុស្សជាដើម) |
| Bona fide (latin) | សុចរិត | N/A | Genuine, sincere | "ដោយស្មោះត្រង់ "។ ដែលធ្វើឡើងដោយគ្មានការឆបោក ឬក្លែងបន្លំ ។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Bond | ប្រាក់ធានា<br>ប័ណ្ណធានា | N/A | N/A | បរិមាណជាសាច់ប្រាក់ ដែលរដ្ឋប្រមូលបានក្នុងនាមជាការធានាថាជនបរទេសត្រូវចាត់វិធានការចាំបាច់ខ្លះ១ ដូចជាការចាកចេញពីរដ្ឋនោះជាដើម ។ ប្រាក់ធានាការចេញដំណើរអាចត្រូវប្រមូលយកនៅពេលផ្តល់ទិដ្ឋាការ ឬ ពេលចូលក្នុងប្រទេសនោះ ។ ជាធម្មតាមូលនិធិ ដែលតំកល់ទុកជាប្រាក់ធានា នឹងត្រូវបង្វិលសងវិញនៅពេលមានភ័ស្តុតាងបញ្ជាក់ពីការចាកចេញពីប្រទេសមួយ ដូចជានៅពេលបុគ្គលនោះចូលទៅបង្ហាញខ្លួនចំពោះមុខស្ថានកុងស៊ុលរបស់រដ្ឋនោះនៅក្នុងប្រទេសកំណើតរបស់ខ្លួន ។ |
| Bondage | ទាសភាព | N/A | Slavery | ភាពស្ថិតនៅក្រោមការគ្រប់គ្រងផ្តាច់ការរបស់បុគ្គលផ្សេងទៀត ។ |
| Bonded labor (debt bondage) | ការបញ្ចាំខ្លួនដោះបំណុល | N/A | N/A | ជាប្រព័ន្ធមួយដែលជនណាម្នាក់បញ្ចាំខ្លួនបម្រើគេ ឬ ស្ថិតក្រោមការគ្រប់គ្រងរបស់ជនម្នាក់ទៀតដែលជនរងគ្រោះមិនអាចសងបំណុលពិតដែលខ្លួនបានជំពាក់ ។ |
| Border control | ការត្រួតពិនិត្យនៅតាមព្រំដែន | N/A | N/A | ការគ្រប់គ្រងរបស់រដ្ឋមួយទៅលើការធ្វើដំណើរចូលរបស់បុគ្គលណាម្នាក់មកក្នុងដែនដីរបស់ខ្លួន (ក្នុងក្របខ័ណ្ឌនៃការអនុវត្តអធិបតេយ្យភាពរបស់រដ្ឋនោះ) ។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Border management | ការគ្រប់គ្រងព្រំដែន | N/A | N/A | ការសម្រួលឱ្យមានលំហូរស្របច្បាប់នៃធុរជន អ្នកទេសចរ ជនចំណាកស្រុក និងជនភៀសខ្លួន និងការស្វែងរកឱ្យឃើញ និងការទប់ស្កាត់ការចូលមកដោយខុសច្បាប់ពីសំណាក់ជនបរទេសទៅក្នុងប្រទេសណាមួយ ។ វិធានការនានាដើម្បីគ្រប់គ្រងព្រំដែនរួមមាន ការតម្រូវដោយរដ្ឋឱ្យមានទិដ្ឋាការ ការដាក់ទណ្ឌកម្មមកលើក្រុមហ៊ុនដឹកជញ្ជូន ដែលនាំមកនូវជនបរទេសចូលក្នុងដែនដីរបស់ខ្លួន និងការហាមឃាត់ការចូលមកក្នុងដែនសមុទ្រ ។ បទដ្ឋានអន្តរជាតិ តម្រូវឱ្យមានតុល្យភាពរវាងការសម្រួលឱ្យអ្នកដំណើរស្របច្បាប់ចូល និងការទប់ស្កាត់អ្នកដំណើរដែលចូលក្នុងប្រទេស ដោយសារតែហេតុផលមិនសមស្រប ឬ ដោយមានឯកសារមិនត្រឹមត្រូវ ។ |
| Border officials | មន្ត្រីព្រំដែន | N/A | N/A | ពាក្យទូទៅមួយសម្រាប់អធិប្បាយអំពីមន្ត្រីដែលមានភារកិច្ចចម្បងក្នុងការយាមកាមព្រំដែន និងអនុវត្តច្បាប់អន្តោប្រវេសន៍ (និងអាចអនុវត្តច្បាប់គយ) របស់រដ្ឋមួយ ។ មន្ត្រីព្រំដែនអាចជា "ទាហានព្រំដែន", "នគរបាលព្រំដែន" ឬ "នគរបាលអន្តោប្រវេសន៍" ។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Border pass | ប័ណ្ណព្រំដែន | N/A | Passport, travel document | ជាឯកសារផ្លូវការសម្រាប់ចេញ-ចូលប្រទេសជាប់ព្រំដែនដែលបានយល់ព្រមចុះកិច្ចព្រមព្រៀងអនុញ្ញាតឱ្យពលរដ្ឋរស់នៅតាមខេត្តជាប់ព្រំដែនរវាងប្រទេសពីរអាចចេញ-ចូល និង ប្រកបអាជីវកម្មនៅតាមទីកន្លែងជាក់លាក់នៅតាមតំបន់ព្រំដែន ។ នៅប្រទេសកម្ពុជា ប័ណ្ណព្រំដែននេះមានសណ្ឋានជាកូនសៀវភៅទំហំប្រហាក់ប្រហែលលិខិតឆ្លងដែន (Passport) ហើយប័ណ្ណនេះត្រូវចេញដោយមន្ត្រីអន្តោប្រវេសន៍ធ្វើការនៅតាមច្រកទ្វារព្រំដែនសម្រាប់រយៈសុពលភាព ១ ឆ្នាំ ។ ពលរដ្ឋដែលកាន់ប័ណ្ណនេះត្រូវមកជួបមន្ត្រីអន្តោប្រវេសន៍១សប្តាហ៍ម្តងជាទៀងទាត់ដើម្បីពិនិត្យតាមដានលើសុពលភាព និងការប្រើប្រាស់ប័ណ្ណ ។ |
| Boycott | ធ្វើពហិការ | Boycott | Refuse, reject, stay away from | បដិសេធមិនទិញ ឬ មិនប្រើប្រាស់របស់នានា ឬ មិនចូលរួមធ្វើអ្វីមួយដោយប្រើប្រាស់រូបភាពទាំងនេះជាមធ្យោបាយសម្រាប់សំដែងចេញនូវការជំទាស់របស់ខ្លួន ។ |
| Breach | រំលោភ ឬ បំពាន (ច្បាប់ឬកិច្ចសន្យា) | breach | Infringe, violate, break, contravene | រំលោភច្បាប់ បទបញ្ជា ឬ កិច្ចព្រមព្រៀង ។ |
| Brain drain | ការធ្វើចំណាកស្រុក (អ្នកដែលមានចំណេះដឹង និងជំនាញខ្ពស់) | N/A | N/A | ការចាកចេញនៃបុគ្គលដែលបានទទួលការបណ្តុះបណ្តាល និង មានទេពកោសល្យពីប្រទេសរបស់ខ្លួន ទៅប្រទេសទីបីដោយសារតែមូលហេតុនានា ដូចជា ជម្លោះ ឬ កង្វះឱកាសនានា ។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Broker | មេខ្យល់<br>ឈ្មួញកណ្តាល<br>មេអណ្តើក | N/A | Intermediary, middleperson | *មេខ្យល់គឺជាភាគីមួយ ដែលធ្វើជាអន្តរការីរវាងអ្នកទិញ និងអ្នកលក់ ។* |
| Brothel | ផ្ទះបន<br>កន្លែងប្រកបរបរពេស្យាចារ | N/A | Bordello, whorehouse, cathouse | *ជាកន្លែងសម្រាប់ប្រកបតែរបរពេស្យាចារ ដោយផ្តល់ស្ត្រីពេស្យានូវកន្លែងដើម្បីជួប និងរួមភេទជាមួយអតិថិជន ។ នៅក្នុងប្រទេសខ្លះ ផ្ទះបនជាកន្លែងស្របច្បាប់ ហើយនៅក្នុងប្រទេសជាច្រើនទៀត គ្រឹះស្ថានមួយចំនួនដូចជា ហាងម៉ាស្សា ក៏ត្រូវបានអនុញ្ញាតឱ្យដំណើរការក្នុងរូបភាពជាផ្ទះបនដោយមានការគ្រប់គ្រង និងការទប់ស្កាត់ទៅតាមកម្រិតផ្សេងៗគ្នា ។* |
| Burden of proof | បន្ទុកនៃភ័ស្តុតាង | N/A | N/A | *ករណីយកិច្ចរបស់ភាគីណាមួយក្នុងការផ្តល់ភ័ស្តុតាងបញ្ជាក់ពីចំណុចនៃជម្លោះឬភ័ស្តុតាងដាក់បន្ទុក ។ នៅក្នុងបរិបទទេសន្តរ-ប្រវេសន៍ ជាទូទៅជនបរទេសដែលចង់ចូលទៅក្នុងប្រទេសដទៃត្រូវទទួលខុសត្រូវចំពោះបន្ទុកនៃភ័ស្តុតាង ពោលគឺជនបរទេសនោះត្រូវបង្ហាញថាខ្លួន ត្រូវបានផ្តល់សិទ្ធិឱ្យចូលទៅក្នុងរដ្ឋនោះ ហើយការចូលនេះមិនត្រូវបានហាមឃាត់ដោយច្បាប់ផ្សេងៗរបស់រដ្ឋនោះឡើយ ។* |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Call for | អំពាវនាវ | N/A | Appeal for | ប្រសិនបើមនុស្សមួយក្រុមអំពាវនាវចង់បានអ្វីមួយ ពួកគេនិយាយជាសាធារណៈ ដើម្បីឱ្យមានការអនុវត្តកិច្ចការនោះ ។ |
| Capacity building | ការកសាងសមត្ថភាព<br>ការពង្រឹងសមត្ថភាព | N/A | N/A | ដំណើរការមួយដែលបុគ្គលស្ថាប័ន និងសង្គមបង្កើតសមត្ថភាពដាច់ដោយឡែករបស់ខ្លួន ឬ រួមគ្នា ដើម្បីអនុវត្តមុខនាទីដោះស្រាយបញ្ហា នឹងកំណត់ និងសម្រេចគោលដៅរបស់ពួកគេ ។ |
| Caregiver | អ្នកថែទាំ | Care | Care provider | បុគ្គល ឬ បុគ្គលិកដែលធ្វើការឱ្យស្ថាប័នណាមួយ ហើយមានតួនាទីមើលថែទាំជនរងគ្រោះ ដើម្បីឱ្យពួកគេទទួលបានសេវាថែទាំពេញលេញ ។ |
| Case management | ការគ្រប់គ្រងករណី | N/A | N/A | គឺជាដំណើរការមួយធ្វើឡើងសម្រាប់បង្កើតក្របខ័ណ្ឌផ្ដល់សេវាដល់ជនរងគ្រោះដោយសារការជួញដូរ ។ ដំណើរការនេះចាប់ផ្ដើមឡើងនៅពេលដែលជនរងគ្រោះឬបុគ្គលដែលអាចជាជនរងគ្រោះត្រូវបានកំណត់អត្តសញ្ញាណ និងឆ្លងកាត់ដំណាក់កាលបន្តបន្ទាប់ទៀតដែលមាន ដូចជា អន្តរាគមន៍វិបត្តិ ការបញ្ជូន ការទទួល ការរៀបចំផែនការករណី ការប៉ាន់ប្រមាណ ការស្តារសមាហរណកម្ម ការតាមដាន និងការបិទករណី ។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
| --- | --- | --- | --- | --- |
| Case plan | ផែនការករណី | N/A | N/A | គឺជាសំណុំឯកសាររបស់ជនរងគ្រោះម្នាក់ៗដែលមានកំណត់ត្រាផ្សេងៗដូចជាគោលដៅ គោលបំណងឬលទ្ធផល វិធីដោះស្រាយឬវិធានការ ធនធាន ពេលវេលា និងបញ្ហាប្រឈមជាដើម ។ |
| Cell | បន្ទប់ឃុំឃាំង | N/A | N/A | បន្ទប់ឃុំឃាំងនៅក្នុងគុកឬនៅក្នុងប៉ុស្តិ៍នគរបាលសម្រាប់ឃុំខ្លួនអ្នកទោស ឬជនសង្ស័យប្រព្រឹត្តបទល្មើស ។ |
| Certificate of identity | លិខិតបញ្ជាក់អត្តសញ្ញាណ | N/A | N/A | ឯកសារមួយ (ក្រៅពីលិខិតឆ្លងដែន) ដែលចេញដោយរដ្ឋាភិបាលឱ្យទៅបុគ្គលណាម្នាក់ ដើម្បីសម្រួលដល់បុគ្គលនោះក្នុងការចូល ឬ ចេញពីប្រទេស ។ |
| Challenge | បញ្ហាប្រឈម<br>ការប្រឈម | N/A | Difficulty | ជាអ្វីមួយដែលថ្មី និងលំបាក ដែលទាមទារឱ្យមានកិច្ចប្រឹងប្រែង និងការប្តេជ្ញាខ្លាំងក្លា ។ |
| Change of status | ការផ្លាស់ប្តូរស្ថានភាពឬឋានៈ | N/A | N/A | នីតិវិធីដែលជនបរទេសមានវត្តមាន ដោយស្របច្បាប់នៅក្នុងរដ្ឋមួយអាចសុំប្តូរស្ថានភាព អន្តោប្រវេសន៍របស់ខ្លួន ។ ឧទាហរណ៍ ច្បាប់អាចចែងថា នៅក្រោយបញ្ចប់ការសិក្សារបស់ខ្លួន និស្សិតបរទេសអាចស្នើសុំប្តូរស្ថានភាពរបស់ខ្លួនពីអ្នកកាន់ទិដ្ឋាការសិក្សាមកជាអ្នកកាន់ទិដ្ឋាការដែលត្រូវអនុញ្ញាតឱ្យធ្វើការបាន ។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Charged person | ជនត្រូវចោទ | Charge | N/A | ជនសង្ស័យដែលត្រូវព្រះរាជអាជ្ញាធ្វើការចោទប្រកាន់ ហើយត្រូវបានដាក់នៅក្រោមការស៊ើបអង្កេត ដែលធ្វើឡើងដោយចៅក្រមស៊ើបសួរ ។ |
| Checkpoint | ច្រកឆែកឆេរ<br>ប៉ុស្តិ៍ត្រួតពិនិត្យ | N/A | N/A | ទីកន្លែងមួយ (នៅតាមព្រំដែនគោក ឬ នៅតាមព្រលានយន្តហោះ ឬ កំពង់ផែសមុទ្រ) ដែលអ្នកឆ្លងកាត់ទាំងឡាយត្រូវមន្ត្រីធ្វើការតាមព្រំដែនបង្គាប់ឱ្យឈប់ ដើម្បីធ្វើការត្រួតពិនិត្យ និងបញ្ជាក់មុននឹងអាចឱ្យចូលទៅក្នុងរដ្ឋនោះ ។ |
| Child | កុមារ<br>អនីតិជន | N/A | Kid, adolescent, infant, juvenile, teenager, teen | បុគ្គលដែលមានអាយុក្រោមដប់ប្រាំបីឆ្នាំ លើកលែងតែច្បាប់ពាក់ព័ន្ធនឹងកុមារចែងថា អ្នកទាំងនោះទទួលបានភាពជានីតិជន (ជាមនុស្សពេញវ័យ) នៅមុនអាយុ (ការទទួលបានអត្តាធិនភាព) ។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Child exploitation | ការកេងប្រវ័ញ្ច ឬ ការធ្វើអាជីវកម្មលើកុមារ | N/A | N/A | យោងតាមអនុសញ្ញាស្តីពីសិទ្ធិកុមារ ឆ្នាំ ១៩៨៩ និងអនុសញ្ញាដែលទាក់ទងនឹងការហាមឃាត់ និងសកម្មភាពបន្ទាន់ ដើម្បីលុបបំបាត់គ្រប់ទម្រង់នៃពលកម្មកុមារឆ្នាំ ១៩៩៩ ការកេង-ប្រវ័ញ្ចលើកុមាររួមមាន ការកេងប្រវ័ញ្ចខាងសេដ្ឋកិច្ច (ការងារណាដែលទំនងជាមានគ្រោះថ្នាក់ ឬ ប៉ះពាល់ដល់ការសិក្សារបស់កុមារ ឬ មានគ្រោះថ្នាក់ដល់សុខភាព ឬ វិវឌ្ឍន៍នៃរាងកាយ ប្រាជ្ញា ស្មារតី សីលធម៌ ឬ សង្គមរបស់កុមារ ការកេងប្រវ័ញ្ចខាងផ្លូវភេទ (ការបំពានខាងផ្លូវភេទ ពេស្យាចារ ការថតរូបអាសអាភាស) ការចាប់ពង្រត់ ការលក់ ឬ ជួញដូរកុមារ ឬ ទម្រង់ដទៃទៀតនៃការកេងប្រវ័ញ្ចលើកុមារ។ |
| Child grooming | ការលួងលោមកុមារក្នុងគោលដៅរំលោភផ្លូវភេទ | N/A | N/A | អំពើដែលធ្វើឡើង ដោយចេតនា ក្នុងបំណងបង្កើតភាពជិតស្និទ្ធ និងបង្កើតទំនាក់ទំនងខាងផ្លូវចិត្តជាមួយកុមារ ដើម្បីកាត់បន្ថយការរារាំងរបស់កុមារនៅក្នុងការត្រៀមខ្លួនទប់ទល់ចំពោះ ការបំពានខាងផ្លូវភេទ។ |
| Child labor | ពលកម្មកុមារ | N/A | N/A | ការងារដែលធ្វើឡើងដោយកុមារ ដែលនាំឱ្យមានគ្រោះថ្នាក់ទៅលើសុខភាពឬការសិក្សា វិវឌ្ឍន៍ខាងរាងកាយ ប្រាជ្ញាស្មារតី សីលធម៌ និងសង្គមរបស់កុមារ។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Child pornography | រូបភាពនិងសម្ភារអាសអាភាសនៃកុមារ | N/A | N/A | ជាសម្ភារដែលអាចមើលឃើញនឹងភ្នែក ដូចជារូបថត ខ្សែវីដេអូ រួមទាំងសម្ភារអេឡិចត្រូនិច ដែលពិពណ៌នាអំពីកេរភេទ ឬភាពអាសអាភាសប្រហាក់ប្រហែលផ្សេងទៀតដែលធ្វើឱ្យរំភើប ឬរំជួលដល់ចំណង់ផ្លូវភេទ។ |
| Child prostitution | អំពើពេស្យាចារកុមារ | N/A | N/A | ជាអំពើរួមភេទ ឬ អំពើគ្រប់រូបភាពផ្សេងទៀតដែលទាក់ទងនឹងភេទ រវាងអនីតិជនជាមួយជនដទៃ ដើម្បីផ្ដោះប្ដូរទៅនឹងវត្ថុមានតម្លៃអ្វីមួយ។ |
| Child protection | ការការពារកុមារ | N/A | N/A | អធិប្បាយអំពីសេវាកម្មផ្សេងៗដែលផ្ដល់ដោយរដ្ឋាភិបាល ឬស្ថាប័នមិនមែនរដ្ឋាភិបាល ដើម្បីការពារកុមារ។ តាមធម្មតាសេវាទាំងនេះរួមមាន ការស៊ើបអង្កេតលើបទចោទប្រកាន់អំពីការបំពានលើកុមារ សេវាការពារកុមារ ការបីបាច់ថែរក្សាជាកូនធម៌ សេវាបីបាច់ថែរក្សាជាកូនចិញ្ចឹម និងសេវានានាដែលមានគោលដៅគាំទ្រដល់គ្រួសារ ដែលប្រឈមមហានិភ័យ ដើម្បីឱ្យពួកគេអាចចៀសផុតពីបញ្ហាប្រឈមទាំងនោះ។ |
| Child sex tourism | ទេសចរណ៍ផ្លូវភេទលើកុមារ | N/A | N/A | ជាការធ្វើដំណើរទៅប្រទេសមួយផ្សេងទៀត ក្នុងបំណងចូលរួមក្នុងសកម្មភាពបំពានខាងផ្លូវភេទលើកុមារ។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Child sexual abuse | ការរំលោភផ្លូវភេទលើកុមារ | N/A | N/A | ជាទម្រង់មួយនៃការបំពានលើកុមារ ដែលក្នុងនោះកុមារត្រូវបានមនុស្សពេញវ័យ ឬមនុស្សជំទង់ ដែលមានវ័យច្រើនជាងបំពារបំពាន ដើម្បីទទួលបានការបំពេញចំណង់ផ្លូវភេទ។ បន្ថែមលើការប៉ះពាល់ផ្លូវភេទដោយផ្ទាល់ ការបំពានខាងផ្លូវភេទលើកុមារក៏កើតឡើងផងដែរនៅពេលដែលមនុស្សពេញវ័យបង្ហាញឱ្យឃើញយ៉ាងអនាចារនូវអង្គជាតិរបស់ខ្លួនដល់កុមារ ស្នើសុំ ឬកៀបសង្កត់ឱ្យកុមារចូលរួមនៅក្នុងសកម្មភាពផ្លូវភេទ បង្ហាញរូបអាសអាភាសដល់កុមារ ឬ ប្រើប្រាស់កុមារដើម្បីផលិតរូបអាសអាភាសកុមារ។ |
| Citizenship | ភាពជាពលរដ្ឋ<br>សញ្ជាតិ | N/A | Nationality | ភាពជាពលរដ្ឋមួយរូប។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Civil and political rights | សិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ | N/A | N/A | តាមធម្មតាត្រូវបានប្រើប្រាស់សម្រាប់អធិប្បាយអំពីសិទ្ធិខុសៗគ្នា ដែលមានចែងនៅក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ឆ្នាំ ១៩៦៦ (ដូចជា សិទ្ធិស្វ័យសម្រេច ការចាត់ចែងដោយសេរីនូវទ្រព្យ និងធនធាន ការមិនរើសអើង សិទ្ធិស្មើគ្នារវាងបុរសនិងស្ត្រី សិទ្ធិមានជីវិត សេរីភាពចាកផុតពីទារុណកម្ម អំពើឃោរឃៅ អមនុស្សធម៌ ឬ ការប្រព្រឹត្តថោកទាប ឬ ការដាក់ទណ្ឌកម្ម សិទ្ធិរួចផុតពីទាសភាព និង សេវភាព សិទ្ធិរួចផុតពីការចាប់ខ្លួនឬការឃុំឃាំងដោយបំពានសេរីភាពធ្វើដំណើរនៅក្នុងប្រទេស សិទ្ធិក្នុងការទទួលបានសេរីភាពនិងសន្តិសុខបុគ្គល សមភាពចំពោះមុខច្បាប់ សិទ្ធិទទួលបានការវិនិច្ឆ័យក្តីជាសាធារណៈនិងដោយត្រឹមត្រូវដោយតុលាការដែលមិនលំអៀងប្រឆាំងនឹងការចោទប្រកាន់ខាងព្រហ្មទណ្ឌ ការហាមឃាត់នូវការទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខណៈប្រតិសកម្ម (ធាក់ថយក្រោយ) សិទ្ធិឯកជនក្នុងផ្ទះ ក្នុងគ្រួសារ ឬការឆ្លើយឆ្លង សេរីភាពក្នុងការបញ្ចេញ គំនិត មនសិការ និងជំនឿសាសនា សេរីភាពនៃការសំដែងមតិ សិទ្ធិក្នុងការប្រមូលផ្តុំដោយសន្តិវិធី សេរីភាពក្នុងការចូលរួមជា សមាគម និងចូលរួមនៅក្នុងកិច្ចការសាធារណៈ) ។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Civil law | នីតិរដ្ឋប្បវេណី<br>ច្បាប់រដ្ឋប្បវេណី | N/A | N/A | ផ្នែកមួយនៃប្រព័ន្ធច្បាប់ដែលពាក់ព័ន្ធនឹងទំនាក់ទំនងខាងផ្លូវច្បាប់រវាងបុគ្គលឯកជន (ដែលមានដូចជាទំនាក់ទំនងចំពោះទ្រព្យសម្បត្តិ ទំនាក់ទំនងញាតិជាដើម) ហើយដែលវាត្រូវបានឱ្យឈ្មោះផងដែរថាជាច្បាប់ឯកជន។ |
| Claim | ការលើកឡើង<br>ការតវ៉ាទាមទារ | Claim | Assertion, declaration, demand | ការអះអាងដែលធ្វើនៅចំពោះមុខស្ថាប័នរដ្ឋាភិបាល ឬ តុលាការដោយស្នើសុំឱ្យមានចំណាត់ការ ឬ ការសម្រេចអំពីសិទ្ធិ ឬ ផលប្រយោជន៍ ដូចជា ឋានៈជាជនភៀសខ្លួន ឬ សិទ្ធិទទួលសំណង ឬ ការជួសជុលតាមផ្លូវច្បាប់នៅក្នុងនីតិវិធីរដ្ឋប្បវេណី ។ល។ |
| Clandestine migration | ទេសន្តរប្រវេសន៍ដោយលួចលាក់ | N/A | N/A | ចំណាកស្រុកដោយអាថិកំបាំង ឬ លួចលាក់ ដែលរំលោភលើលក្ខខណ្ឌអន្តោប្រវេសន៍។ វាអាចកើតឡើងនៅពេលដែលជនបរទេសរំលោភលើបទប្បញ្ញត្តិអំពី ការចូលក្នុងប្រទេសមួយ (ឧទាហរណ៍ដូចជាមិនមានឯកសារត្រឹមត្រូវជាដើម) ឬ បានចូលក្នុងប្រទេសមួយដោយស្របច្បាប់ ប៉ុន្តែស្នាក់នៅហួសកាលកំណត់ដែលជាការរំលោភលើបទប្បញ្ញត្តិអន្តោប្រវេសន៍។ |
| Client | កូនក្តី<br>អតិថិជន | N/A | N/A | បុគ្គលម្នាក់ដែលទទួលសេវាពីបុគ្គលមានជំនាញវិជ្ជាជីវៈ ដូចជាមេធាវី ឬទីភ្នាក់ងារផ្តល់សេវាគាំទ្រជនរងគ្រោះជាដើម។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Coercion | ការបង្ខិតបង្ខំ<br>ការចាប់បង្ខំ | Coerce | Compulsion, duress, oppression, force | ជាអំពើដែលធ្វើឡើងប្រឆាំងនឹងជនម្នាក់ផ្សេងទៀតដើម្បីឱ្យជននោះមិនអាចបញ្ចេញឆន្ទៈសេរីរបស់ខ្លួន។ ការបង្ខិតបង្ខំអាចស្តែងឡើងតាមទម្រង់ដូចជា៖ ការប្រើប្រាស់កម្លាំងឬការគំរាមកំហែងបង្កឱ្យមានគ្រោះថ្នាក់ឬការបង្ខាំងរូបកាយ, គ្រោង-ការណ៍ ផែនការ ឬគំរូ ដែលធ្វើឡើងក្នុងចេតនាបណ្តាលឱ្យជនណាម្នាក់ជឿជាក់ថាការខកខាមិនបានប្រព្រឹត្តអំពើណាមួយនឹងនាំឱ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរឬនាំឱ្យមានការបង្ខាំង រូបកាយ, ការគាបសង្កត់ផ្លូវចិត្តដើម្បីធ្វើឱ្យជនណាម្នាក់ជឿថារូបខ្លួនឬបុគ្គលផ្សេងទៀតនឹងត្រូវគេនាំយកចេញដោយមិនស្របច្បាប់ លក់-ដូរ ឬបង្ខាំង ជាដើម។ |
| Co-existence | សហត្ថិភាព (ការស្ថិតនៅ ឬការកើតមានជាមួយគ្នា) | Co-exist | N/A | ស្ថានភាពមួយនៃការអត់ធ្មត់ជាទូទៅរវាងសហគមន៍នៅក្រោយការបញ្ចប់អរិភាព (ភាពជាសត្រូវ) និងមុនមានការផ្សះផ្សា។ កិច្ចផ្តួចផ្តើមនានាដែលទាក់ទងនឹងអភិក្រម សហត្ថិភាពរួមមានការអប់រំអំពីសន្តិភាព ការអភិវឌ្ឍ សហគមន៍ដោយចីរភាព ការផ្តល់សិទ្ធិអំណាចខាងសេដ្ឋកិច្ច សង្គមដល់ជនភៀសខ្លួន ការធ្វើសមាហរណកម្មឡើងវិញនៃយុទ្ធជនកុមារ និងការបង្កើតភាពជាដៃគូ។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Commercial sexual exploitation | ការប្រកបរបរធ្វើអាជីវកម្ម កេងប្រវ័ញ្ចផ្លូវភេទ | N/A | Procuring | ជាអំពើទាញយកឬទទួលអត្ថប្រយោជន៍ហិរញ្ញវត្ថុពី អំពើពេស្យាចាររបស់ជនដទៃ, ការធ្វើឱ្យរីកចម្រើនដល់សកម្មភាពអាជីវកម្មពេស្យាចារ, ការជួយឬការពារអំពើពេស្យាចាររបស់ជនដទៃ, ការជ្រើសរើស អូសទាញ ឬបណ្ដុះបណ្ដាលបុគ្គលណាមួយឱ្យធ្វើពេស្យាចារ ឬ ការគាបសង្កត់លើបុគ្គលណាមួយដើម្បីឱ្យបុគ្គលនោះធ្វើពេស្យាចារ ។ |
| Commodity | ទំនិញ<br>របស់របរ | N/A | Article, asset, belonging, goods, material, object, property | ទំនិញមួយដែលត្រូវការ ប៉ុន្តែត្រូវបានផ្គត់ផ្គង់នៅក្នុងទីផ្សារដោយគ្មានការបែងចែកភាពខុសគ្នាខាងគុណភាព ។ នៅក្នុងបរិបទនៃការជួញដូរមនុស្ស មនុស្សត្រូវបានចាត់ទុកថាជាទំនិញ ។ |
| Community development | ការអភិវឌ្ឍសហគមន៍ | N/A | N/A | ដំណើរការមួយដើម្បីកែលម្អលក្ខខណ្ឌសេដ្ឋកិច្ច សង្គម និងវប្បធម៌របស់សហគមន៍ ។ ការអភិវឌ្ឍសហគមន៍មានគោលដៅធ្វើសមាហរណកម្មជនភៀសខ្លួនឬជនរងគ្រោះទៅក្នុងប្រទេសដែលទទួលយកពួកគេ ឬ ធ្វើសមាហរណកម្មអ្នកទាំងនោះទៅកាន់ប្រទេសដើម កំណើតវិញបន្ទាប់ពីការវិលត្រឡប់របស់ពួកគេ ហើយការធ្វើសមាហរណកម្មនេះត្រូវធ្វើឡើងជាមួយនឹងការកែលម្អជីវភាពរស់នៅរបស់សហគមន៍ពួកគេទាំងមូល ។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Complex emergency | វិបត្តិសង្គមធ្ងន់ធ្ងរនិង ស្មុគស្មាញ | N/A | N/A | *វិបត្តិមនុស្សធម៌ចាក់ស្រែះនៅក្នុងប្រទេស តំបន់ ឬ សង្គមមួយ ដែលមានការដួលរលំអំណាចគ្រប់គ្រងទាំងស្រុង ឬ មួយផ្នែកធំ ដោយសារជម្លោះផ្ទៃក្នុង ឬខាងក្រៅ និងដែលទាមទារឱ្យមានការឆ្លើយតបពហុវិស័យជាអន្តរជាតិ ដែលហួសពីអាណត្តិ ឬ សមត្ថភាព របស់ស្ថាប័នតែមួយ និង/ឬ កម្មវិធីរបស់ អ.ស.ប ដែលមានស្រាប់នៅក្នុងប្រទេសនោះ។ ស្ថានភាពវិបត្តិបែបនេះមានឥទ្ធិពលបំផ្លិចបំផ្លាញ ជាពិសេស មកលើកុមារ និងស្ត្រី និងទាមទារឱ្យមានការឆ្លើយតបច្រើនយ៉ាងពីគ្រប់លំដាប់ថ្នាក់។* |
| Confidentiality | ការសម្ងាត់ | N/A | Private | *ភាពអាថិកំបាំង ឬការមិនឱ្យលេចធ្លាយព្ធខ្សរខ្ចាយ។* |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
| --- | --- | --- | --- | --- |
| Confinement | ការបង្ខាំង | Confine | Detain, immure, incarcerate | អំពើនៃការឃុំឃាំងឬបង្ខាំងជនណាម្នាក់ផ្ទុយពីឆន្ទៈរបស់ជនរងគ្រោះដោយរារាំងជនរងគ្រោះមិនឱ្យចាក់ចេញពីទីកន្លែងបង្ខាំងនោះ។ ការបង្ខាំងក៏សំដៅផងដែរទៅលើការគ្រប់គ្រងបុគ្គលណាម្នាក់ដោយមន្ត្រីនគរបាលឬមន្ត្រីមានសមត្ថកិច្ចផ្សេងទៀតឬដោយបុគ្គលឯកជន ដោយគ្មានអំណាចតាមផ្លូវច្បាប់ឬហួសពីវិសាលភាពនៃសិទ្ធិអំណាចដែលច្បាប់បានកំណត់ និងដោយបានរារាំងជនរងគ្រោះមិនឱ្យចាកចេញពីទីកន្លែងបង្ខាំងនោះ។ ការបង្ខាំងអាចមានទម្រង់ជាការបង្ខាំងរូបកាយ (ឧទាហរណ៍ : ការរក្សាជនរងគ្រោះ ក្នុងបន្ទប់ចាក់សោ), ការបង្ខាំងផ្លូវចិត្ត (ឧទាហរណ៍ : ការបង្ខាំងដោយផ្អែកលើការគំរាមកំហែង), ការបង្ខាំងតាមវិជ្ជាជីវៈ (ឧទាហរណ៍ : និយោជករក្សាទុកលិខិតឆ្លងដែនឬឯកសារផ្សេងទៀតរបស់និយោជិតដើម្បីជាការធានាឬរក្សានិយោជិតកុំឱ្យចាកចេញ ឬការរក្សាទុកនិយោជិតឱ្យធ្វើការតាមរយៈការគំរាមកំហែងថានឹងបណ្ដេញចេញពីការងារជាដើម)។ ដូចគ្នានេះផងដែរ អង្គការដែលធ្វើការងារទីតិសម្បទាសង្គមនិងដែលទទួលអំណាចតាមផ្លូវច្បាប់ក្នុងការទទួលយកនិងថែរក្សាមនុស្សមួយចំនួន (ដូចជា ជនរងគ្រោះដោយអំពើជួញដូរមនុស្ស អ្នកប្រើប្រាស់គ្រឿងញៀន កុមារតាមចិញ្ចើម-ថ្នល់ ។ល។) មិនមានអំណាចតាមផ្លូវច្បាប់ធ្វើការបង្ខាំងពួកគេដោយផ្ទុយពីឆន្ទៈរបស់ពួកគេឬហាមឃាត់ពួកគេមិនឱ្យចាកចេញពីអគាររបស់អង្គការឡើយ។ ចំណែកឯម្ចាស់ផ្ទះវិញក៏មិនអាចហាមឃាត់ឈ្នួលបម្រើកុំឱ្យចាកចេញពីផ្ទះឡើយ។ (ស្រង់ចេញពី "កំណត់ពន្យល់ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ" បោះពុម្ព ខែមេសា ឆ្នាំ ២០១៣) |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Confiscation | ការរឹបអូស | Confiscate | Foreiture | សំដៅលើការដកហូតយកទ្រព្យសម្បត្តិជាអចិន្ត្រៃយ៍ដោយផ្អែកលើដីកា ឬ សេចក្តីសម្រេច ដែលចេញដោយតុលាការ ឬអាជ្ញាធរមានសមត្ថកិច្ច ។ |
| Consent | ការអនុញ្ញាត<br>ការយល់ព្រម | Consent | Approval, Permission, Compliance, authorization, Permit | ការផ្តល់ការទទួលយល់ព្រម ឬ ការឯកភាព ។ |
| Constitution | រដ្ឋធម្មនុញ្ញ | N/A | N/A | ច្បាប់គ្រឹះ និងច្បាប់រៀបចំអង្គការនៃរដ្ឋមួយដែលបង្កើតគោលគំនិត សំណុំលក្ខណៈ និងការចាត់ចែងរដ្ឋាភិបាលរបស់ខ្លួន ក៏ដូចជាការចែងអំពីវិសាលភាពនៃអំណាចអធិបតេយ្យរបស់ខ្លួន និងទម្រង់នៃអត្ថិភាពរបស់ខ្លួនផងដែរ ។ វាក៏មានន័យផងដែរថា ជាសន្ធិសញ្ញាដែលបង្កើតអង្គការអន្តរជាតិមួយ និង កំណត់អាណត្តិ និងការប្រព្រឹត្តទៅរបស់អង្គការនោះ ។ |
| Consular functions | តួនាទីរបស់ស្ថានកុងស៊ុល | N/A | N/A | រួមមានការការពារផលប្រយោជន៍របស់រដ្ឋបញ្ជូន( ឱ្យតាំងស្ថានកុងស៊ុល) និងជនជាតិរបស់ ខ្លួននៅលើទឹកដីនៃរដ្ឋទទួល (រដ្ឋម្ចាស់ផ្ទះ) ។ លើសពីនេះទៅទៀត ក៏មានការពង្រីកទំនាក់ទំនងពាណិជ្ជកម្ម សេដ្ឋកិច្ច វប្បធម៌ និងវិទ្យាសាស្ត្រ រវាងរដ្ឋបញ្ជូន និងរដ្ឋទទួល ។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Consular officer | មន្ត្រីកុងស៊ុល | N/A | N/A | មន្ត្រីរដ្ឋាភិបាលដែលតំណាងឱ្យរដ្ឋនៅក្រៅប្រទេស នៅក្នុងការចេញទិដ្ឋាការ និងបញ្ហានៃការស្នាក់នៅ។ មាត្រា ១(ឃ), នៃអនុសញ្ញាក្រុងវីយែន ស្តីពីទំនាក់ទំនងកុងស៊ុល ឆ្នាំ ១៩៦៣ ចែងថាមន្ត្រីកុងស៊ុលគឺជា "បុគ្គល (ដែលរួមទាំងប្រធានស្ថានកុងស៊ុល) ដែលត្រូវបានប្រគល់ភារកិច្ចឱ្យកាន់តួនាទីកុងស៊ុល"។ |
| Consular protection | កិច្ចការពារដោយស្ថានកុងស៊ុល | N/A | N/A | តួនាទីរបស់ស្ថានកុងស៊ុល ដែលមានគោលដៅផ្តល់ជំនួយដល់ជនរួមជាតិនៅក្រៅប្រទេស និងជួយការពារសិទ្ធិ និងផលប្រយោជន៍របស់ពួកគេនៅចំពោះមុខតុលាការរបស់រដ្ឋនោះ។ កិច្ចការពារបែបនេះ ក៏មានផងដែរ សម្រាប់ជនចំណាកស្រុកដែលត្រូវបានចាប់ខ្លួន ឬ ឃុំឃាំងនៅក្នុងពន្ធនាគារ ឬ ស្ថិតនៅក្រោមការឃុំគ្រងរង់ចាំការវិនិច្ឆ័យទោសឬឃុំឃាំងតាមទម្រង់ណាមួយផ្សេង-ទៀត។ ជនចំណាកស្រុកបែបនេះត្រូវតែបានជូនដំណឹងដោយគ្មានការពន្យាពេលអំពីសិទ្ធិរបស់ខ្លួនដើម្បីទាក់ទងជាមួយអាជ្ញាធរកុងស៊ុល។ ផ្នែកផ្តល់សេវាគាំទ្រ (ជាមុន) របស់ស្ថានកុងស៊ុលដែលជួយរដ្ឋាភិបាល និង ជនចំណាកស្រុកក្នុងការសម្រួល ការបំពេញបែបបទសុំទិដ្ឋាការមុនការដាក់ពាក្យសុំ។ សេវាទាំងនេះអាចរាប់បញ្ចូលទាំងជំនួយក្នុងការបំពេញ និង ចាត់ចែងឯកសារពាក្យសុំទិដ្ឋាការ ជំនួយក្នុងការប្រមូលផ្តុំឯកសារពាក់ព័ន្ធនឹងការដាក់ពាក្យសុំទិដ្ឋាការ ផ្ទៀងផ្ទាត់ឯកសារដែលទាក់ទងនឹងផ្លូវច្បាប់ ការសិក្សា និងការងារ និងការបកប្រែឯកសារផ្សេងៗ។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Contract | កិច្ចសន្យា | Contract | Agreement | កិច្ចសន្យាមួយគឺ ជាការសន្យាទៅវិញទៅមករវាងភាគីពីរ ឬច្រើន ដើម្បីធ្វើ ឬ មិនធ្វើអ្វីមួយ ពោលគឺ ជាកិច្ចដែលអាចយកមកប្រើប្រាស់បាននៅក្នុងតុលាការ ។ កិច្ចសន្យាគឺជាកិច្ចព្រមព្រៀងចងភ្ជាប់កាតព្វកិច្ចតាមផ្លូវច្បាប់ ។ |
| Contract slavery | ទាសភាពតាមរយៈកិច្ចសន្យា | N/A | N/A | ទម្រង់បែបថ្មីមួយនៃទាសភាព ដែលជនទន់ខ្សោយត្រូវបានបោកបញ្ឆោតឱ្យធ្លាក់ក្នុងទាសភាពតាមរយៈការប្រើប្រាស់កិច្ចសន្យាការងារក្លែងបន្លំ ។ អ្នកគ្រប់គ្រងទាសករ បង្កើតកិច្ចសន្យាដើម្បីបញ្ចុះបញ្ចូលបុគ្គលទាំងឡាយ ដោយសន្យាថានឹងផ្តល់ការងារឱ្យធ្វើ ប៉ុន្តែនៅពេលពួកគេទៅដល់កន្លែងត្រូវធ្វើ ពួកគេត្រូវបានបង្ខំឱ្យធ្វើការដោយគ្មានប្រាក់កម្រៃ និងមិនអាចរត់គេចខ្លួនបាន ។ កិច្ចសន្យាក្លែងបន្លំបែបនេះត្រូវបានប្រើប្រាស់ដើម្បីបញ្ចៀសនូវការចោទប្រកាន់ផ្នែកព្រហ្មទណ្ឌណាមួយ ឬដើម្បីបង្ហាញឱ្យឃើញពី "បំណុល" ដែលជនរងគ្រោះត្រូវជំពាក់ម្ចាស់ទាសករ ។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Convention | អនុសញ្ញា | N/A | N/A | កិច្ចព្រមព្រៀងផ្លូវការជាអន្តរជាតិ ក្នុងចំណោមប្រទេសនានា (ដែលជាសមាជិក) ដែលបង្កើតឱ្យមានកាតព្វកិច្ចតាមផ្លូវច្បាប់។ កិច្ចព្រមព្រៀងបែបនេះអាចមានឈ្មោះខុសៗគ្នា ដូចជា សន្ធិសញ្ញា អនុសញ្ញា កតិកាសញ្ញា ឬកិច្ចព្រមព្រៀង។ អនុសញ្ញាគឺជាប្រភេទមួយ ក្នុងចំណោមប្រភេទធំៗទាំងពីរនៃលិខិតុបករណ៍សិទ្ធិមនុស្សអង្គការសហប្រជាជាតិ។ រីឯប្រភេទមួយទៀតនោះគឺឈ្មោះលិខិតបទដ្ឋានទាក់ទងនឹងសេចក្តីសម្រេចរបស់អង្គការសហប្រជាជាតិ។ |
| Convicted person | ទណ្ឌិត | Convict | N/A | ជនជាប់ចោទដែលទទួលទោសកំណត់ដោយសាលក្រមឬសេចក្តីសម្រេចស្ថាពររបស់តុលាការ។ |
| Co-perpetrator | សហចារី | N/A | Co-actors, Principal in the second degree | ចារីដែលរួមគ្នានៅក្នុងការប្រព្រឹត្តបទល្មើស។ បុគ្គលច្រើននាក់ព្រមព្រៀងគ្នាប្រព្រឹត្តបទល្មើសរួមគ្នាដោយផ្ទាល់។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Corruption | អំពើពុករលួយ | Corrupt | Bribery | អំពើពុករលួយឬបទល្មើសពុករលួយគឺជាបទល្មើសទាំងឡាយណាដែលមានចែងក្នុងក្រមព្រហ្មទណ្ឌ និងច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ដែលមានដូចជា ការស៊ីសំណូកនៃនិយោជិត, ការសូកប៉ាន់ដល់និយោជិត, ការស៊ីសំណូករបស់អភិបាលជា-អាទិ៍, ការដេញថ្លៃមិនត្រឹមត្រូវ, ការសម្អាតប្រាក់, ការស៊ីសំណូកប្រព្រឹត្តដោយចៅក្រម, ការសូកប៉ាន់ចំពោះចៅក្រម, ការស៊ីសំណូករបស់សាក្សីដើម្បីធ្វើសក្ខីកម្មក្លែងក្លាយ, ការសូកប៉ាន់សាក្សី, ការស៊ីសំណូករបស់អ្នកបកប្រែ, ការសូកប៉ាន់អ្នកបកប្រែ, ការស៊ីសំណូករបស់អ្នកជំនាញ, ការសូកប៉ាន់អ្នកជំនាញ, បទល្មើសវិតិក្រម, បទស៊ីសំណូក, ជំនួញឥទ្ធិពលអកម្ម, ការកេងយកផលប្រយោជន៍ដោយខុសច្បាប់, បទបក្ខានុគ្រោះ, ការបំផ្លាញដោយចេតនានិងគៃបំបាត់ដោយទុច្ចរិត, ការសូកប៉ាន់, បទជំនួញឥទ្ធិពលសកម្ម, ការសម្លុតគំរាម, បទបំផ្លាញនិងគៃបំបាត់, ការស៊ីសំណូកដោយអ្នកមានទីតិសម្បទាដើម្បីធ្វើលិខិតបញ្ជាក់មិនពិត, ការស៊ីសំណូកដោយសមាជិកនៃគណៈវិជ្ជាជីវៈខាងវេជ្ជសាស្ត្រដើម្បីធ្វើលិខិតបញ្ជាក់មិនពិត, ការសូកប៉ាន់ចំពោះសមាជិកនៃគណៈវិជ្ជាជីវៈខាងវេជ្ជសាស្ត្រដើម្បីធ្វើលិខិតបញ្ជាក់មិនពិត, ការស៊ីសំណូកនៃមន្ត្រីសាធារណៈបរទេសឬមន្ត្រីអង្គការអន្តរជាតិសាធារណៈ, ការសូកប៉ាន់ចំពោះមន្ត្រីសាធារណៈបរទេស ឬមន្ត្រីអង្គការអន្តរជាតិសាធារណៈ, បទរំលោភអំណាច, បទមានទ្រព្យសម្បត្តិដោយខុសច្បាប់, បទទទួលផលបន្តពីបទល្មើសពុករលួយ និង បទល្មើសពុករលួយតូចតាច ។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Counseling | ការពិគ្រោះយោបល់ | Counsel | N/A | *សំដៅលើដំណើរការផ្ដែកទ្រឹស្ដីដែលមានលក្ខណៈអន្តរបុគ្គល និងរយៈពេលខ្លីក្នុងការជួយបុគ្គលណាម្នាក់ដែលនៅមានសុខភាពផ្លូវចិត្តធម្មតាឱ្យចេះស្វែងរកដំណោះស្រាយឆ្លើយតបទៅនឹងបញ្ហាផ្សេងៗ ។* |
| Country of destination | ប្រទេសគោលដៅ | N/A | N/A | *ប្រទេសដែលជាគោលដៅនៃលំហូរចំណាកស្រុក (ដោយស្រប ច្បាប់ ឬ មិនស្របច្បាប់) ។* |
| Country of first asylum | ប្រទេសទីមួយ ដែលផ្ដល់ សិទ្ធិជ្រកកោន | N/A | N/A | *ប្រទេសទីមួយដែលបានផ្ដល់សិទ្ធិជ្រកកោនដល់អ្នកសុំសិទ្ធិជ្រកកោនតាមផ្លូវច្បាប់ ។* |
| Country of habitat | ប្រទេសដែលជាលំនៅឋានអចិន្ត្រៃយ៍ | N/A | N/A | *ប្រទេសដែលបុគ្គលណាម្នាក់រស់នៅ ពោលគឺជាទីអាស្រ័យនៅជាប្រក្រតីរបស់បុគ្គលនោះ នៅក្នុងប្រទេសមួយដែលមានកន្លែងសម្រាប់គាត់រស់នៅ និងចំណាយពេលវេលាសម្រាកលំហែប្រចាំថ្ងៃរបស់ខ្លួន ។ ការធ្វើដំណើរទៅក្រៅប្រទេសជាបណ្ដោះអាសន្នសម្រាប់លំហែ សម្រាកកាយ ជួបមិត្តភក្តិ និងសាច់ញាតិ ការងារ ព្យាបាលជំងឺ ឬ ការប្រតិបត្តិតាមសាសនា មិនធ្វើឱ្យផ្លាស់ប្ដូរ ប្រទេសដែលជាកន្លែងស្នាក់នៅជាធម្មតារបស់បុគ្គលនេះឡើយ ។* |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Country of origin | ប្រទេសកំណើត<br>ប្រទេសប្រភព | N/A | N/A | ប្រទេសដែលជាប្រភពដើមរបស់ជនចំណាកស្រុក (ដោយស្របច្បាប់ ឬ មិនស្របច្បាប់) ។ |
| Country of transit | ប្រទេសសំចត | N/A | N/A | ប្រទេសដែលមានជនចំណាកស្រុកឆ្លងកាត់ (ដោយស្របច្បាប់ ឬ មិនស្របច្បាប់) ។ |
| Country of usual residence | ប្រទេសអាស្រ័យនៅជាប្រក្រតី | N/A | N/A | ប្រទេសដែលបុគ្គលណាម្នាក់រស់នៅ ពោលគឺប្រទេសដែលបុគ្គលនោះមានកន្លែងសម្រាប់ រស់នៅនិងសម្រាប់ចំណាយពេលវេលាសម្រាកលំហែប្រចាំថ្ងៃរបស់ខ្លួន។ ការធ្វើដំណើរទៅក្រៅប្រទេសជាបណ្ដោះអាសន្នសម្រាប់លំហែ សម្រាកកាយ ជួបមិត្តភក្ដិ និងសាច់ញាតិ ការងារព្យាបាលជំងឺ ឬ ការប្រតិបត្តិតាមសាសនាមិនធ្វើឱ្យផ្លាស់ប្ដូរប្រទេស ដែលជាកន្លែងស្នាក់នៅជាធម្មតារបស់បុគ្គលនេះឡើយ។ |
| Credibility assessment | ដំណើរការវាយតំលៃលើភាពដែលអាចជឿទុកចិត្តបាន | N/A | N/A | ជំហានដែលអនុវត្តនៅក្នុងការវិនិច្ឆ័យពាក្យសុំទិដ្ឋាការ ឬ ឋានៈអន្តោប្រវេសន៍ផ្សេងទៀត ដើម្បីកំណត់ថាតើព័ត៌មានដែលផ្ដល់ជូនដោយបេក្ខជននោះមានសង្គតិភាព និងជឿទុកចិត្តបានដែរឬទេ។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Crime | បទល្មើស | N/A | Offense | អំពើខុសឆ្គងដែលរំលោភលើវិធានជាធរមានផ្សេងៗ ។ បទល្មើសត្រូវបានកំណត់និយមន័យដោយច្បាប់របស់ប្រទេស ឬ របស់រដ្ឋនីមួយៗ ឬ ច្បាប់ព្រហ្មទណ្ឌដែលមានយុត្តាធិការ ។ ជាទូទៅបទល្មើសត្រូវបានចាត់ថ្នាក់ជាប្រភេទផ្សេងៗរួមមានបទល្មើសដោយប្រើប្រាស់ហិង្សា បទល្មើសប្រឆាំងទ្រព្យសម្បត្តិ និងបទល្មើសប្រឆាំងនឹងសណ្តាប់ធ្នាប់សាធារណៈ ជាដើម ។ |
| Criminal | ឧក្រិដ្ឋជន<br>ជនល្មើសច្បាប់ព្រហ្មទណ្ឌ | Criminalize | Offender | សំដៅលើបុគ្គលដែលរំលោភលើច្បាប់ព្រហ្មទណ្ឌ ឬ ប្រព្រឹត្តបទល្មើសផ្សេងៗដែលមានដូចជា បទឧក្រិដ្ឋ ឬមជ្ឈិម ជាដើម ។ |
| Criminal law | ច្បាប់ព្រហ្មទណ្ឌ<br>នីតិព្រហ្មទណ្ឌ | N/A | N/A | សំដៅលើអត្ថបទច្បាប់ទាំងឡាយនៅក្នុងដែនសមត្ថកិច្ចផ្សេងៗដែលមានលក្ខណៈរួមគឺការកំណត់អំពើណាមួយថាជាបទល្មើស និងកំណត់ទណ្ឌកម្មចំពោះការមិនគោរពតាម ។ |
| Custodian | អ្នកអាណាព្យាបាល | N/A | N/A | សំដៅលើបុគ្គលដែលគ្រប់គ្រងអនីតិជន (កុមារ) ដែលពុំមានអ្នកមានអំណាចមេបា (ឪពុក-ម្តាយ) នៅជួយថែរក្សា ។ ប្រសិនបើអ្នកមានអំណាចមេបាមិនបានកំណត់អ្នកអាណាព្យាបាលតាមមតកសាសន៍ (បណ្តាំមរតក) ទេនោះ តុលាការត្រូវជ្រើសតាំងអ្នកអាណាព្យាបាលសម្រាប់អនីតិជនតាមការទាមទាររបស់ញាតិ (នៅក្នុងបួនថ្នាក់) មេឃុំឬចៅសង្កាត់ នាយកមជ្ឈមណ្ឌលសាធារណៈ ឬ តំណាងអយ្យការ ។ (ដកស្រង់ចេញពីមាត្រា ១០៥២ និង ១០៦៨ នៃក្រមរដ្ឋប្បវេណី) ។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Custody | ការគ្រប់គ្រង<br>ការឃាត់ខ្លួន | N/A | Care, guardianship, curatorship, nurture, arrest, detention | ការទទួលខុសត្រូវលើការថែទាំ និងគ្រប់គ្រងបុគ្គលណាម្នាក់។ តុលាការអាចផ្តល់សិទ្ធិទៅ សាច់ញាតិ ឬអាណាព្យាបាលដទៃទៀតដើម្បីមាននាទីជាអ្នកគ្រប់គ្រងអនីតិជន។<br>អត្ថន័យមួយទៀតគឺសំដៅលើការឃាត់ខ្លួនដែលធ្វើឡើងដោយអាជ្ញាធរមានសមត្ថកិច្ច។ |
| Customary international law | ច្បាប់អន្តរជាតិដែលកើតចេញពីទំនៀមទំលាប់ | N/A | N/A | ច្បាប់អន្តរជាតិទាំងឡាយដែលប្រែក្លាយចេញពីការអនុវត្តជាប់ជាប្រចាំ និងមានសង្គតិភាព និងប្រតិបត្តិដោយរដ្ឋផ្សេងៗ ជាជាងប្រែក្លាយចេញពីខ្លឹមសារផ្លូវការរបស់សន្ធិសញ្ញា ឬ អត្ថបទច្បាប់មួយ។ ដើម្បីឱ្យការអនុវត្តរបស់រដ្ឋនីមួយៗអាចបង្កើតបានជាច្បាប់អន្តរជាតិ ដែលកើតចេញពីទំនៀមទម្លាប់ទៅបានលុះត្រាតែការអនុវត្តនេះធ្វើឡើងដោយមានស្មារតីភ្ជាប់ទៅនឹងកាតព្វកិច្ចផ្លូវច្បាប់។ បទប្បញ្ញត្តិមួយចំនួននៅក្នុងសេចក្តីថ្លែង-ការណ៍ជាសកលស្តីអំពីសិទ្ធិមនុស្សដែលរួមមានការហាមឃាត់អំពើទាសភាព ទារុណកម្ម ការឃុំឃាំង ដោយបំពាន និងហួសរយៈពេល និងការសម្លាប់ក្រៅប្រព័ន្ធតុលាការត្រូវបានទទួលស្គាល់ជាទូទៅថាជាជាផ្នែកមួយនៃច្បាប់អន្តរជាតិដែលកើតចេញពីទំនៀមទម្លាប់។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| De facto refugees | ជនភៀសខ្លួនតាមព្រឹត្តិន័យ | N/A | N/A | បុគ្គលដែលមិនត្រូវបានទទួលស្គាល់ថាជាជនភៀសខ្លួន ទោះតាមសេចក្តីដែលមានចែងនៅក្នុងអនុសញ្ញា អ.ស.ប ដែលទាក់ទងនឹងឋានៈជនភៀសខ្លួន ឆ្នាំ ១៩៥១ និងពិធីសារដែលទាក់ទងជាមួយឋានៈជនភៀសខ្លួនឆ្នាំ ១៩៦៧ និងជាជនដែលមិនអាច ឬ មិនមានឆន្ទៈ (ដោយសារមូលហេតុសមស្របណាមួយ) វិលត្រឡប់ ទៅកាន់ប្រទេសដែលខ្លួនមានសញ្ជាតិ ឬ ប្រទេសដែលជាលំនៅឋានអចិន្ត្រៃយ៍ក្នុងករណីពួកគេគ្មានសញ្ជាតិ ។ |
| De facto statelessness | ភាពគ្មានស្រុកទេសតាមព្រឹត្តិន័យ | N/A | N/A | ស្ថានភាពរបស់បុគ្គលនានាដែលមានសញ្ជាតិនៃរដ្ឋមួយ ប៉ុន្តែបានចាកចេញពីរដ្ឋនោះ ដោយពុំបានទទួលកិច្ចការពារពីរដ្ឋនោះ ឬ ដោយសារពួកគេបដិសេធមិនទទួលកិច្ចការពារបែបនេះ ឬ ដោយសាររដ្ឋនោះបដិសេធមិនការពារពួកគេ ។ ពាក្យនេះជារឿយៗត្រូវបានប្រើប្រាស់សម្រាប់ជនភៀសខ្លួន ។ |
| Debt bondage | ការបញ្ចាំខ្លួនដោះបំណុល | N/A | Bonded labor | ជាប្រព័ន្ធមួយដែលជនណាម្នាក់បញ្ចាំខ្លួនបម្រើគេ ឬ ស្ថិតក្រោមការគ្រប់គ្រងរបស់ជនម្នាក់ទៀត ដែលជនរងគ្រោះមិនអាចសងបំណុលពិតដែលខ្លួនបានជំពាក់ ។ |
| Debtor | កូនបំណុល | N/A | N/A | បុគ្គលម្នាក់ ក្រុម ឬអង្គការមួយ ដែលជំពាក់ប្រាក់របស់ម្ចាស់បំណុល ។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Decentralization | វិមជ្ឈការ | Decentralize | N/A | ការបង្កើតក្របខ័ណ្ឌស្ថាប័ន និងច្បាប់សម្រាប់ធ្វើសេចក្តីសម្រេច និងការពង្រឹងសិទ្ធិអំណាច នៃស្ថាប័ននៅថ្នាក់ក្រោមជាតិនៅលំដាប់ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ-សង្កាត់ ទាក់ទងនឹងដំណើរ-ការរដ្ឋបាល នយោបាយ និងច្បាប់ ។ |
| Deception | ការបោកបញ្ឆោត | Deceive | trickery | ជាស្ថានការណ៏ដែលជនល្មើសប្រើពាក្យកុហក ការផ្តល់ព័ត៌មានមិនពេញលេញ ឬរឿងមិនពិតជាពាក្យសម្តីឬជាទង្វើ ដើម្បីឱ្យជនរងគ្រោះជឿធ្វើអ្វីមួយ ។ |
| Defendant | ចុងចម្លើយ<br>ជនជាប់ចោទ | N/A | Appelant, litigant, suspect | បុគ្គលម្នាក់ដែលជាប់បណ្តឹងក្នុងរឿងក្តីរដ្ឋប្បវេណី ឬ រងការចោទប្រកាន់ក្នុងរឿងក្តីព្រហ្មទណ្ឌ ។ |
| Demand for trafficking | តម្រូវការជួញដូរមនុស្ស | N/A | N/A | សំដៅលើតម្រូវការកម្មករដែលមានសមត្ថភាពទាប ប្រាក់កម្រៃទាប នៅក្នុងការកេងប្រវ័ញ្ចកម្លាំងពលកម្ម ឬដើម្បីធ្វើពាណិជ្ជកម្មខាងផ្លូវភេទ ជាពិសេសលើស្ត្រីនិងកុមារ ។ |
| Demography | ប្រជាសាស្ត្រ | N/A | Population studies | ការសិក្សាអំពីប្រជាជន ជាពិសេស សំដៅលើទំហំ និងដង់ស៊ីតេរបាយ និងស្ថិតិសំខាន់ៗ ។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Dependant | អ្នករស់នៅក្នុងបន្ទុក | | N/A | ក្នុងការប្រើប្រាស់ទូទៅ សំដៅលើអ្នកដែលពឹងផ្អែកលើការឧបត្ថម្ភគាំទ្ររបស់មនុស្សម្នាក់ផ្សេងទៀត ។ នៅក្នុងបរិបទនៃការធ្វើចំណាកស្រុក ជាទូទៅ សហព័ទ្ធមួយ និងកូនតូចៗត្រូវបានចាត់ទុកថាជា "អ្នកក្នុងបន្ទុក" សូម្បីតែសហព័ទ្ធនោះមានស្ថានភាពហិរញ្ញវត្ថុដាច់ដោយឡែកក៏ដោយ ។ |
| Deportation | និរទេស<br>ការបញ្ជូនត្រឡប់ | Deport | Displacement, eviction, exile, expatriation, expulsion, extradition, removal | អំពើរបស់រដ្ឋមួយ( ក្នុងដំណើរការនៃការអនុវត្តអធិបតេយ្យភាពរបស់ខ្លួន) ក្នុងការនាំយកជនបរទេសចេញពីដែនដីរបស់ខ្លួនដើម្បីយកទៅកាន់កន្លែងណាមួយផ្សេងទៀត ក្រោយពីការបដិសេធមិនអនុញ្ញាត ឬ បញ្ឈប់ការអនុញ្ញាតឱ្យស្នាក់នៅ ។ |
| Deportee | ជនដែលត្រូវនិរទេស ឬ បញ្ជូនត្រឡប់ | Deport | N/A | បុគ្គលម្នាក់ដែលត្រូវបាននិរទេស ឬបញ្ជូនត្រឡប់ ឬកំពុងរង់ចាំការធ្វើនិរទេស ឬបញ្ជូនត្រឡប់ ។ |
| Deprivation | ការដកហូត<br>ការបំបាត់ | Deprive | Destitution, dispos-session, expropriation, withholding | អំពើនៃការដកហូត ការលះបង់ ឬលែងមានជាបន្ត។ អំពើនៃការបំបាត់ចោលឬដកហូត សេចក្តីថ្លៃថ្នូរ ឬសេរីភាពមួយចំនួន ។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Detainee | អ្នកដែលត្រូវបានឃុំឃាំង<br>អ្នកជាប់ឃុំ | Detain | N/A | *សំដៅលើបុគ្គលដែលជាប់ក្នុងការឃុំឃាំង។ បុគ្គលម្នាក់អាចជាប់ឃុំផ្ទុយពីឆន្ទៈរបស់ខ្លួន (ពោលគឺក្នុងករណីជួញដូរមនុស្ស ឬ ពលកម្មដោយបង្ខំ ឬអំពើពេស្យាចារ)។* |
| Detention (immigration) | ការឃុំខ្លួន<br>(ពាក់ព័ន្ធបញ្ហាអន្តោប្រវេសន៍) | Detain | Custody, detainment, incarceration, internment, quarantine | *ការឃុំខ្លួនក្នុងករណីអន្តោប្រវេសន៍ គឺជាគោលនយោបាយនៃការឃាត់ខ្លួនបុគ្គលនានា (ដែលជាប់សង្ស័យពីបទរំលោភលើទិដ្ឋាការ ការចូលដោយខុសច្បាប់ ឬការមកដល់ដោយគ្មានការអនុញ្ញាត) ឱ្យនៅក្នុងការឃុំឃាំងរហូតដល់មានការសម្រេចដែលធ្វើឡើងដោយអាជ្ញាធរ អន្តោប្រវេសន៍ក្នុងការផ្តល់ទិដ្ឋាការ និងដោះលែងពួកគេទៅក្នុងសហគមន៍ ឬ ធ្វើមាតុភូមិនិវត្តន៍ពួកគេទៅកាន់ប្រទេសដែលពួកគេធ្វើដំណើរមក។ ការឃុំឃាំងតាមអាជ្ញាគឺជាការអនុវត្តការឃុំខ្លួនដែលកំណត់ដោយច្បាប់ ឬ ការឃុំខ្លួនអ្នកដែលសុំសិទ្ធិជ្រកកោនខាងនយោបាយ ឬ អ្នកដែលត្រូវបានចាត់ទុកថាជនអន្តោប្រវេសន៍ខុសច្បាប់ ឬ ដែលបានមកដល់ក្នុងប្រទេសមួយដោយគ្មានការអនុញ្ញាត។* |
| Diaspora | ក្រុមមនុស្ស ឬ ក្រុមជនជាតិ ដែលរស់នៅរាយប៉ាយពេញពិភពលោក | N/A | N/A | *សំដៅលើបុគ្គលណាម្នាក់ ឬក្រុមជនជាតិ ដែលចាកចោលភូមិកំណើតពីបុរាណរបស់ខ្លួន ដោយរសាត់អណ្តែតទៅនៅតំបន់នានានៃពិភពលោក។* |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Diplomatic protection | កិច្ចការពារតាមផ្លូវទូត | N/A | N/A | គោលការណ៍គ្រឹះនៃច្បាប់អន្តរជាតិ ដែលរដ្ឋមួយមានសិទ្ធិការពារពលរដ្ឋរបស់ខ្លួន នៅពេលរងគ្រោះដោយសារអំពើដែលផ្ទុយនឹងច្បាប់អន្តរជាតិ ដែលប្រព្រឹត្តដោយរដ្ឋមួយផ្សេងទៀត ដែលពួកគេមិនអាចពេញចិត្តចំពោះកិច្ចការពារពីរដ្ឋក្រោយនេះតាមមធ្យោបាយធម្មតា។ ដោយធ្វើការដោះស្រាយករណីនៃប្រជាពលរដ្ឋរបស់ខ្លួន និងដោយផ្អែកលើដំណោះស្រាយការទូត ឬ នីតិវិធីតុលាការអន្តរជាតិជំនួសមុខឱ្យបុគ្គលនោះ នៅក្នុងសភាពជាក់ស្តែង រដ្ឋមួយអះអាងអំពីសិទ្ធិរបស់ខ្លួនក្នុងការធានាឱ្យមានការគោរពចំពោះបទបញ្ញានៃច្បាប់អន្តរជាតិមកលើបុគ្គលដែលស្ថិតក្រោមអំណាចរបស់ខ្លួន។ |
| Directive | សេចក្តីណែនាំ | N/A | N/A | ជាបទបញ្ជា ឬការណែនាំផ្លូវការ ដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ច។ |
| Discourage | បន្ថយបង្អាក់<br>មិនលើកទឹកចិត្ត | Discourage | Deter, dissuade | ធ្វើឱ្យជនណាម្នាក់មិនសូវទុកចិត្ត ឬ លែងមានឆន្ទៈធ្វើការងារអ្វីមួយ។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Discrimination | ការរើសអើង | Discriminate | Prejudice | ការខកខានក្នុងការយកចិត្តទុកដាក់ដល់មនុស្សគ្រប់រូបឱ្យបានស្មើៗគ្នានៅក្នុងករណីដែលពុំមានភាពខុសគ្នាសមហេតុផលរវាងអ្នកដែលបានទទួលការអនុគ្រោះ និងអ្នកមិនបានទទួលការអនុគ្រោះ។ ហាមឃាត់ការរើសអើងទាក់ទងនឹង "ជាតិសាសន៍ ភេទ ភាសា សាសនា" ឬ "ទម្រង់ណាមួយ ដូចជា ជាតិសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា នយោបាយ និងទស្សនៈផ្សេងទៀត សញ្ជាតិ ឬ សង្គម ទ្រព្យសម្បត្តិ កំណើត ឬស្ថានភាពផ្សេងទៀត"។ |
| Displacement | ការជម្លៀសឬបន្លាស់ទី | Displace | Movement, shift, removal | ការនាំយកបុគ្គលណាម្នាក់ចេញដោយបង្ខំពីផ្ទះ ឬ ប្រទេសរបស់ជននោះ ដែលជាញឹកញាប់ដោយសារតែជម្លោះប្រដាប់អាវុធ ឬ គ្រោះមហន្តរាយធម្មជាតិ។ |
| Dissociation | ការមិនចង់នឹកនាពីអ្វីមួយ ឬ ការផ្តាច់ខ្លួនចេញពីអ្វីមួយ | Dissociate | Division, separation | ការផ្តាច់ខ្លួន គឺជាការឆ្លើយតបធម្មតាមួយទៅនឹងការប៉ះទង្គិចណាមួយ និងទុកឱ្យអារម្មណ៍ ផ្តាច់ចេញឆ្ងាយពីការបទពិសោធន៍នានាដែលធ្ងន់ធ្ងរហួសហេតុមិនអាចឱ្យអារម្មណ៍ទទួលយកបាននៅក្នុងពេលណាមួយ។ នៅក្នុងបរិបទជួញដូរមនុស្ស និងចំណាកស្រុក បុគ្គលឬជនរងគ្រោះម្នាក់អាចផ្តាច់ខ្លួនឯងចេញពីប្រទេសលំនៅឋាន ឬ ពីវប្បធម៌របស់ខ្លួន។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Documented migrant | ជនចំណាកស្រុកស្របច្បាប់ | N/A | N/A | ជនចំណាកស្រុកដែលចូលទៅក្នុងប្រទេសមួយដោយស្របច្បាប់ និងស្នាក់នៅក្នុងប្រទេសនោះស្របតាមលក្ខណៈវិនិច្ឆ័យរបស់ប្រទេសនោះក្នុងការអនុញ្ញាតឱ្យចូល ។ |
| Documented migrant worker | កម្មករចំណាកស្រុកស្របច្បាប់ | N/A | N/A | ពលករចំណាកស្រុក ឬ សមាជិកម្នាក់នៃគ្រួសាររបស់គាត់ ដែលបានទទួលការអនុញ្ញាតឱ្យចូលស្នាក់នៅ និងចូលរួមនៅក្នុងសកម្មភាព ដែលផ្ដល់ប្រាក់កម្រៃនៅក្នុងរដ្ឋនោះ អនុលោមតាមច្បាប់នៃរដ្ឋនោះ និងកិច្ចព្រមព្រៀងអន្តរជាតិដែលរដ្ឋនោះ ចូលជាសមាជិក ។ |
| Domestic employees | បុគ្គលិកធ្វើការក្នុងភ្នាក់ងារទូតបរទេស | N/A | N/A | បុគ្គលជាជនបរទេស ដែលបានទទួលការអនុញ្ញាតក្នុងគោលបំណងជាក់លាក់នៃការផ្ដល់សេវាផ្ទាល់ខ្លួនដល់កិច្ចការទូតបរទេស និងបុគ្គលិកស្ថានកុងស៊ុលក្នុងប្រទេសរបស់បុគ្គលនោះ ។ |
| Domestic servitude | ភាពជាខ្ញុំបម្រើតាមផ្ទះ | N/A | N/A | ភាពជាមនុស្សម្នាក់ដែលធ្វើការ និងច្រើនតែរស់នៅផងដែរក្នុងក្រុមគ្រួសាររបស់និយោជក ។ នៅក្នុងបរិបទនៃការជួញដូរអ្នកបម្រើក្នុងផ្ទះនឹងទទួលបានកម្រៃតិចតួច ឬមិនទទួលបានកម្រៃទាល់តែសោះ និងធ្វើការនៅក្រោមលក្ខខណ្ឌគ្មានមនុស្សធម៌ ។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Domestic violence | អំពើហិង្សាក្នុងគ្រួសារ | N/A | N/A | *សំដៅលើអំពើហិង្សាដែលកើតមាន និងអាចកើតមានទៅលើប្ដីឬប្រពន្ធ កូនក្នុងបន្ទុក និងជនទាំងឡាយដែលរស់នៅក្រោមដំបូលផ្ទះ និងក្នុងបន្ទុកគ្រួសារ។ អំពើហិង្សានេះរួមមានអំពើប៉ះពាល់ដល់ជីវិត (ដូចជាមនុស្សឃាត...), អំពើប៉ះពាល់ដល់បូរណភាពរូបកាយ (ដូចជា ការបំពារបំពានលើរូបកាយ...), ការធ្វើទារុណកម្មឬការធ្វើអំពើឃោរឃៅ (ដូចជា ការធ្វើទុក្ខបុកម្នេញបង្កឱ្យមានការឈឺចុកចាប់ផ្លូវចិត្ត សតិអារម្មណ៍ បញ្ញាស្មារតី...) និងការឈ្លានពានខាងផ្លូវភេទ (ដូចជាការប្រើហិង្សាសេពសន្ថវៈ...)។* |
| Domicile | លំនៅឋាន | N/A | Residence, abode | *ទីកន្លែងដែលបុគ្គលម្នាក់មានវត្តមានជាក់ស្ដែង និងដែលបុគ្គលនោះចាត់ទុកថាជាផ្ទះ ពោលគឺ ផ្ទះពិតប្រាកដ ទ្បើងទាត់ ចំបង និងអចិន្ត្រៃយ៍របស់បុគ្គលម្នាក់ ដែលបុគ្គលនោះមានបំណងវិលត្រឡប់មកវិញ និងស្នាក់នៅ សូម្បីតែបច្ចុប្បន្នកំពុងរស់នៅកន្លែងផ្សេងណាមួយក៏ដោយ។ ក្រមរដ្ឋប្បវេណីបានកំណត់ថាលំនៅឋានគឺជាទីតាំងនៃជីវភាពរស់នៅរបស់បុគ្គលម្នាក់ៗ។ ចំពោះបុគ្គលដែលគ្មានលំនៅឋាន នៅក្នុងប្រទេសកម្ពុជាទេ ទីសំណាក់របស់បុគ្គលនោះនៅក្នុងប្រទេសកម្ពុជាត្រូវចាត់ទុកថាជាលំនៅឋាន។* |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Due process | នីតិវិធីត្រឹមត្រូវ | N/A | Equity | *ការអនុវត្តនីតិវិធីច្បាប់ស្របតាមបទបញ្ញា និងគោលការណ៍ដែលមានទទួលយកជាទូទៅ ដែលផ្តល់នូវកិច្ចការពារ និងពង្រឹងសិទ្ធិឯកជន ដែលរួមទាំងការជូនដំណឹង និងសិទ្ធិក្នុងការទទួលបានការកាត់ក្តីដោយយុត្តិធម៌នៅចំពោះមុខតុលាការ ឬ ស្ថាប័នរដ្ឋបាលដែលមានអំណាចសម្រេចលើករណីនោះ ។* |
| Duress | ការគម្រាមកំហែង<br>ការបង្ខិតបង្ខំ | N/A | Force, compulsion,<br>coercion , pressure | *ការគំរាមកំហែង ឬ ការប្រើកម្លាំង ដើម្បីធ្វើឱ្យជនណាម្នាក់ធ្វើអ្វីមួយ ។* |
| Dysfunctional | ដែលដំណើរការខុសប្រក្រតី | N/A | N/A | *មិនធ្វើតាមទម្រង់ធម្មតានៃឥរិយាបថសង្គម ជាពិសេសជាមួយលទ្ធផលដែលអ្នកខ្លះមិនអាចប្រកាន់អាកប្បកិរិយាតាមវិធីធម្មតា ឬ មិនមានការរស់នៅជាទីពេញចិត្ត ។* |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Economic migrant | ជនចំណាកស្រុកដោយសារមូលហេតុសេដ្ឋកិច្ច | N/A | N/A | បុគ្គលម្នាក់ដែលចាកចោលកន្លែងរស់នៅរបស់ខ្លួន ដើម្បីតាំងទីលំនៅក្រៅប្រទេសកំណើតរបស់ខ្លួនដើម្បីកែលម្អគុណភាពនៃការរស់នៅផ្ទាល់ខ្លួន ។ ពាក្យនេះអាចនឹងប្រើប្រាស់ ដើម្បីបង្ហាញភាពខុសគ្នាពីជនភៀសខ្លួនដែលគេចចេញពីការធ្វើទុក្ខបុកម្នេញ និងត្រូវបានប្រើប្រាស់ផងដែរ ដើម្បីសំដៅលើបុគ្គលនានាដែលប៉ុនប៉ងចូលក្នុងប្រទេសមួយដោយគ្មានការអនុញ្ញាតស្របច្បាប់ និង/ឬប្រើប្រាស់នីតិវិធីនៃការសុំសិទ្ធិជ្រកកោនដោយគ្មានមូលហេតុស្មោះត្រង់ ។ ពាក្យនេះក៏ពាក់ព័ន្ធផងដែរទៅនឹងបុគ្គលនានា ដែលតាំងលំនៅក្រៅប្រទេសដើមកំណើតរបស់ខ្លួននៅក្នុងអំឡុងពេលនៃរដូវកសិកម្ម ដែលច្រើនហៅថាកម្មករចំណាកស្រុកតាមរដូវកាល ។ |
| Emergency relief | ជំនួយសង្គ្រោះបន្ទាន់ | N/A | Emergency assistance | ជំនួយសង្គ្រោះជីវិតជាបន្ទាន់ដល់ជនរងគ្រោះពីវិបត្តិ និងជម្លោះដោយអំពើហិង្សា ។ ភាគច្រើន នៃជំនួយសង្គ្រោះត្រូវបានផ្តួចផ្តើមឡើងដោយការជូនដំណឹងក្នុងរយៈពេលខ្លី និងមានរយៈពេលខ្លីដើម្បីអនុវត្ត (ជាទូទៅ គម្រោងមានគោលបំណងបញ្ចប់ក្នុងរយៈពេលមួយឆ្នាំ) ។ គោលបំណងចម្បងនៃជំនួយសង្គ្រោះបន្ទាន់គឺការសង្គ្រោះជីវិត ។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Emigration | ទេសន្តរប្រវេសន៍<br>ការចាកចេញពីប្រទេស | Emigrate | N/A | អំពើនៃការចេញដំណើរ ឬចាកចេញពីរដ្ឋមួយក្នុងបំណងតាំងលំនៅក្នុងរដ្ឋមួយផ្សេងទៀត ។ និយាមអន្តរជាតិស្តីពីសិទ្ធិមនុស្សចែងថាបុគ្គលគ្រប់រូបគួរតែមានសេរីភាពចាកចេញពីប្រទេសណាមួយដែលរួមទាំងប្រទេសរបស់ខ្លួន និងមានតែនៅក្នុងកាលៈទេសៈតិចតួចបំផុតប៉ុណ្ណោះ ដែលរដ្ឋអាចដាក់កំហិតលើសិទ្ធិរបស់បុគ្គលនោះក្នុងការចាកចេញពីដែនដីនោះ ។ |
| Emotional abuse | ការរំលោភបំពានខាងស្មារតី ឬ ផ្លូវអារម្មណ៍ | N/A | N/A | ជាទម្រង់មួយនៃការបំពាន ដែលធ្វើឡើងដោយបុគ្គលម្នាក់ដែលធ្វើឱ្យឬបង្ហាញពីអាកប្បកិរិយាមួយផ្សេងទៀត ដែលមានគ្រោះថ្នាក់មកលើចិត្តសាស្ត្រ ។ វាទាក់ទងនឹងការបង្កការឈឺចាប់ដោយចេតនាមកលើស្មារតី ឬ ភាពតានតឹងខាងអារម្មណ៍ដោយការគំរាមកំហែង ការប្រមាថ ឬ ការប្រព្រឹត្តផ្សេងទៀតដោយពាក្យសំដី ឬមិនមែនដោយពាក្យសំដី ។ វាច្រើនតែពាក់ព័ន្ធជាមួយស្ថានភាពនៃអតុល្យភាពអំណាច ដូចជាស្ថានភាពនៃទំនាក់ទំនងនៃការបំពាន និងការរំលោភបំពានលើកុមារ ។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Empowerment | ការពង្រឹងភាពអង់អាច ការផ្ដល់អំណាច | Empower | N/A | ដំណើរឬបាតុភូតមួយដែលអនុញ្ញាតឱ្យមនុស្សចាប់យកអំណាចត្រួតត្រាលើការសម្រេចលើទ្រព្យសម្បត្តិ វិធានការ គោល-នយោបាយ ដំណើរការ និងស្ថាប័ននានាដែលមានឥទ្ធិពលលើជីវិតរបស់ពួកគេ។ |
| Enslavement | ការដាក់ឱ្យស្ថិតនៅក្នុងទាសភាព | Enslave | N/A | ការអនុវត្តអំណាចណាមួយឬទាំងអស់ដែលមានចំពោះសិទ្ធិកម្មសិទ្ធិទៅលើបុគ្គលណាម្នាក់។ (មាត្រា ៧ នៃលក្ខន្តិកៈក្រុងរ៉ូមស្ដីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ) |
| Entertainment service | សេវាកំសាន្តសប្បាយ | N/A | N/A | សេវានានាដែលធ្វើឱ្យអតិថិជនពេញចិត្តដោយផ្ដល់អាហារ ភេសជ្ជៈ របាំ ចម្រៀង ។ល។ |
| Enticement | ការលួងលោម | Entice | Lure, temptation | ជាស្ថានភាពមួយ ដែលជនល្មើសទាក់ទាញជនរងគ្រោះតាមរយៈការសន្យាក្លែងក្លាយ ឬ ការមិនផ្ដល់ព័ត៌មានឱ្យបានសព្វគ្រប់ជ្រុងជ្រោយក្នុងគោលដៅបញ្ចុះបញ្ចូលជនរងគ្រោះឱ្យធ្វើអ្វីមួយ។ |
| Entry | ការចូលទៅកាន់ប្រទេសណាមួយ | Enter | N/A | ការចូលដោយជនណាម្នាក់ទៅក្នុងទឹកដីបរទេស បើទោះជាដោយស្ម័គ្រចិត្ត ឬ មិនស្ម័គ្រចិត្ត ដោយស្របច្បាប់ ឬ មិនស្របច្បាប់ក៏ដោយ។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Entry stamp | ត្រាចូល | N/A | N/A | សញ្ញាសំគាល់ដែលធ្វើឡើងដោយមន្ត្រី ដែលធ្វើការតាមច្រកព្រំដែននៅលើលិខិតឆ្លងដែនរបស់បុគ្គលណាម្នាក់ ដែលបញ្ជាក់អំពីកាលបរិច្ឆេទ និងកន្លែងដែលបុគ្គលនោះចូលក្នុងរដ្ឋនោះ ។ |
| Evaluation | ការវាយតម្លៃ | Evaluate | Assessment | ការវិភាគ និងប៉ាន់ប្រមាណជាលក្ខណៈប្រព័ន្ធ និងផ្តោតលើគោលបំណងជាក់លាក់លើគោលនយោបាយ កម្មវិធី ការអនុវត្តភាពជាដៃគូ និងនីតិវិធីរបស់អង្គការ ដោយផ្តោតលើការកសាងផែនការ ការបង្កើត ការអនុវត្ត និងឥទ្ធិពលគម្រោង ។ ការវាយតម្លៃគម្រោងស្តីពីការងារអភិវឌ្ឍឬជំនួយគាំទ្រណាមួយត្រូវធ្វើឡើងដោយផ្អែកលើចំណុចដៅសំខាន់ៗចំនួនប្រាំគឺ ភាពជាប់ទាក់ទងឬសង្គតិភាព, ប្រសិទ្ធភាព, ប្រសិទ្ធផល, និរន្តរភាព និងផលរយៈពេលវែងដែលគម្រោងណាមួយមាន ។ |
| Evidence | ភ័ស្តុតាង | N/A | N/A | រួមបញ្ចូលអ្វីៗទាំងអស់ដែលត្រូវប្រើប្រាស់សម្រាប់កំណត់ ឬបង្ហាញភាពពិតនៃអំណះអំណាងមួយ ដែលមានដូចជាវត្ថុតាង និងសក្ខីកម្មរបស់សាក្សីជាដើម ។ |
| Excessive | លើសលុប ឬ ហួសហេតុ | N/A | Overwhelming | ដែលមានលក្ខណៈច្រើហួសហេតុ ឬ ជ្រុលហួស មិនអាចទ្រាំទ្រ ឬ ទទួលយកបាន ។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Exclusion | ការបដិសេធមិនឱ្យចូលក្នុងប្រទេស | Exclude | Dismissal, eviction, exception, interdict, non-admission, prohibition, refusal, rejection, removal. | ការបដិសេធជាផ្លូវការមិនឱ្យជនបរទេសចូលទៅក្នុងរដ្ឋមួយ ។ នៅក្នុងរដ្ឋខ្លះ មន្ត្រីច្រកព្រំដែន ឬ អាជ្ញាធរដទៃទៀតមានអំណាចបដិសេធជនបរទេស ។ នៅក្នុងរដ្ឋផ្សេងទៀត ការបដិសេធត្រូវបានបញ្ជាដោយចៅក្រមអន្តោប្រវេសន៍នៅក្រោយពេលមានសវនាការ ។ |
| Excursionist | អ្នកធ្វើដំណើរកំសាន្ត | N/A | Same day visitor | បុគ្គលនានាដែលមិនរស់នៅក្នុងប្រទេសដែលខ្លួនមកដល់ និងស្នាក់នៅត្រឹមតែមួយថ្ងៃដោយ មិនចំណាយពេលយប់នៅក្នុងកន្លែងស្នាក់នៅរួម ឬ ឯកជននៅក្នុងប្រទេសដែលខ្លួនធ្វើទស្សនកិច្ចនោះទេ ។ អ្នកដំណើរជំពូកនេះ រាប់បញ្ចូលអ្នកដំណើរតាមនាវាកំសាន្ត ដែលមកដល់ក្នុងប្រទេសមួយ តាមនាវាទេសចរណ៍ និងវិលត្រឡប់ទៅកាន់នាវានោះវិញរៀងរាល់យប់ដើម្បីស្នាក់នៅក្នុងនាវា ក៏ដូចជាបុគ្គលិកនាវា ដែលមិនចំណាយពេលយប់នៅក្នុងប្រទេសនោះទេ ។ អ្នកដំណើរជំពូកនេះក៏រាប់បញ្ចូលផងដែរនូវអ្នករស់នៅតាមព្រំដែន ដែលចូលទៅក្នុងប្រទេសជិតខាងនៅពេលថ្ងៃដើម្បីទិញទំនិញ ទៅលេងមិត្តភក្តិ ឬសាច់ញាតិ ស្វែងរកការព្យាបាលជំងឺ ឬ ចូលរួមនៅក្នុងសកម្មភាពលំហែកាយ ។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Exile | ធ្វើនិរទេសចេញពីស្រុកកំណើត | Exile | Banish, expel, deport, send away | ការបញ្ជូនជនណាម្នាក់ចេញពីប្រទេសកំណើត ។ ខុសគ្នាពីជនដែលត្រូវបានបង្ខំឱ្យចេញពីប្រទេសមួយដែលគាត់មិនមែនជាពលរដ្ឋនៃប្រទេសនោះ ជននិរទេសគឺជាបុគ្គលដែលត្រូវបានបង្ខំឱ្យចេញពីប្រទេសកំណើត ។ នៅពេលដែលច្បាប់ ឬការកៀបសង្កត់ មនុស្សម្នាក់ឱ្យចាកចេញ គាត់ស្ថិតក្នុងការធ្វើនិរទេសដោយបង្ខំ ។ នៅក្នុងករណីដែលកាលៈទេសៈបង្កឱ្យបុគ្គលម្នាក់ចាកចេញដោយខ្លួនឯង គាត់ស្ថិតក្នុងការធ្វើនិរទេសដោយស្ម័គ្រចិត្ត ។ |
| Exit visa | ទិដ្ឋាការឬត្រាចេញពីប្រទេស | N/A | N/A | ទិដ្ឋាការដែលចេញឱ្យបុគ្គលនានា និងដែលមានកាលកំណត់ដែលត្រូវបន្តពេលមុននឹងចេញពីប្រទេសនោះ ។ |
| Exodus | ចលនាចាកចេញពីប្រទេសជាក្រុម | N/A | N/A | ការផ្លាស់ទីជាក្រុម (ដាច់ដោយឡែកនិងមិនទាក់ទងគ្នា) ចេញពីប្រទេសកំណើត ។ ការចាកចេញជាក្រុម គឺជាចលនានៃមនុស្សជាច្រើននៅក្នុងសហគមន៍មួយនៅក្នុងពេលណាមួយ ។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Exploitation | ការកេងប្រវ័ញ្ច | Exploit | N/A | *អំពើនៃការទាញយកផលពីអ្វីម៉្យាង ឬ ពីជនណាម្នាក់ ជាពិសេសអំពើនៃការកេងយកផល ដោយមិនត្រឹមត្រូវពីអ្នកដទៃសម្រាប់ជាប្រយោជន៍ផ្ទាល់ខ្លួន (ដូចជា ការកេងប្រវ័ញ្ចខាងផ្លូវភេទ ពលកម្ម ឬ សេវាកម្មដោយបង្ខំ ទាសភាព ឬ ការអនុវត្តស្រដៀងគ្នានឹងទាសភាព សេវភាព ឬ ការដកហូតសរីរាង្គនានា) ។* |
| Expulsion | ការបណ្តេញចេញពីប្រទេស | Expel | Banishment, deportment, dispossession, eviction, expatriation, removal | *អំពើរបស់អាជ្ញាធរនៃរដ្ឋមួយក្នុងបំណង និងក្នុងន័យធ្វើឱ្យមានការបណ្តេញចេញបុគ្គលម្នាក់ ឬ ច្រើន (ជនបរទេស ឬ បុគ្គលគ្មានសញ្ជាតិ) ផុយពីឆន្ទៈរបស់ពួកគេ ពីដែនដីរបស់រដ្ឋនោះ ។* |
| Expulsion order | សេចក្តីសម្រេចបណ្តេញចេញ | N/A | N/A | *បទបញ្ជារបស់រដ្ឋមួយ ដែលជូនដំណឹងអំពីការហាមឃាត់ជនបរទេសមិនឱ្យបន្តស្ថិតនៅក្នុងដែនដីនៃរដ្ឋនោះ ។ បទបញ្ជានេះនឹងត្រូវចេញ ទោះបីបុគ្គលនោះចូលមកក្នុងដែនដីនោះដោយល្មើសច្បាប់ ឬ លែងមានទទួលសិទ្ធិបន្តស្នាក់នៅក្នុងរដ្ឋនោះ ។ ជាទូទៅ បទបញ្ជានេះរួមផ្សំជាមួយការប្រកាសផ្សាយដែលនឹងត្រូវអនុវត្តតាមរយៈការនិរទេសប្រសិនបើចាំបាច់ ។* |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Extended family | គ្រួសារសាច់ញាតិ | N/A | N/A | ញាតិសន្តានរបស់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដែលមិនមែនជាឪពុកម្តាយនិងកូនបង្កើត ដែលអាចត្រូវបានស្នើសុំឱ្យមើលថែជនរងគ្រោះនៅក្នុងសហគមន៍ ។ |
| Externally displaced person | ជនភៀសខ្លួនដោយសារកត្តាសង្គម-ធម្មជាតិ | N/A | N/A | បុគ្គលនានាដែលបានគេចចេញពីប្រទេសខ្លួន ដោយសារតែការធ្វើទុក្ខបុកម្នេញ អំពើហិង្សាជាទូទៅ ស្ថានភាពជម្លោះប្រដាប់អាវុធ ឬ គ្រោះមហន្តរាយផ្សេងទៀត ដែលបង្កដោយមនុស្ស ។ ជាញឹកញាប់បុគ្គលទាំងនោះ គេចចេញក្នុងចំនួនយ៉ាងច្រើន ។ ជួនកាល ពួកគេក៏ត្រូវបានហៅផងដែរថាជា "ជនភៀសខ្លួនជាក់ស្តែង" ។ |
| Extradition | បត្យាប័ន | Extradite | Deportation, expatriation | ជាទូទៅ ការប្រគល់ជាផ្លូវការដោយផ្អែកលើសន្ធិសញ្ញា ឬ ការចាត់ចែងទៅវិញទៅមក ពីសំណាក់រដ្ឋមួយមកលើរដ្ឋមួយផ្សេងទៀត អំពីបុគ្គលម្នាក់ដែលត្រូវបានចោទប្រកាន់ ឬ ជាប់ចោទពីបទល្មើសនៅក្រៅដែនដីរបស់ខ្លួន និងនៅក្នុងដែនសមត្ថកិច្ចរបស់រដ្ឋផ្សេងទៀត ក្នុងបំណងយកមកជំនុំជម្រះ ឬ ទទួលទោសលើទឹកដីកំណើតរបស់ខ្លួន ។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Facilitate | ជួយសម្រួល | Facilitate | Ease, assist | ធ្វើឱ្យដំណើរការមួយងាយស្រួលក្នុងការកើតមានឡើង ។ |
| Family unity | សិទ្ធិរស់នៅជួបជុំគ្រួសារ | N/A | N/A | សិទ្ធិរបស់គ្រួសារមួយក្នុងការរស់នៅជាមួយគ្នា និងជាឯកត្តាតូចបំផុតមួយនៃសង្គម ដើម្បីទទួលបាននូវការគោរព កិច្ចការពារ ជំនួយ និងការគាំទ្រ ។ |
| Force | ការប្រើប្រាស់កម្លាំង | Force | Restraint, pressure | សំដៅលើការប្រើកម្លាំងផ្លូវកាយ ឬផ្លូវចិត្តដើម្បីប្រឆាំងនឹងឆន្ទៈរបស់ជនរងគ្រោះ ។ ជាគោលការណ៍វាមិនចាំបាច់តម្រូវថាជនរងគ្រោះត្រូវទទួលរងរបួសដោយសារតែការប្រើប្រាស់កម្លាំងនេះឡើយ ។ |
| Forced labor | ពលកម្មដោយបង្ខំ | N/A | N/A | គ្រប់ការងារ ឬ សេវាដែលតម្រូវឱ្យបុគ្គលណាម្នាក់ធ្វើនៅក្រោមការគំរាមដាក់ទណ្ឌកម្ម ហើយដែលបុគ្គលនោះមិនបានផ្តល់ឱ្យដោយស្ម័គ្រចិត្តឡើយ ។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Forced marriage | អាពាហ៍ពិពាហ៍ដោយបង្ខំ | N/A | N/A | ជាពាក្យប្រើប្រាស់ដើម្បីអធិប្បាយអំពីអាពាហ៍ពិពាហ៍មួយដែលភាគីមួយឬច្រើនរៀបការ ដោយគ្មានការឯកភាពគ្នា ឬដែលផ្ទុយនឹងឆន្ទៈរបស់ពួកគេ។ អាពាហ៍ពិពាហ៍ដោយបង្ខំខុសគ្នា ពីអាពាហ៍ពិពាហ៍ដោយការចាត់ចែង ដែលក្នុងនោះភាគីទាំងពីរឯកភាពគ្នាជាមួយជំនួយពីឪពុកម្តាយរបស់ពួកគេ ឬពីភាគីទីបីណាមួយ (ដូចជា មេអណ្តើក) ក្នុងការស្វែងរកសហព័ទ្ធ។ |
| Forced migration | ទេសន្តរប្រវេសន៍ដោយបង្ខំ | N/A | N/A | ជាពាក្យទូទៅមួយសម្រាប់អធិប្បាយអំពីចលនាទេសន្តរប្រវេសន៍ដែលក្នុងនោះមានការបង្ខិតបង្ខំដែលរួមទាំងការគំរាមកំហែងដល់អាយុជីវិតនិងរបរចិញ្ចឹមជីវិត ទោះជាកើតឡើងដោយកត្តាធម្មជាតិ ឬដោយមនុស្សក៏ដោយ (ដូចជា ចលនានៃជនភៀសខ្លួន និងជនចំណាកស្រុក ដោយសារគ្រោះធម្មជាតិ និង បរិស្ថាន គ្រោះមហន្តរាយដោយសារធាតុគីមី ឬនុយក្លេអ៊ែរ ទុរ្ភិក្ស ឬគម្រោងអភិវឌ្ឍន៍ផ្សេងៗ)។ |
| Forced prostitution | អំពើពេស្យាចារដោយបង្ខំ | N/A | N/A | ការរួមភេទជាមួយជនណាម្នាក់ដែលមិនកំណត់ ឬ អំពើគ្រប់រូបភាពផ្សេងទៀតដែលទាក់ទងនឹងភេទ ដោយផ្តោះប្តូរនឹងវត្ថុមានតម្លៃអ្វីមួយ និងដោយមិនមានការស្ម័គ្រចិត្ត។ ជាទូទៅ "ពេស្យាចារដោយបង្ខំ" ស្តែងឡើងក្នុងរូបភាពជាការត្រួតត្រាលើបុគ្គលម្នាក់ដែលស្ថិតក្រោមការបង្ខិតបង្ខំឱ្យប្រព្រឹត្តសកម្មភាពខាងផ្លូវភេទ។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Forced resettlement | ការតាំងទីលំនៅដោយបង្ខំ | N/A | N/A | *ការផ្ទេរបុគ្គល ឬក្រុមនានាដោយបង្ខំ នៅក្នុងដែនសមត្ថកិច្ចរបស់រដ្ឋមួយ ចេញពីកន្លែងស្នាក់នៅជាធម្មតារបស់ពួកគេ ដែលជាផ្នែកមួយនៃគោលនយោបាយរបស់រដ្ឋាភិបាល ដើម្បីឱ្យទៅតាំងទីលំនៅថ្មីនៅកន្លែងផ្សេង ។* |
| Forced return | ការបញ្ជូនត្រឡប់ ឬនិរទេសដោយបង្ខំ | N/A | Forced repatriation | *ភាពចាំបាច់ត្រូវវិលត្រឡប់នៃបុគ្គលណាម្នាក់ទៅប្រទេសដើមកន្លែងសំចត ឬ ប្រទេសទីបីវិញ ដោយសារតែចំណាត់ការខាងរដ្ឋបាល ឬ អំណាចតុលាការ ។* |
| Forcibly assisted | ដែលផ្តល់ជំនួយក្នុងលក្ខណៈបង្ខំ | N/A | N/A | *ដែលប្រើកម្លាំងដើម្បីឱ្យបុគ្គលណាម្នាក់ទទួលជំនួយ ។* |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
| --- | --- | --- | --- | --- |
| Fraud | ការបន្លំ<br>ការឆបោក | Defraud | Fraudulence, deception, cheating, trickery | អំពើបន្លំចំពោះបុគ្គលណាម្នាក់ ហើយដែលនាំឱ្យខូចខាតប្រយោជន៍របស់បុគ្គលនេះ ឬ របស់តតិយជន តាមរយៈការប្រើប្រាស់ឈ្មោះក្លែង ឬ ការអះអាងទៅលើឋានៈក្លែង ឬ ការរំលោភលើឋានៈពិតប្រាកដ ឬ ការប្រើឧបាយកលទុច្ចរិត ដើម្បីទទួលបានពីជនរងគ្រោះនូវ :<br>១) ការប្រគល់មូលនិធិ តម្លៃ ឬ ទ្រព្យសម្បត្តិអ្វីមួយ ។<br>២) ការផ្តត់ផ្គង់សេវា ។<br>៣) ការធ្វើលិខិតដែលមានតម្លៃជាកាតព្វកិច្ច ឬ ជាការឱ្យរួចពីកាតព្វកិច្ច ។ |
| Fraudulent | ដែលមានលក្ខណៈបន្លំ ឬ ឆបោក | N/A | N/A | សូមមើលនិយមន័យនៃពាក្យ "ការបន្លំ ឬ ឆបោក (Fraud)"។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Fraudulent document | ឯកសារក្លែងបន្លំ | N/A | N/A | ឯកសារធ្វើដំណើរ ឬ ឯកសារអត្តសញ្ញាណដែលក្លែងបន្លំ ឬ កែប្រែផ្នែកខ្លះដោយជនណាផ្សេងទៀត ក្រៅពីបុគ្គលដើម ឬ ភ្នាក់ងារដែលមានសិទ្ធិស្របច្បាប់ក្នុងការចេញ ឬ ផលិតឯកសារធ្វើដំណើរ ឬឯកសារអត្តសញ្ញាណនោះ ក្នុងនាមរដ្ឋ ឬ ដែលត្រូវបានចេញដោយមិនត្រឹមត្រូវ ឬ ទទួលបានតាមរយៈតំណាងមិនត្រឹមត្រូវដោយអំពើពុករលួយ ឬ ការបង្ខាប់បញ្ជា ឬ តាមវិធីផ្សេងណាមួយ ដែលមិនស្របច្បាប់ ឬ ដែលត្រូវបុគ្គលផ្សេងក្រៅពីបុគ្គលស្របច្បាប់ពីខាងដើមយកទៅប្រើប្រាស់។ |
| Freedom of movement | សេរីភាពបន្លាស់ទី | N/A | N/A | សិទ្ធិនេះផ្សំឡើងដោយផ្នែកសំខាន់ៗចំនួនបី ៖ សេរីភាពនៃការធ្វើដំណើរនៅក្នុងដែនដីនៃប្រទេសមួយ (មាត្រា ១៣(១) សេចក្តីថ្លែងការណ៍ជាសកលអំពីសិទ្ធិមនុស្ស ឆ្នាំ ១៩៤៨៖ "មនុស្សគ្រប់រូបមានសិទ្ធិក្នុងការធ្វើដំណើរដោយសេរីនិងស្នាក់នៅក្នុងព្រំដែននៃរដ្ឋនីមួយៗ") សិទ្ធិក្នុងការចាកចេញពីប្រទេសណាមួយ និងសិទ្ធិវិលត្រឡប់មកប្រទេសរបស់ខ្លួនវិញ (មាត្រា ១៣ (២) សេចក្តីថ្លែងការណ៍ជាសកលអំពីសិទ្ធិមនុស្ស ឆ្នាំ ១៩៤៨ "ជនគ្រប់រូបមានសិទ្ធិចាកចេញពីប្រទេសណាមួយ ដែលរួមទាំងប្រទេសផ្ទាល់ខ្លួន និងវិលត្រឡប់មកប្រទេសខ្លួនវិញ") |
| Freezing | ការបង្កក | Freeze | Seizure | សំដៅលើការការហាមឃាត់ជាបណ្តោះអាសន្នលើការផ្ទេរ ការផ្លាស់ប្តូរ ការចាត់ចែង ឬការធ្វើចលនាទ្រព្យសម្បត្តិនានា។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Gender-related persecution | ការធ្វើទុក្ខបុកម្នេញដោយមូលហេតុពាក់ព័ន្ធនឹងយេនឌ័រ | N/A | N/A | *ការធ្វើទុក្ខទោស ការចោទប្រកាន់ ឬការយាយីដែលផ្តោតលើ ឬមានឥទ្ធិពលក្នុងកម្រិតវិសមាមាត្រមកលើភេទណាមួយ ។* |
| Genuine and stable marriage | អាពាហ៍ពិពាហ៍ពិតប្រាកដ និងយូរអង្វែង | N/A | N/A | *អាពាហ៍ពិពាហ៍មួយដែលមន្ត្រីកុងស៊ុល ឬ មន្ត្រីអន្តោប្រវេសន៍ចាត់ទុកថាពិតឥតក្លែងក្លាយ ដោយសារបានធ្វើឡើងក្នុងបំណងរក្សាចំណងអាពាហ៍ពិពាហ៍ពិតប្រាកដ និងយូរអង្វែងដោយសារវាទំនងជានឹងស្ថិតស្ថេរ ។ នៅក្នុងរដ្ឋជាច្រើន ប្រសិនបើមន្ត្រីមិនអាចកំណត់ថាតើអាពាហ៍ពិពាហ៍នោះធ្វើឡើងក្នុងបំណងរក្សាចំណងអាពាហ៍ពិពាហ៍សម្រាប់រយៈពេលយូរអង្វែងទេនោះ គេអាចធ្វើការសន្និតថាជាអាពាហ៍ពិពាហ៍ពិតឥតក្លែងក្លាយ លើកលែងតែមានភស្តុតាងដែលបញ្ជាក់ផ្ទុយពីនេះ ។* |
| Good practice | បទពិសោធល្អ | N/A | N/A | *បទពិសោធបែបថ្មី ដែលគួរឱ្យចាប់អារម្មណ៍ និងដែលញ៉ាំងអារម្មណ៍ ហើយល្អដែលមានសក្តានុពលក្នុងការផ្ទេរទាំងស្រុង ឬ មួយផ្នែកទៅក្នុងបរិបទដទៃទៀតរបស់ជាតិ ។* |
| Green border | បន្ទាត់ព្រំដែនគោក ឬ ព្រំដែនបៃតង | N/A | N/A | *ពាក្យនេះ ប្រើប្រាស់ដើម្បីអធិប្បាយអំពីព្រំដែនដីគោករបស់រដ្ឋមួយរវាងច្រកត្រួតពិនិត្យតាមព្រំដែន ។ ព្រំដែនទឹក (ទន្លេ ឬសមុទ្រ) អាចហៅថាជា "ព្រំដែនខៀវ" ។* |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Grounds of inadmissibility | លក្ខខណ្ឌឬមូលហេតុក្នុងការមិនអនុញ្ញាតចូលក្នុងប្រទេស | N/A | N/A | *និយមន័យ ដែលមានចែងនៅក្នុងច្បាប់ និងបទប្បញ្ញត្តិអន្តោប្រវេសន៍ អំពីហេតុផលដែលជនបរទេសអាចត្រូវហាមឃាត់មិនឱ្យចូលក្នុងរដ្ឋណាមួយ ។ សូម្បីតែក្នុងករណី ដែលបុគ្គលនោះ មានគុណវុឌ្ឍិគ្រប់គ្រាន់សម្រាប់ទទួលបានទិដ្ឋាការ ឬ ឋានៈដទៃទៀតខាងអន្តោប្រវេសន៍ក៏ដោយ ប្រសិនបើគាត់ស្ថិតនៅក្នុងលក្ខខណ្ឌនៃការមិនអាចអនុញ្ញាតឱ្យចូលបានទិដ្ឋាការ ឬ ឋានៈដទៃទៀតនឹងត្រូវបដិសេធ ។ លក្ខខណ្ឌនៃការមិនអនុញ្ញាតឱ្យចូលត្រូវបានកំណត់ឡើង ដោយឡែកសម្រាប់ហាមជនបរទេសមួយចំនួនចូល ដូចជាបុគ្គលដែលគ្មានឯកសារ ដែលមិនមានឯកសារសុពលភាពសម្រាប់ការធ្វើដំណើរ បុគ្គលដែលជាប់ការចោទប្រកាន់ពីបទព្រហ្មទណ្ឌ បុគ្គលដែលគេជឿថាអាចបង្កគ្រោះថ្នាក់ដល់សុខភាពសាធារណៈ ឬ សុវត្ថិភាពសាធារណៈ បុគ្គលដែលធ្លាប់ត្រូវបាននិរទេសពីមុនមក ។ល ។* |
| Guiding principles on internal displacement | គោលការណ៍ណែនាំស្តីពីបន្លាស់ទីនៅក្នុងប្រទេស | N/A | N/A | *គោលការណ៍មួយឈុត ដែលចែងអំពីបទដ្ឋានការពារជំនួយ និងដំណោះស្រាយសម្រាប់បន្លាស់ទីនៅក្នុងប្រទេសមួយ ។ គោលការណ៍ណែនាំត្រូវបានដាក់ជូនទៅស្នងការទទួលបន្ទុកសិទ្ធិមនុស្ស ដោយតំណាងនៃអគ្គលេខាធិការសម្រាប់បន្លាស់ទីក្នុងប្រទេសនៅក្នុងខែមេសា ឆ្នាំ ១៩៩៨ ។* |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Guardian | អ្នកអាណាព្យាបាល | N/A | Care taker, custodian | *ជនដែលមានសមត្ថកិច្ច និងករណីយកិច្ចស្របច្បាប់ ក្នុងការថែទាំបុគ្គល ឬទ្រព្យសម្បត្តិផ្សេងទៀត ដែលតាមធម្មតាដោយសារកង្វះសមត្ថភាព ពិការភាព ឬ ស្ថានភាពអនីតិជនរបស់ជននេះ ។* |
| Guilty | ដែលមានពិរុទ្ធ<br>ដែលជាប់ពិរុទ្ធ | N/A | Culpable | *ដែលបានប្រព្រឹត្តអំពើដែលត្រូវចាត់ថ្នាក់ជាបទល្មើសព្រហ្មទណ្ឌ ។* |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Habeas corpus | ដីកាបង្គាប់ឱ្យនាំខ្លួនមកកាន់តុលាការដើម្បីត្រួតពិនិត្យពីភាពស្របច្បាប់នៃការឃុំខ្លួន<br>បណ្តឹងសុំឱ្យមានការត្រួតពិនិត្យលើភាពស្របច្បាប់នៃការឃុំខ្លួន | N/A | N/A | *ដីការកោះអញ្ជើញបុគ្គលម្នាក់មកបង្ហាញខ្លួននៅចំពោះមុខតុលាការ ដែលជាញឹកញាប់ដើម្បីធានាថា ការដាក់ពន្ធនាគារលើភាគីនោះមិនមែនជាករណីល្មើសច្បាប់ឡើយ ។ ចំណាត់ការមួយនៅចំពោះមុខតុលាការដើម្បីពិនិត្យមើលភាពស្របច្បាប់នៃការឃុំឃាំង ឬ ការដាក់ក្នុងពន្ធនាគារ ។* |
| Habitual/usual residence | លំនៅរស់នៅជាប្រក្រតី | N/A | N/A | *កន្លែងមួយនៅក្នុងប្រទេស ដែលបុគ្គលម្នាក់រស់នៅ និងដែលតាមធម្មតារូបគាត់ចំណាយពេលសម្រាកកាយប្រចាំថ្ងៃ ។* |
| Harbor | ផ្តល់ទីជម្រក (ដោយខុសច្បាប់) | N/A | N/A | *ការផ្តល់ជម្រក ឬ លាក់បុគ្គលណាម្នាក់ក្នុងបំណងល្មើសទៅនឹងច្បាប់ ដូចជា ការពារឧក្រិដ្ឋជនពីការស្វែងរកចាប់ខ្លួនពីនគរបាលជាដើម ។* |
| Hearing | សវនាការ | N/A | Trial | *ពេលវេលាដែលរឿងក្តីមួយត្រូវបានយកមកជំនុំជម្រះនៅចំពោះតុលាការឬជាពេលសម្រាប់បង្ហាញអំណះអំណាងរបស់ភាគីនៃរឿងក្តីណាមួយនៅចំពោះមុខតុលាការ ។* |
| Heterosexuality | ការមានទំនាក់ទំនង ឬ អារម្មណ៍ផ្លូវភេទជាមួយមនុស្សដែលមានភេទផ្ទុយគ្នា | N/A | N/A | *សំដៅលើឥរិយាបថខាងផ្លូវភេទ ឬ ការទាក់ទាញមនុស្ស ដែលមានភេទខុសគ្នា ឬ ការប្រតិព័ទ្ធចំពោះមនុស្សដែលមានភេទខុសគ្នា ។* |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Holding centre | មណ្ឌលសំចតបណ្ដោះអាសន្ន | N/A | N/A | កន្លែងសំចតសម្រាប់អ្នកស្វែងរកការជ្រកកោន ឬជនចំណាកស្រុកនៅក្នុងស្ថានភាពមិនស្របច្បាប់នៅពេលដែលពួកគេ មកដល់ក្នុងប្រទេសដែលជាកន្លែងទទួលភ្លាម ។ ស្ថានភាពរបស់ពួកគេត្រូវកំណត់នៅមុនពួកគេត្រូវបានបញ្ជូនទៅជំរំជនភៀសខ្លួន ឬ ត្រឡប់ទៅប្រទេសដើមវិញ ។ |
| Holistic | ដែលមានលក្ខណៈរួមចម្រុះ ឬ សព្វមុខ | N/A | N/A | ការចាត់ទុកបុគ្គលម្នាក់ ឬ វត្ថុទាំងមូល ជាងការពិចារណាលើផ្នែកផ្សេងៗដោយឡែកពីគ្នា ។ |
| Homelessness | ភាពគ្មានផ្ទះសំបែង | N/A | N/A | ជាលក្ខខណ្ឌនិងជំពូកមនុស្សនៅក្នុងសង្គមមួយ ដែលខ្វះផ្ទះសំបែងដោយសារតែពួកគេមិនមានលទ្ធភាពទិញ ឬ ដោយសារពួកគេមិនអាចរក្សាជម្រកឱ្យមានជាធម្មតាប្រកបដោយសុវត្ថិភាព និងបានគ្រប់គ្រាន់ ។ |
| Homosexuality | ការមានទំនាក់ទំនង ឬ អារម្មណ៍ផ្លូវភេទជាមួយមនុស្សដែលមានភេទដូចគ្នា | N/A | N/A | សំដៅលើអាកប្បកិរិយាខាងផ្លូវភេទ ឬ ភាពទាក់ទាញរវាងមនុស្សមានភេទដូចគ្នា ឬ ការផ្តោតលើភេទតែមួយ ។ |
| Household | គ្រួសារ | N/A | N/A | ក្រុមមនុស្សដែលមានកន្លែងស្នាក់នៅរួមគ្នា ។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Human capital | ជំនាញ និងសមត្ថភាពរបស់មនុស្ស<br>ដើមទុនជាមនុស្ស | N/A | N/A | ជំនាញ និងទេពកោសល្យរបស់មនុស្សម្នាក់ ។ |
| Human development index | សន្ទស្សន៍នៃការអភិវឌ្ឍមនុស្ស | N/A | N/A | រង្វាស់នៃការរីកចម្រើនរបស់ប្រទេស ឬ តំបន់មួយ ដោយគិតតាមអាយុកាល កម្រិតនៃការអប់រំ និងកម្រិតប្រាក់ចំណូលពិតប្រាកដដែលបានកែតម្រូវ ។ |
| Human rights | សិទ្ធិមនុស្ស | N/A | N/A | សិទ្ធិដែលមានលក្ខណៈជាសកល មិនអាចផ្តាច់ចេញបានពឹងផ្អែកលើគ្នាទៅវិញទៅមក មានការទាក់ទងគ្នាទៅវិញទៅមក និងពាក់ព័ន្ធជាមួយបុគ្គលគ្រប់រូប ដែលបានទទួលការយកចិត្តទុកដាក់បានត្រឹមត្រូវ និងសមភាព ដោយផ្អែកលើមូលដ្ឋាន និងការយកចិត្តទុកដាក់ដូចគ្នា ។ |
| Human smuggling | ការរត់ពន្ធមនុស្ស | N/A | N/A | ការជួយជនណាម្នាក់ឱ្យឆ្លងដែនដោយខុសច្បាប់ជាញឹកញាប់ដោយគ្មានការបញ្ជាក់អត្តសញ្ញាណ ឬ ឯកសារនានា ក្នុងបំណងទទួលផលប្រយោជន៍ខាងហិរញ្ញវត្ថុ ឬ សម្ភារ ។ ការរត់ពន្ធបញ្ចប់ត្រឹមពេលដែលជនចំណាកស្រុកបានមកដល់ទីដៅ ។ ចំណែកការជួញដូរ ទាក់ទងនឹងការកេងប្រវ័ញ្ចជាប់ជាបន្តមកលើជនរងគ្រោះក្រោមរូបភាពមួយចំនួន ដើម្បីបង្កើតផលប្រយោជន៍មិនស្របច្បាប់សម្រាប់អ្នកជួញដូរ ។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Human trafficking | ការជួញដូរមនុស្ស | N/A | N/A | អ.ស.បឱ្យនិយមន័យការជួញដូរមនុស្សថាជា "ការជ្រើសរើស ការដឹកជញ្ជូន ការផ្ទេរ ការផ្តល់ជម្រក ឬការទទួលបុគ្គលនានា តាមមធ្យោបាយនៃការគំរាមកំហែង ឬប្រើប្រាស់កម្លាំង ឬទម្រង់ដទៃទៀតនៃការបង្ខិតបង្ខំ ការចាប់ពង្រត់ ការឆបោក ការបោកបញ្ឆោត ការបំពានដោយអំណាច ឬលើភាពងាយរងគ្រោះ ឬការផ្តល់ ឬទទួលកម្រៃ ឬផលប្រយោជន៍ដើម្បីទទួលបាននូវការយល់ព្រមពីបុគ្គលណាម្នាក់ ដែលមានអំណាចគ្រប់គ្រងលើជនម្នាក់ផ្សេងទៀតក្នុងបំណងដើម្បីកេងប្រវ័ញ្ច។ "ការកេងប្រវ័ញ្ចនេះអាចកើតឡើងតាមទម្រង់ខុសៗគ្នា ដែលរួមទាំងអំពើពេស្យាចារ ឬទម្រង់ដទៃទៀតនៃការកេងប្រវ័ញ្ចខាងផ្លូវភេទ ពលកម្ម ឬសេវាកម្មដោយបង្ខំ ទាសភាព ឬ ការអនុវត្តស្រដៀងគ្នា នឹងទាសភាព ការដកហូតសរីរាង្គជាដើម។ |
| Humanitarian coordination | ការសម្របសម្រួលផ្នែកមនុស្សធម៌ | N/A | N/A | អភិក្រមមួយដែលផ្អែកលើជំនឿថា វិធានការដែលស៊ីសង្វាក់គ្នាតបទៅនឹងភាពបន្ទាន់ណាមួយនឹងបង្កើនអត្ថប្រយោជន៍ ព្រមទាំងកាត់បន្ថយភាពខ្វះចន្លោះដែលអាចកើតមាន។ |
| Humanitarian law | ច្បាប់មនុស្សធម៌ | N/A | N/A | បទបញ្ញានៅក្នុងច្បាប់អន្តរជាតិ ជាពិសេស ដែលបង្កើតឡើងសម្រាប់ការពារបុគ្គលនៅក្នុងពេលមានសង្គ្រាម ឬ ជម្លោះប្រដាប់អាវុធ។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Identify | កំណត់អត្តសញ្ញាណ | N/A | Determine | *បង្ហាញ និងបញ្ជាក់លក្ខណៈ ឬសញ្ញាណាមួយ ដោយផ្អែកលើលក្ខណវិនិច្ឆ័យផ្សេងៗ ។* |
| Identity document | ឯកសារបញ្ជាក់អត្តសញ្ញាណបុគ្គល | N/A | N/A | *សន្លឹកមួយនៃឯកសារដែលបង្កើតឡើង ដើម្បីបញ្ជាក់អត្តសញ្ញាណរបស់បុគ្គលដែលកាន់ឯកសារនោះ ។* |
| Illegal entry | ការចូលទៅក្នុងប្រទេសមួយដោយខុសច្បាប់ | N/A | N/A | *អំពើនៃការឆ្លងដែនដោយមិនគោរពតាមលក្ខខណ្ឌចាំបាច់នៃការចូលទៅក្នុងរដ្ឋមួយដោយស្របច្បាប់ ។* |
| Illegal immigrant | ជនអន្តោប្រវេសន៍ខុសច្បាប់ | N/A | N/A | *(ដែលហៅថាកម្មករគ្មានឯកសារផងដែរនោះ) សំដៅលើបុគ្គលដែលបានធ្វើអន្តោប្រវេសន៍ឆ្លងដែនតាមវិធីដែលរំលោភលើច្បាប់អន្តោប្រវេសន៍របស់ប្រទេសគោលដៅ ។* |
| Immigrant | ជនអន្តោប្រវេសន៍ | N/A | Adoptive citizen, alien, documented alien, migrant, undocumented alien | *ជាបុគ្គលដែលចូលទៅក្នុងប្រទេសមួយផ្សេងទៀត ។* |
| Immigration status | ឋានៈ ឬលក្ខខណ្ឌទាក់ទងនឹងជនអន្តោប្រវេសន៍ | N/A | N/A | *ស្ថានភាពដែលជនអន្តោប្រវេសន៍បានគោរពតាមច្បាប់អន្តោប្រវេសន៍នៃប្រទេសជាម្ចាស់ផ្ទះ* |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Immigration zone | ព្រំដែន(ដីគោកនិងសមុទ្រ) ដែលគ្រប់ដណ្ដប់ដោយច្បាប់អន្តោប្រវេសន៍របស់ប្រទេសណាមួយ | N/A | N/A | តំបន់នៅសមុទ្រអន្តរជាតិ និងដែនដីរបស់រដ្ឋមួយ ដែលក្នុងនោះមានការអនុវត្តច្បាប់អន្តោប្រវេសន៍របស់រដ្ឋនោះ ។ |
| Imprisonment | ការជាប់ទោសពន្ធនាគារ ទោសគុក | Imprison | Incarceration | ស្ថានភាពនៃការជាប់ឃុំ ឬ ពេលវេលាដែលជនណាម្នាក់ជាប់ឃុំក្នុងពន្ធនាគារតាមអំណាចសាលក្រមស្ថាពររបស់តុលាការ ។ |
| Incentive | សម្ភារ ឬគ្រឿងលើកទឹកចិត្ត | N/A | Inducement | ជាកត្តាណាមួយ(ហិរញ្ញវត្ថុ ឬក្រៅពីហិរញ្ញវត្ថុ) ដែលអាចឱ្យ ឬជំរុញឱ្យមានចំណាត់ការណាមួយ ឬចាត់បញ្ចូលថាជាមូលហេតុមួយនៃការជ្រើសយកជម្រើសណាមួយ ។ |
| Indecent act/ Indecency | អំពើអាស | N/A | Obscenity, lewdness | អំពើនៃការប៉ះពាល់ ឬ ការបង្ហាញកេរភេទ ឬ ផ្នែកភេទផ្សេងទៀតរបស់ជនដទៃ ឬ ការឱ្យជនដទៃប៉ះពាល់កេរភេទ ឬ ផ្នែកភេទផ្សេងទៀតរបស់ជនល្មើសខ្លួនឯង ឬ របស់ជនទីបី ក្នុងចេតនាធ្វើឱ្យរំជួលឬរីករាយដល់ចំណង់ផ្លូវភេទរបស់ជនល្មើស ។ (ស្រង់ចេញពីមាត្រា ៣៤១ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៤៣ នៃច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ) ។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Indecent assault | ការប្រទូស្តកេរ្តិ៍ខ្មាស<br>ការបៀតបៀនកេរ្តិ៍ខ្មាស | N/A | N/A | ការប្រទូស្តកេរ្តិ៍ខ្មាសសំដៅលើគ្រប់អំពើប៉ះពាល់ ស្ទាបអង្អែលកេរភេទ ឬផ្នែកភេទផ្សេងទៀតរបស់បុគ្គលដទៃ តែបុគ្គលនេះមកមិនស្ម័គ្រផងទេ ឬ បង្ខំបុគ្គលដទៃឱ្យប្រព្រឹត្តអំពើនេះមកលើខ្លួនឬទៅលើបុគ្គលទីបី ក្នុងគោលបំណងធ្វើឱ្យរំជួលឬរីករាយដល់ចំណង់ផ្លូវភេទរបស់ជនល្មើស (ស្រង់ចេញពី មាត្រា ២៤៦ នៃក្រមព្រហ្មទណ្ឌ) ។ ស្រដៀងគ្នានេះផងដែរ មាត្រា ៤២ នៃច្បាប់អ៊ុនតាក់ (ហើយដែលរំឭកឡើងវិញដោយមាត្រា ៧ នៃច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ) បានបញ្ជាក់បន្ថែមទៀតថាអំពើបៀតបៀនដល់កេរ្តិ៍ខ្មាស អាចប្រព្រឹត្តប្រឆាំងជនណាម្នាក់ទៀតដែលមានភេទដូចគ្នាឬមិនដូចគ្នា ដោយប្រព្រឹត្តទៅលើជននោះតាមការស្ទាបអង្អែល ឬអំពើផ្សេងទៀតទាក់ទងនឹងរឿងភេទ ប៉ុន្តែពុំបានដល់ទីជម្រៅ និងធ្វើឡើងដោយការបន្លំដោយអំពើហិង្សា ឬដោយការគំរាមកំហែង ។ |
| Individual migration | ការធ្វើទេសន្តរប្រវេសន៍ជាឯកជន | N/A | N/A | ករណីដែលបុគ្គលធ្វើទេសន្តរប្រវេសន៍តែឯង ឬ ជាគ្រួសារ ។ ជាទូទៅ ការធ្វើបន្លាស់ទីបែបនេះត្រូវចេញចំណាយដោយខ្លួនឯង ឬ មានបុគ្គល អង្គការ ឬ រដ្ឋាភិបាលជាអ្នកចេញជំនួសដែលខុសពីកម្មវិធីជាទ្រង់ទ្រាយធំ ។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Individualized assistance | ជំនួយសមស្របតាមលក្ខណៈបុគ្គល | N/A | N/A | *ជំនួយដែលផ្តល់ជូនជនរងគ្រោះដោយផ្អែកលើតម្រូវការជាលក្ខណៈបុគ្គលផ្ទាល់របស់ជននោះ ។* |
| Informed consent | ការយល់ព្រមដែលផ្អែកលើព័ត៌មានគ្រប់គ្រាន់ | N/A | N/A | *ការព្រមព្រៀងរបស់ជនរងគ្រោះក្នុងការសម្រេចទៅលើអ្វីមួយបន្ទាប់ពីខ្លួនទទួលបានព័ត៌មានគ្រប់គ្រាន់ ។* |
| Influx | លំហូរជនបរទេសទៅក្នុងប្រទេសមួយ (ក្នុងចំនួនច្រើន) | N/A | Arrival, inflow | *ការមកដល់ជាបន្តបន្ទាប់នៃជនបរទេសក្នុងចំនួនច្រើនចូលមកក្នុងប្រទេសមួយ ។* |
| Inhumane treatment | ការប្រព្រឹត្តអំពើអមនុស្សធម៌ | N/A | Brutality | *អំពើឃោរឃៅធ្ងន់ធ្ងរខាងផ្លូវកាយ ឬ ស្មារតី ដែលបង្កគ្រោះថ្នាក់ដល់ជីវិត ឬ សុខភាព ។* |
| Insensitivity | ភាពមិនរសើប ភាពមិនងាយទទួលឥទ្ធិពល ស្ពឹក | N/A | Insensitiveness, numb | *ភាពមិនឆ្លើយតបទៅនឹងការប្រែប្រួលពីមជ្ឈដ្ឋានខាងក្រៅ ។* |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Instigator | អ្នកផ្តើមគំនិត | Instigate | Initiator | អ្នកដែលជំរុញឱ្យប្រព្រឹត្តបទល្មើស តាមការណែនាំ ឬការបញ្ជា ឬ អ្នកដែលបង្កឱ្យមានបទល្មើសដោយផ្តល់អំណោយ ដោយការសន្យា ឬការគំរាមកំហែង ការញុះញង់ ការលួងលោម ឬក៏ដោយរំលោភអាជ្ញាឬអំណាចរបស់ខ្លួន។ |
| Institution | ស្ថាប័ន<br>ប្រព័ន្ធរួម | N/A | N/A | ក) អង្គការ ឬ ទីភ្នាក់ងារដែលប្រតិបត្តិការនៅក្នុងវិស័យសាធារណៈ ឬឯកជន<br>ខ) យន្តការបទបញ្ជា និងប្រពៃណីដែលមនុស្ស និងអង្គការនានាទាក់ទងជាមួយគ្នាទៅវិញទៅមក។ |
| Integrated approach | វិធីសាស្ត្រឬអភិក្រមពហុវិស័យ | N/A | N/A | អភិក្រម (វិធីសាស្ត្រ) មួយនៃការកសាងផែនការដែលនាំមកបញ្ចូលគ្នានូវបញ្ហានានាពីវិស័យជាច្រើន ស្ថាប័ននៅថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន និងក្រុមមនុស្សខុសៗគ្នា។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
| --- | --- | --- | --- | --- |
| Integration | សមាហរណកម្ម | Integrate | N/A | ដំណើរការមួយដែលជនអន្តោប្រវេសន៍ត្រូវបានទទួលឱ្យចូលនៅក្នុងសង្គមមួយ ទាំងក្នុងនាម ជាបុគ្គល និងជាក្រុម។ លក្ខខណ្ឌជាក់លាក់នានាសម្រាប់ការទទួលយកដោយសង្គមមួយដែលជាកន្លែងទទួលមានភាពខុសគ្នាជាខ្លាំងពីប្រទេសមួយទៅប្រទេសមួយផ្សេងទៀត ហើយការទទួលខុសត្រូវលើការធ្វើសមាហរណកម្មមិនមែនអាស្រ័យលើក្រុមជាក់លាក់ណាមួយនោះទេ ប៉ុន្តែអាស្រ័យលើក្រុមជាច្រើន ដូចជា ជនអន្តោប្រវេសន៍ខ្លួនឯង រដ្ឋាភិបាលជាម្ចាស់ផ្ទះ ស្ថាប័ននានា និងសហគមន៍ផងដែរ។ ក្នុងបរិបទជួញដូរមនុស្ស សមាហរណកម្មសំដៅទៅលើដំណើរការបញ្ជូនត្រឡប់ជនរងគ្រោះទៅរួមរស់ក្នុងគ្រួសារ និងសហគមន៍ ដោយយោងទៅតាមការសម្រេចចិត្តរបស់ជន-រងគ្រោះ ឬជាការបញ្ជូនជនរងគ្រោះទៅរស់នៅក្នុងសហគមន៍ថ្មីមួយទៀត។ |
| Interception | ការរារាំងមិនឱ្យចូលក្នុងប្រទេស | Intercept | Obstruction | វិធានការណាមួយដែលអនុវត្តដោយរដ្ឋមួយនៅក្រៅដែនដីរបស់ខ្លួន ដើម្បីទប់ស្កាត់ រារាំង ឬ បញ្ឈប់បន្ទាស់ទិរបស់បុគ្គលនានាដែលពុំមានឯកសារត្រឹមត្រូវសម្រាប់បញ្ជាក់ពីការឆ្លងកាត់តាមដែនគោក អាកាស ឬ សមុទ្រ និងដែលធ្វើដំណើរចូលក្នុងប្រទេសគោលដៅខុសៗគ្នា។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Internal disturbance | ស្ថានភាពរឹករវក្នុងប្រទេស | N/A | N/A | ស្ថានភាពមួយដែលឆ្លុះបញ្ចាំងអំពីអំពើហិង្សា និងគ្មានសណ្តាប់ធ្នាប់ ប៉ុន្តែស្ថានភាពនេះ មិនទាន់ឈានដល់ជម្លោះប្រដាប់អាវុធនៅឡើយទេ ។ |
| Internal migration | ចំណាកស្រុកក្នុងប្រទេស | N/A | N/A | ការផ្លាស់ទីរបស់ប្រជាជនពីកន្លែងមួយទៅកន្លែងមួយផ្សេងទៀតនៅក្នុងប្រទេសតែមួយក្នុងគោលបំណង ឬ ដែលបាននាំឱ្យមានការបង្កើតជម្រកស្នាក់នៅថ្មី ។ ចំណាកស្រុកបែបនេះអាចមានលក្ខណៈបណ្តោះអាសន្ន ឬអចិន្ត្រៃយ៍ ។ ជនចំណាកស្រុកក្នុងប្រទេសធ្វើបន្លាស់ទី ប៉ុន្តែនៅតែស្ថិតក្នុងរង្វង់ព្រំដែននៃប្រទេសកំណើតរបស់ខ្លួន (ដូចជា ចំណាកស្រុកពីជនបទទៅកាន់ទីក្រុងជាដើម) ។ |
| Internal Trafficking | អំពើជួញដូរមនុស្សក្នុងប្រទេស | N/A | N/A | ជាការជួញដូរមនុស្សនៅក្នុងប្រទេសតែមួយ ។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Internally displaced persons | ជនដែលត្រូវជម្លៀសទៅកាន់កន្លែងណាមួយក្នុងប្រទេស | N/A | N/A | បុគ្គល ឬ ក្រុមមនុស្សដែលបានរងការបង្ខំ ឬ ត្រូវភៀសខ្លួន ឬ ចាកចេញពីផ្ទះសំបែង ឬ កន្លែងរស់នៅប្រក្រតី ជាពិសេសដោយសារតែ ឬ ដើម្បីជៀសវាងឥទ្ធិពលនៃជម្លោះប្រដាប់អាវុធ ស្ថានភាពនៃអំពើហិង្សា ជាទូទៅ អំពើហិង្សាលើសិទ្ធិមនុស្ស ឬ គ្រោះមហន្តរាយធម្មជាតិ ឬ ដោយសកម្មភាពមនុស្ស និងជាអ្នកដែលពុំទាន់បានឆ្លងព្រំដែនរបស់រដ្ឋ ដែលមានការទទួលស្គាល់ជាអន្តរជាតិ។ |
| International armed conflict | ជម្លោះប្រដាប់អាវុធដែលមានលក្ខណៈជាអន្តរជាតិ ឬ ឆ្លងប្រទេស | N/A | N/A | សង្គ្រាមមួយដែលពាក់ព័ន្ធជាមួយរដ្ឋចំនួនពីរ ឬ ច្រើន។ |
| International law | ច្បាប់អន្តរជាតិ | N/A | N/A | គោលការណ៍ច្បាប់ដែលណែនាំដល់ទំនាក់ទំនងរវាងរដ្ឋនានា។ ថ្មីៗនេះ ច្បាប់ស្តីពីទំនាក់ទំនងអន្តរជាតិថែងមិនត្រឹមតែរវាងរដ្ឋនានាប៉ុណ្ណោះទេ ប៉ុន្តែរួមទាំងអ្នកពាក់ព័ន្ធផ្សេងៗ ដូចជាអង្គការអន្តរជាតិ និងសូម្បីតែបុគ្គលនានា (ដូចជា អ្នកដែលរំលោភសិទ្ធិមនុស្ស ឬ ប្រព្រឹត្តឧក្រិដ្ឋកម្មសង្គ្រាម)។ វាត្រូវបានហៅផងដែរថាជាច្បាប់ប្រជាជាតិ ឬ នីតិអន្តរជាតិ។ល។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| International migration | ទេសន្តរប្រវេសន៍អន្តរជាតិ<br>ទេសន្តរប្រវេសន៍ឆ្លងដែន | N/A | N/A | *ការផ្លាស់ទីរបស់បុគ្គលនានាដែលចាកចេញពីប្រទេសដើមរបស់ខ្លួន ឬ ប្រទេសដែលជាលំនៅប្រក្រតី ដើម្បីស្នាក់នៅ ឬ មួយជាបណ្តោះអាសន្ន ឬ ជាអចិន្ត្រៃយ៍នៅក្នុងប្រទេសមួយផ្សេងទៀត ។ ដូច្នេះ មានការឆ្លងកាត់ព្រំដែនអន្តរជាតិ ។* |
| International protection | ការការពារជាអន្តរជាតិ | N/A | N/A | *សកម្មភាពនានារបស់សហគមន៍អន្តរជាតិ ដោយផ្អែកលើច្បាប់អន្តរជាតិក្នុងគោលដៅការពារសិទ្ធិជាមូលដ្ឋាននៃជំពូកបុគ្គលជាក់លាក់នៅក្រៅប្រទេសដើមដែលខ្វះកិច្ចការពារពីថ្នាក់ជាតិនៅក្នុងប្រទេសផ្ទាល់ខ្លួន ។* |
| Intervention | អន្តរាគមន៍ | Intervene | Interposition, mediation | *ការប៉ុនប៉ងមួយដើម្បីកាត់បន្ថយការឈឺចាប់នៅក្នុងរដ្ឋមួយ ឬនៅកម្រិតបុគ្គល ដែលមានមហន្តរាយ ឬ អយុត្តិធម៌ ឬ ដែលកើតមានមហន្តរាយ ឬអយុត្តិធម៌ ។* |
| Interview | ការធ្វើសម្ភាស | Interview | N/A | *ដំណើរការមួយនៃការសាកសួរ ឬ និយាយជាមួយបុគ្គលម្នាក់ដើម្បីទទួលបានព័ត៌មាន ឬ កំណត់អំពីគុណភាពរបស់បុគ្គលនោះ ។ ការសម្ភាសគឺជាជំហានរួមមួយនៅក្នុងការវិនិច្ឆ័យលើពាក្យសុំសិទ្ធិជាជនភៀសខ្លួនសិទ្ធិផ្សេងទៀតខាងអន្តោប្រវេសន៍ ឬដើម្បីកំណត់អត្តសញ្ញាណថាជនរងគ្រោះ ជាដើម ។* |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Investigation | ការស៊ើបអង្កេត | Investigate | Enquiry, probe | ដំណើរការមួយជាផ្លូវការឬតាមផ្លូវតុលាការ ដើម្បីស្វែងរកភាពពិតអំពី ឬ បង្ហោយអ្វីមួយ ដែលមានដូចជា ឧក្រិដ្ឋកម្មគ្រោះថ្នាក់នៅក្នុងក្របខ័ណ្ឌនៃបញ្ហាវិទ្យាសាស្ត្រ ។ល។ |
| Involuntary labor slavery | ការធ្វើការងារទាសភាពដោយបង្ខំ | N/A | N/A | លក្ខខណ្ឌនៃសេវាកម្ម ឬ ការងារដែលចាំបាច់ត្រូវអនុវត្តដោយបុគ្គលណាម្នាក់ ជំទាស់នឹងឆន្ទៈរបស់ពួកគេ ដើម្បីជាប្រយោជន៍របស់បុគ្គលផ្សេងទៀត ដោយសារតែការបង្ខិតបង្ខំ ការគំរាមកំហែង ការបំភិតបំភ័យ ឬ មធ្យោបាយផ្សេងទៀតស្រដៀងគ្នានឹងការបង្ខិតបង្ខំ និងកាតព្វកិច្ច ដែលផ្ទុយនឹងឆន្ទៈរបស់ជននោះ ។ |
| Involuntary repatriation | ការធ្វើមាតុភូមិនិវត្តន៍ដោយបង្ខំ | N/A | N/A | ការធ្វើមាតុភូមិនិវត្តន៍នៃជនភៀសខ្លួនទៅក្នុងប្រទេសដើមតាមការស្នើសុំ ដោយប្រទេសទទួល ដោយបង្កើតកាលៈទេសៈដែលមិនបន្សល់ទុកជម្រើសផ្សេងទៀតណាមួយឡើយ ។ ដោយសារការធ្វើមាតុភូមិនិវត្តន៍ គឺជាសិទ្ធិផ្ទាល់ខ្លួន (មិនដូចការបណ្តេញចេញ និងការធ្វើនិរទេសឡើយ ដែលភាគច្រើនស្ថិតនៅក្នុងវិស័យនៃអធិបតេយ្យរបស់រដ្ឋ) ទាំងរដ្ឋដែលជននោះមានសញ្ជាតិ ទាំងរដ្ឋ ដែលជាកន្លែងស្នាក់នៅបណ្តោះអាសន្ន ឬ រដ្ឋដែលមានអំណាចចាប់ឃុំជននោះពុំអាចដោះសារលើកលែងពីការធ្វើមាតុភូមិនិវត្តន៍ដោយបង្ខំ និងដោយផ្ទុយពីឆន្ទៈរបស់បុគ្គល ដែលមានសិទ្ធស្របច្បាប់ឡើយ បើទោះបីបុគ្គលនោះជាជនភៀសខ្លួន ឬ ជាឈ្លើយសឹកក៏ដោយ ។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Involuntary servitude | សេវភាពដោយមិនស្ម័គ្រចិត្ត | N/A | N/A | *ការបង្ខំឱ្យបុគ្គលណាម្នាក់ធ្វើការដោយការគំរាមកំហែង បង្កគ្រោះថ្នាក់ការបំពានលើរូបកាយ ការកំហិត ឬ ការសងសឹកដែលស្របច្បាប់ ។* |
| Irregular migrant | ជនធ្វើទេសន្តរប្រវេសន៍មិនរៀបរយ | N/A | N/A | *បុគ្គលដែលខ្វះឋានៈតាមផ្លូវច្បាប់នៅក្នុងប្រទេសសំចត ឬ ប្រទេសជាម្ចាស់ផ្ទះ ដោយសារតែការចូលដោយខុសច្បាប់ ឬ ការផុតសុពលភាពនៃទិដ្ឋាការ ។ ពាក្យនេះសំដៅលើជនអន្តោប្រវេសន៍ ដែលរំលោភលើបទប្បញ្ញត្តិនៃការចូលក្នុងប្រទេស និងបុគ្គលដទៃទៀត ដែលមិនមានសិទ្ធិស្នាក់នៅក្នុងប្រទេសជាម្ចាស់ផ្ទះ (គេអាចហៅផងដែរថាជាជនអន្តោប្រវេសន៍ លួចលាក់/មិនស្របច្បាប់/គ្មានឯកសារ ឬ ជនអន្តោប្រវេសន៍នៅក្នុងស្ថានភាពមិនប្រក្រតី) ។* |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
| --- | --- | --- | --- | --- |
| Irregular migration | ការធ្វើទេសន្តរប្រវេសន៍ដោយមិនរៀបរយ | N/A | N/A | បន្លាស់ទីដែលកើតឡើងនៅក្រៅនិយាមរបស់ប្រទេស បញ្ជូន ប្រទេសសំចត និងប្រទេសទទួល ។ គេគ្មាននិយមន័យច្បាស់លាស់ ឬដែលមានការទទួលយកជាសកលឡើយ ហើយបើគិតតាមទស្សនៈរបស់ប្រទេសជាទីដៅ នេះជាការចូលស្នាក់នៅ ឬធ្វើការក្នុងប្រទេសមួយដោយល្មើសច្បាប់ ដែលមានន័យថាជនអន្តោប្រវេសន៍មិនមានការអនុញ្ញាតចាំបាច់ ឬឯកសារនានា នៅក្រោមបទប្បញ្ញត្តិអន្តោប្រវេសន៍សម្រាប់ចូលស្នាក់នៅ ឬធ្វើការនៅក្នុងប្រទេសនោះ ។ តាមទស្សនៈរបស់ប្រទេសបញ្ជូន ភាពមិនប្រក្រតីនេះត្រូវបានមើលឃើញនៅក្នុងករណីនានា ដែលបុគ្គលម្នាក់ឆ្លងកាត់ព្រំដែនអន្តរជាតិដោយគ្មានលិខិតឆ្លងដែនមានសុពលភាព ឬឯកសារធ្វើដំណើរ ឬមិនបានបំពេញតាមលក្ខខណ្ឌរដ្ឋបាលសម្រាប់ការចេញពីប្រទេសនោះឡើយ ។ ទោះជាយ៉ាងណាក៏ដោយ គេឃើញមាននិន្នាការក្នុងការដាក់ម្រិតការប្រើប្រាស់ពាក្យ "ទេសន្តរប្រវេសន៍ខុសច្បាប់" មកត្រឹមករណីនៃការរត់ពន្ធជនអន្តោប្រវេសន៍ និង ការជួញដូរមនុស្សប៉ុណ្ណោះ ។ |
| Itinerant worker | អ្នកធ្វើការចល័ត | N/A | N/A | ពលករចំណាកស្រុក ដែលមានកន្លែងស្នាក់នៅជាធម្មតារបស់ខ្លួននៅក្នុងរដ្ឋមួយ និងបានធ្វើដំណើរទៅរដ្ឋមួយ ឬ រដ្ឋនានាផ្សេងទៀតសម្រាប់រយៈពេលខ្លី ដោយសារតែប្រភេទមុខរបររបស់គាត់ ។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Judgment | សាលក្រម | Judge | Verdict, ruling, decision | សេចក្តីសម្រេចចុងក្រោយរបស់តុលាការនូវសិទ្ធិ និងកាតព្វកិច្ចរបស់ភាគីនានាក្នុងរឿងក្តីមួយ ។ |
| Jurisdiction | យុត្តាធិការ<br>ដែនសមត្ថកិច្ច | N/A | N/A | សិទ្ធិ ឬ សមត្ថកិច្ចប្រើប្រាស់អំណាចផ្លូវការដើម្បីធ្វើការសម្រេចខាងផ្លូវច្បាប់ ឬ ទីតាំងដែលសិទ្ធិបែបនេះអាចត្រូវយកមកអនុវត្តបាន ។ |
| Jus sanguinis | គោលការណ៍ ឬ សិទ្ធិទទួលបានសញ្ជាតិតាមរយៈ: ចំណងលោហិត | N/A | N/A | បទបញ្ញា ឬ សិទ្ធិ ដែលសញ្ជាតិរបស់កុមារមួយរូបត្រូវបានកំណត់ដោយសញ្ជាតិរបស់ឪពុក ម្តាយរបស់ខ្លួន ដោយមិនគិតពីកន្លែងកំណើតរបស់ខ្លួនឡើយ ។ |
| Jus soli | គោលការណ៍ឬ សិទ្ធិទទួលបានសញ្ជាតិតាមរយៈ: ទីកន្លែងកំណើត | N/A | N/A | បទបញ្ញា ឬសិទ្ធិ ដែលសញ្ជាតិរបស់កុមារមួយរូបត្រូវបានកំណត់ដោយកន្លែងកំណើត (ទោះបីកុមារនោះអាចទទួលសញ្ជាតិបន្តពីឪពុកម្តាយខ្លួនក៏ដោយ) ។ |
| Juvenile | ដែលនៅជាអនីតិជនឬកុមារ | N/A | Young, immature, adolescent, childish | ដែលនៅក្មេងនៅឡើយ ។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Karaoke parlor | ហាងខារ៉ាអូខេ | N/A | N/A | *កន្លែងដែលផ្តល់ការកំសាន្តដោយមានម៉ាស៊ីនខារ៉ាអូខេសម្រាប់ច្រៀង និងរាំ ។* |
| Key informants | អ្នកផ្តល់ព័ត៌មានសំខាន់ៗ | N/A | N/A | *បុគ្គលដែលមានវិជ្ជាជីវៈណាមួយ (ដូចជា គិលានុបដ្ឋាក គ្រូបង្រៀន និងកសិករក្រីក្រ) និងដែលផ្តល់ទស្សនៈនានារបស់ខ្លួនអំពីបញ្ហាខុសៗគ្នា ។* |
| Kidnapping | ការចាប់ពង្រត់ | Kidnap | Abduction | *ការចាប់ពង្រត់ ឬការឃុំឃាំងដោយបង្ខំមិនស្របច្បាប់លើបុគ្គល ឬក្រុមបុគ្គលនានា ។ តាមធម្មតាវាត្រូវបានធ្វើឡើងក្នុងបំណងជំរិតយកផលប្រយោជន៏ខាងសេដ្ឋកិច្ច ឬនយោបាយពីជនរងគ្រោះដោយសារការជួញដូរ ឬ ពីភាគីទីបី ។ តាមធម្មតា ការចាប់ពង្រត់ត្រូវស្ថិតនៅក្រោមច្បាប់ព្រហ្មទណ្ឌរបស់ជាតិនៃរដ្ឋនីមួយៗ ។ ទោះជាយ៉ាងណាក៏ដោយ មានការចាប់ពង្រត់ខ្លះៗដែលស្ថិតនៅក្រោមច្បាប់អន្តរជាតិ (ដូចជា អំពើប្លន់តាមសមុទ្រ) ។* |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Labor migration | ទេសន្តរប្រវេសន៍ការងារ<br>ចំណាកស្រុកដើម្បីរកការងារ | N/A | N/A | បន្លាស់ទីរបស់បុគ្គលនានាពីរដ្ឋជាកន្លែងកំណើតរបស់ខ្លួន ទៅរដ្ឋមួយផ្សេងទៀតក្នុងបំណងស្វែងរកការងារ ។ ទេសន្តរប្រវេសន៍ដើម្បីស្វែងរកការងារមានចែងនៅក្នុងច្បាប់ទេសន្តរប្រវេសន៍នៅក្នុងរដ្ឋភាគច្រើន ។ លើសពីនេះ រដ្ឋខ្លះដើរតួយ៉ាងសកម្មនៅក្នុងការកម្រិតលើទេសន្តរប្រវេសន៍ចេញទៅរកការងារធ្វើ និងស្វែងរកឱកាសសម្រាប់ប្រជាពលរដ្ឋរបស់ខ្លួន នៅក្រៅប្រទេស ។ |
| Labor shortage | កង្វះខាតកំលាំងពលកម្ម | N/A | N/A | លក្ខខណ្ឌសេដ្ឋកិច្ចដែលក្នុងនោះពុំមានបេក្ខជន (និយោជិត) ប្រកបដោយគុណវុឌ្ឍិគ្រប់គ្រាន់ ដើម្បីបំពេញតម្រូវការលើទីផ្សារការងារ ។ |
| Legal procedure | នីតិវិធីច្បាប់<br>ក្បួននីតិវិធីច្បាប់ | N/A | Rules, methods, proceeding, way | ជាវិធាន និងវិធីនៃដំណើរការនៃបណ្តឹងឬចំណាត់ការមួយដែលរួមមាន ការជជែកការពារក្តី ការចាប់ខ្លួន ការឃុំខ្លួន វិធានការផ្សេងៗ ការបង្ហាញភ័ស្តុតាង និងការអនុវត្តតាមវិធានច្បាប់ជាដើម ។ |
| Legitimate | ដែលត្រឹមត្រូវស្របច្បាប់<br>ដែលទទួលស្គាល់ពេញ<br>លក្ខណៈច្បាប់ជាធម្មានុរូប | N/A | Genuine, lawful, licit real, verifiable | អ្វីមួយដែលពិតឥតក្លែងក្លាយ មានសុពលភាព ឬស្របច្បាប់ ដូចជា ជនអន្តោប្រវេសន៍ម្នាក់ ចូលក្នុងប្រទេសមួយ ក្នុងបំណងស្របច្បាប់ក្នុងការគោរពតាមច្បាប់អន្តោប្រវេសន៍ និងមានឯកសារធ្វើដំណើរស្របច្បាប់ ។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Laissez-passer | លិខិតបើកផ្លូវ | N/A | N/A | ជាលិខិតសម្រាប់ចេញ-ចូលតំបន់ណាមួយជាក់លាក់នៃប្រទេសមួយ ហើយត្រូវបានប្រើក្នុងគោលដៅជាកំណត់ដូចជា កិច្ចការមនុស្សធម៌ ការសង្គ្រោះបន្ទាន់ ឬសម្រាប់ជនដែលគ្មានសញ្ជាតិ ។ លិខិតនេះប្រើបានតែម្តងប៉ុណ្ណោះក្នុងការធ្វើដំណើរចេញ ឬ ចូលប្រទេសណាមួយ ។ ក្នុងក្របខ័ណ្ឌអង្គការសហប្រជាជាតិ លិខិតបើកផ្លូវត្រូវបានចេញដោយអង្គការសហប្រជាជាតិផ្ទាល់សម្រាប់ឱ្យបុគ្គលិករបស់ខ្លួនអាចបំពេញបេសកកម្មផ្លូវការនៅក្នុងរដ្ឋមួយបាន ។ |
| Legal proceedings | កិច្ចនៃនីតិវិធីច្បាប់<br>កិច្ចនៃនីតិវិធីតុលាការ | N/A | Legal procedure | ដំណាក់កាលណាមួយនៃនីតិវិធីដែលតួអង្គផ្សេងៗនៅក្នុងប្រព័ន្ធយុត្តិធម៌ត្រូវបំពេញកិច្ច តាមក្បួន ឬ ច្បាប់ដែលបានកំណត់ ។ |
| Life skill | បំណិនជីវិត | N/A | N/A | សំដៅដល់ចំណេះដឹងដែលផ្តោតលើសុខភាព ការបង្ការទប់ស្កាត់អាហារូបត្ថម្ភ ការយល់ដឹងពីកិច្ចការពលរដ្ឋ និងបរិស្ថាន ជំនាញសង្គម និងជំនាញក្នុងការប្រាស្រ័យទាក់ទងគ្នារបស់អ្នកសិក្សា ។ (ច្បាប់ ស្តីពីការអប់រំ) |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Limitations of human rights | ការរិតត្បិតទៅលើសិទ្ធិមនុស្ស | N/A | N/A | *សិទ្ធិជាច្រើនរបស់មនុស្សមិនមែនដាច់ខាតនោះឡើយ ។ បទប្បញ្ញត្តិសិទ្ធិមនុស្សផ្ទាល់ ច្រើនតែមានមាត្រាជាក់លាក់ (ដែលថែងជាទូទៅក៏ដូចជាជាក់លាក់ផងដែរ) ដែលដាក់កម្រិតលើសិទ្ធិទាំងនេះ ។ នៅថ្នាក់ជាតិ រដ្ឋធម្មនុញ្ញច្រើនតែមានថែងដូចគ្នាអំពីការដាក់កម្រិតទៅលើការប្រើប្រាស់សិទ្ធិ ។* |
| Livelihoods | មធ្យោបាយចិញ្ចឹមជីវិត | N/A | N/A | *បង្គុំនៃធនធានដែលបានប្រើប្រាស់ និងសកម្មភាពនានាដែលបានធ្វើឡើងដើម្បីរស់នៅ ។ ធនធាននានារាប់បញ្ចូលទាំងជំនាញរបស់បុគ្គល (មូលធនមនុស្ស) ដីធ្លី (មូលធនធម្មជាតិ) ប្រាក់សន្សំ (មូលធនហិរញ្ញវត្ថុ) បរិក្ខារ (មូលធនរូបវន្ត) ក៏ដូចជាក្រុមគាំទ្រផ្លូវការ និង បណ្តាញមិនផ្លូវការ (មូលធនសង្គម) ជាដើម ។* |
| Local Integration | ការធ្វើសមាហរណកម្មទៅក្នុងប្រទេសណាមួយ | N/A | N/A | *ដំណោះស្រាយយូរអង្វែងមួយចំពោះបញ្ហាជនភៀសខ្លួន ដែលពាក់ព័ន្ធនឹងការតាំងទីលំនៅអចិន្ត្រៃយ៍របស់ពួកគេនៅក្នុងប្រទេសមួយ ដែលពីដំបូងផ្តល់សិទ្ធិត្រឹមជ្រកកោន និង ក្រោយមកត្រូវបានអនុញ្ញាតឱ្យចូលសញ្ជាតិនៃប្រទេសនោះ ។* |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Long-term migrant | អ្នកធ្វើចំណាកស្រុករយៈពេលវែង | N/A | N/A | បុគ្គលម្នាក់ ដែលចូលទៅក្នុងប្រទេសមួយក្រៅពីប្រទេសជាកន្លែងរស់នៅជាធម្មតារបស់ខ្លួនសម្រាប់រយៈពេល យ៉ាងហោចណាស់មួយឆ្នាំ ដើម្បីឱ្យប្រទេសជាទីដៅក្លាយជាប្រទេសថ្មីមួយសម្រាប់ការរស់នៅជាធម្មតារបស់ខ្លួន។ តាមទស្សនៈរបស់ប្រទេសជាកន្លែងចេញដំណើរ បុគ្គលនោះនឹងក្លាយជាជនចំណាកស្រុករយៈពេលវែងមួយ និងតាមទស្សនៈរបស់ប្រទេសជាកន្លែងមកដល់បុគ្គលនោះនឹងក្លាយជាជនអន្តោប្រវេសន៍រយៈពេលវែង។ |
| Loss of nationality | ការបាត់បង់សញ្ជាតិ | N/A | N/A | ការបាត់បង់សញ្ជាតិអាចកើតឡើង ដោយអំពើរបស់បុគ្គល (ការនិរទេសការលះបង់ចោល ដោយចេតនានូវសញ្ជាតិពីសំណាក់បុគ្គលនោះ ឬការបាត់បង់ដោយស្វ័យប្រវត្តិនូវសញ្ជាតិ ក្រោយពីបានទទួលសញ្ជាតិមួយផ្សេងទៀត) ឬ ដោយរដ្ឋ (និជាតូបនីយកម្ម)។ ជាតូបនីយកម្ម ជាអំពើដោយឯកតោភាគីរបស់រដ្ឋ ទោះជាតាមរយៈការសម្រេចរបស់អាជ្ញាធររដ្ឋបាល ឬ ដោយការអនុវត្តច្បាប់ក៏ដោយ ដែលធ្វើឱ្យបុគ្គលបាត់បង់សញ្ជាតិរបស់ខ្លួន។ ទោះបីជាគ្មានបទប្បញ្ញត្តិឯកភាពគ្នាអំពីនិជាតូបនីយកម្មក៏ដោយ រដ្ឋខ្លះៗបានបង្កើតមូលដ្ឋាននៃលក្ខន្តិកៈសម្រាប់ដំណើរការនេះ ដែលរួមទាំងការចូលក្នុងសេវាកម្មស៊ីវិល ឬ យោធានៅបរទេស ការទទួលយកគោរម្យងារបរទេស ការចោទប្រកាន់ពីបទព្រហ្មទណ្ឌជាក់លាក់។ ទោះបីជាគោលការណ៍ការទទួលបាន និងការបាត់បង់សញ្ជាតិត្រូវបានចាត់ទុកថាជាការធ្លាក់ចុះនៃវិស័យសមត្ថកិច្ចនៅក្នុងប្រទេសក៏ដោយ រដ្ឋនានាត្រូវគោរពតាមនិយាមនៃច្បាប់អន្តរជាតិនៅពេលកំហិតលើបញ្ហាសញ្ជាតិ។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Marginalization | ការដាក់ឱ្យស្ថិតនៅក្នុងសភាពឯកោ និងមិនសំខាន់ | Marginalize | N/A | ជាដំណើរការសង្គមនៃការក្លាយជា ឬ បានធ្វើឱ្យមានកម្រិតបន្ទាប់បន្សំ (ក្នុងការកំហិតលើ ឬ មានត្រឹមតែលក្ខខណ្ឌទាបខាងសង្គម ឬ ផ្នែកខាងក្រៅនៃគោលការណ៍សង្គម)។ |
| Massage parlor | ហាងឬកន្លែងម៉ាស្សា | N/A | N/A | កន្លែងដែលផ្តល់សេវាម៉ាស្សា។ |
| Mass migration | ការធ្វើចំណាកស្រុកជាក្រុម ឬក្នុងទ្រង់ទ្រាយធំ | N/A | Collective migration | ការបន្លាស់ទីភ្លាមៗនៃមនុស្សក្នុងចំនួនច្រើន។ |
| Member of minority | សមាជិកក្រុមជនជាតិភាគតិច | N/A | N/A | ទោះបីមានប្រភពដើមនៅក្នុងប្រទេសផ្សេងមួយក៏ដោយបុគ្គលម្នាក់បានទទួលសញ្ជាតិពីប្រទេសដែលខ្លួនរស់នៅ ទោះជាពីកំណើត ឬ ដោយការចូលសញ្ជាតិ។ |
| Memorandum | អនុស្សរណៈ<br>សារណា | N/A | Agreement, memo | ឯកសារច្បាប់ខ្លីមួយដែលមានចែងអំពីសេចក្តីលំអិតសំខាន់ៗអំពីកិច្ចព្រមព្រៀងមួយរវាងរដ្ឋ និងរដ្ឋ។ ក្នុងនីតិវិធីតុលាការ ឯកសារដែលមេធាវីឬភាគីអាចដាក់ជូនតុលាការដើម្បីបំភ្លឺបន្ថែមកិច្ចការផ្សេងៗត្រូវបានហៅថាសារណា។ នៅក្នុងការងាររបស់អង្គការសង្គមស៊ីវិល ការជូនព័ត៌មានផ្សេងៗជាលាយលក្ខណ៍អក្សរទៅកាន់បុគ្គលិក អ្នកគ្រប់គ្រង ឬអ្នកធ្វើការងារពាក់ព័ន្ធក្នុងក្របខ័ណ្ឌនៃវិសាលភាពស្ថាប័នរបស់ខ្លួនក៏ភាគច្រើនត្រូវបានគេធ្វើឡើងក្នុងទម្រង់ជាសារណានេះផងដែរ។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Memorandum of Understanding (MoU) | អនុស្សរណៈនៃការយោគយល់គ្នា | N/A | Agreement | ឯកសារផ្លូវច្បាប់ដែលចងភ្ជាប់កាតព្វកិច្ច និងចែងអំពីសិទ្ធិរវាងរដ្ឋពីរ ។ |
| Microcredit | ឥណទានខ្នាតតូច ឬ មីក្រូឥណទាន | N/A | Micro-finance | មីក្រូឥណទាន គឺជាការពង្រីកបំណុលទំហំតូច (បំណុលខ្នាតតូច) ដល់អ្នកគ្មានការងារធ្វើ សហគ្រិនក្រីក្រ និងដល់អ្នកដទៃទៀតដែលរស់នៅក្នុងភាពក្រីក្រ ។ |
| Migrant | ជនធ្វើចំណាកស្រុក ឬ ជនធ្វើទេសន្តរប្រវេសន៍ | Migrate | N/A | នៅកម្រិតអន្តរជាតិគ្មាននិយមន័យ ដែលមានការទទួលយកបានជាសកលអំពីជនចំណាកស្រុកឡើយ ។ ពាក្យជនចំណាកស្រុកតាមធម្មតាត្រូវបានគេយល់ថាវាគ្របដណ្តប់គ្រប់ករណីដែលការសម្រេចនានាដើម្បីធ្វើចំណាកស្រុកត្រូវបានធ្វើឡើងដោយសេរីពីសំណាក់បុគ្គលនានាដែលពាក់ព័ន្ធ ដោយសារតែហេតុផលនៃ "ភាពងាយស្រួលផ្ទាល់ខ្លួន" និងដោយគ្មានអន្តរាគមន៍ពីកត្តាជម្រុញពីខាងក្រៅណាមួយឡើយ ។ ដូច្នេះពាក្យនេះ ទាក់ទងនឹងបុគ្គល និងសមាជិកគ្រួសារដែលផ្លាស់ទីទៅប្រទេស ឬ តំបន់មួយផ្សេងទៀត ដើម្បីកែលម្អលក្ខខណ្ឌសម្ភារ និងសង្គមរបស់ពួកគេ និងកែលម្អទស្សនទានសម្រាប់ខ្លួនឯង ឬ គ្រួសាររបស់ពួកគេ ។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Migrant flow | លំហូរនៃអ្នកធ្វើចំណាកស្រុក | N/A | N/A | ចំនួនជនចំណាកស្រុកដែលត្រូវចាត់ទុកថា ផ្លាស់ទី ឬបានទទួលការអនុញ្ញាតឱ្យផ្លាស់ទីទៅ ឬ មកពីប្រទេសមួយក្នុងការទទួលបានការងារធ្វើ ឬ ដើម្បីតាំងលំនៅដោយខ្លួនឯងនៅក្នុងអំឡុងពេលកំណត់មួយ ។ |
| Migrant Labor | ការងារសម្រាប់ពលករចំណាកស្រុក | N/A | N/A | ការងារដែលបានធ្វើឡើងដោយមនុស្សដែលធ្វើដំណើរ ដើម្បីស្វែងរកការងារធ្វើ ។ តាមធម្មតាអ្នកទាំងនោះ គឺជាជនចំណាកស្រុកដែលជួនកាលដោយល្មើសច្បាប់ និងច្រើនតែរងការកេងប្រវ័ញ្ចពីនិយោជកររបស់ខ្លួន ។ ភាគច្រើននៃការងារស្ថិតក្នុងវិស័យកសិកម្មហើយពលករផ្លាស់ទីគ្មានទីដៅច្បាស់លាស់ក្នុងប្រទេសនោះ ដើម្បីប្រមូលផលដំណាំនៅក្នុងរដូវខុសៗគ្នា ។ តាមធម្មតាពួកគេបានទទួលកម្រៃតិចតួចពីការងារនោះ ហើយជួនកាលបានឈានចូលទៅក្នុងទាសភាព នៅពេលពួកគេពុំបានទទួលកម្រៃទាល់តែសោះ និងមិនអាចចាកចេញវិញបាន ។ |
| Migrant Worker | ពលករទេសន្តរប្រវេសន៍<br>ពលករចំណាកស្រុក | N/A | N/A | ពលករដែលធ្វើចំណាកស្រុកចេញពីប្រទេសដើមទៅកាន់ប្រទេសគោលដៅដើម្បីធ្វើការងារ ឬរកប្រាក់ចំណូល ។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Migrants for settlement | អ្នកធ្វើចំណាកស្រុកដើម្បីតាំងលំនៅ | N/A | N/A | ជនបរទេសដែលបានទទួលការអនុញ្ញាតឱ្យស្នាក់នៅរយៈពេលវែង ឬ គ្មានកាលកំណត់ និងគ្មានរងការកំហិតដែលទាក់ទងនឹងសិទ្ធិអនុវត្តសកម្មភាពសេដ្ឋកិច្ច សង្គម និងនយោបាយ (ដូចជាពលករស្វែងរកការងារ ជនចំណាកស្រុកជាគ្រួសារ ជនចំណាកស្រុកជាច្រើនតំណ ជនចំណាកស្រុកដែលមានសិទ្ធិក្នុងការតាំងទីលំនៅដោយសេរី ឬ និវត្តន៍ជនបរទេស)។ |
| Migration | ចំណាកស្រុក<br>ទេសន្តរប្រវេសន៍ | Migrate | N/A | ដំណើរការមួយនៃបន្លាស់ទី ទោះជាឆ្លងដែន ឬ នៅក្នុងរដ្ឋមួយក៏ដោយ។ នេះជាបន្លាស់ទីរបស់មនុស្ស ដែលគ្របដណ្តប់លើរាល់ទម្រង់នៃបន្លាស់ទីដោយមិនគិតអំពីរយៈពេល សមាសភាព និងមូលហេតុ។ វាក៏រាប់បញ្ចូលទេសន្តរប្រវេសន៍នៃជនភៀសខ្លួន ជនចំណាកស្រុក ពលរដ្ឋដែលត្រូវបង្ខំឱ្យចាកចេញពីលំនៅឋាន និងជនចំណាកស្រុកដើម្បីសេដ្ឋកិច្ចផងដែរ។ |
| Migration Management | ការគ្រប់គ្រងការធ្វើចំណាកស្រុក | N/A | N/A | ពាក្យប្រើប្រាស់សំដៅលើមុខនាទីជាច្រើនរបស់រដ្ឋាភិបាល និងប្រព័ន្ធថ្នាក់ជាតិនៃការគ្រប់គ្រងទេសន្តរប្រវេសន៍ឆ្លងដែនតាមលំដាប់លំដោយ និងប្រកបដោយមនុស្សធម៌ ជាពិសេស ការគ្រប់គ្រងលើការចូល និងវត្តមាននៃជនបរទេសនៅក្នុងព្រំដែនរបស់រដ្ឋ និងកិច្ចការពារជនភៀសខ្លួន និងជនដទៃទៀតដែលត្រូវការឱ្យមានកិច្ចការពារ។ |

| ពាក្យ | ខ្មែរ | ការិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Military use of children | ការប្រើកុមារធ្វើជាកងទ័ព | N/A | N/A | កុមារអាចចូលរួមដោយផ្ទាល់នៅក្នុងចម្បាំង (យុទ្ធជនកុមារ) ឬ ពួកគេអាចត្រូវប្រើប្រាស់នៅក្នុងតួនាទីគាំទ្រនានា ដូចជា អ្នកលីសែង អ្នកស៊ើបការណ៍ នីរសារ អ្នកមើលផ្លូវ និងទាសករខាងផ្លូវភេទ ឬ ពួកគេអាចត្រូវបានប្រើប្រាស់សម្រាប់ផលប្រយោជន៍ខាងនយោបាយ ឬ មួយជារបាំងមនុស្ស ឬ នៅក្នុងការឃោសនា។ |
| Millennium Development Goals | គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ | N/A | N/A | សេចក្តីសង្ខេបមួយ អំពីគោលដៅអភិវឌ្ឍន៍ដែលមានចែងនៅក្នុងសន្និសីទអន្តរជាតិ និងកិច្ចប្រជុំកំពូលពិភពលោកនៅក្នុងអំឡុងទសវត្សរ៍ឆ្នាំ ១៩៩០។ |
| Minimum standards | បទដ្ឋានអប្បបរមា | N/A | Basic rule | និយាម វិធាន ក្បួន ឬស្តង់ដារ ក្នុងកម្រិតមូលដ្ឋាន ឬកម្រិតយ៉ាងទាបមួយ ដែលតម្រូវឱ្យមានការទទួលស្គាល់ជាទូទៅ។ |
| Minor | អនីតិជន | N/A | Kid, adolescent, child, infant, juvenile, teenager, underage | យោងតាមច្បាប់នៃប្រទេសមួយចំនួនបុគ្គលម្នាក់ ដែលស្ថិតក្រោមអាយុពេញវ័យ ពោលគឺនៅពុំទាន់អាចអនុវត្តសិទ្ធិពលរដ្ឋ និងសិទ្ធិខាងនយោបាយណាមួយជាក់លាក់។ សម្រាប់ប្រទេសកម្ពុជាអនីតិជនសំដៅលើជនដែលមានអាយុក្រោម ១៨ ឆ្នាំ។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Minority | ក្រុមជនភាគតិច | N/A | N/A | ទោះបីពុំមាននិយមន័យដែលមានការទទួលយកជាសកលអំពីជនជាតិភាគតិចក៏ដោយ នៅក្នុងច្បាប់អន្តរជាតិ ក្រុមជនជាតិភាគតិចមួយអាចត្រូវចាត់ទុកថា ជាក្រុមមួយដែលមានចំនួនតិចជាងក្រុមពលរដ្ឋដទៃទៀតនៅក្នុងរដ្ឋមួយ និងនៅក្នុងតំណែងដែលគ្មានអំណាចលុប ហើយសមាជិកនៃក្រុមនេះ មានជាតិពន្ធ សាសនា ឬភាសា ដែលខុសគ្នាពីក្រុមជនជាតិដទៃទៀតនៅក្នុងចំណោមប្រជាពលរដ្ឋសរុប និងដែលអាចរក្សាសាមគ្គីភាពនៅក្នុងការថែរក្សាវប្បធម៌ ប្រពៃណី សាសនា និងភាសារបស់ខ្លួនបានគត់មត់ ។ |
| Monitoring | ការពិនិត្យតាមដាន<br>ការត្រួតពិនិត្យ | Monitor | N/A | ការពិនិត្យឡើងវិញជាប្រចាំ និងការត្រួតពិនិត្យមើលការអនុវត្តគម្រោងមួយ ដើម្បីធានាថាធាតុចូលកម្មវិធីការងារ និងសកម្មភាពដែលបានឯកភាពគ្នាហើយនោះបានប្រព្រឹត្តទៅដូចការគ្រោងទុក និងលក្ខខណ្ឌនៃថវិកា ។ |
| Multilateral | ពហុភាគី | N/A | N/A | ទាក់ទងនឹងសន្និសញ្ញា និងការចរចាពហុភាគីសំដៅលើការពាក់ព័ន្ធនៃរដ្ឋចំនួនច្រើនជាងពីរនៅក្នុងដំណើរការនោះ ។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| National | ជាតិ | N/A | N/A | បុគ្គលម្នាក់ ដែលជាសមាជិកសហគមន៍នយោបាយមួយ ឬ មួយតាំងពីកំណើត ឬ មួយដោយសារការចូលសញ្ជាតិ ដោយសារតែភក្តីភាពជាមួយសហគមន៍នោះ និងមានសិទ្ធិក្នុងការអនុវត្តគ្រប់សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងការទទួលបានកិច្ចការពារ ។ គឺជាសមាជិកនៃរដ្ឋមួយដែលមានសិទ្ធិពេញលេញជាពលរដ្ឋ ។ បុគ្គលម្នាក់ដែលមានសិទ្ធិទទួលសញ្ជាតិរបស់រដ្ឋណាមួយ ។ |
| Nationality | សញ្ជាតិ | N/A | Citizenship | ការធានាតាមផ្លូវច្បាប់រវាងបុគ្គលម្នាក់ និងរដ្ឋមួយ ។ តុលាការយុត្តិធម៌អន្តរជាតិបានឱ្យនិយមន័យសញ្ជាតិនៅក្នុងករណី Nottebohm ឆ្នាំ ១៩៥៥ ថាជា "...ការធានាមួយតាមផ្លូវច្បាប់ ដែលមានមូលដ្ឋានលើសម្ព័ន្ធភាពសង្គម អត្ថិភាពជាមួយគ្នាពិតប្រាកដ ចំណាប់អារម្មណ៏ និងមនោសញ្ចេតនារួមផ្សំជាមួយអត្ថិភាពនៃសិទ្ធិ និងករណីយកិច្ចចំពោះគ្នាទៅវិញទៅមក... បុគ្គលដែលមានជាប់ទាក់ទងដោយផ្ទាល់រវាងគ្នា ឬ មួយតាមរយៈច្បាប់ ឬ ដោយសារតែអំពើរបស់អាជ្ញាធរ ដែលពិតជាមានទំនាក់ទំនងកាន់តែជិតស្និទ្ធជាមួយពលរដ្ឋនៅក្នុងរដ្ឋនោះ ដែលមានទំនាក់ទំនងខាងសញ្ជាតិជាងជាមួយរដ្ឋណាមួយផ្សេងទៀត ។" យោងតាមមាត្រា ១) អនុសញ្ញាទីក្រុងឡាអេស្តីពីបញ្ហាទាក់ទងនឹងទំនាស់ច្បាប់សញ្ជាតិឆ្នាំ ១៩៣០, "រដ្ឋនីមួយៗត្រូវកំណត់នៅក្នុងច្បាប់របស់ខ្លួនអំពីពលរដ្ឋ ដែលមានសញ្ជាតិរបស់ខ្លួន ។ ច្បាប់នេះត្រូវបានទទួលស្គាល់ដោយរដ្ឋផ្សេងទៀត នៅក្នុងករណីដែលវាមានភាពស៊ីសង្វាក់គ្នាជាមួយអនុសញ្ញាអន្តរជាតិ ទម្លាប់អន្តរជាតិ និងគោលការណ៍នានានៃច្បាប់ដែលមានការទទួលស្គាល់ជាទូទៅទាក់ទងនឹងសញ្ជាតិ ។" |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Nomad | ចរកជន<br>អ្នកដើរត្រាច់ចរពីកន្លែងមួយ<br>ទៅកន្លែងមួយទៀត | N/A | N/A | បុគ្គលដែលគ្មានកន្លែងជាក់លាក់សម្រាប់ការរស់នៅជាប្រក្រតី និងផ្លាស់ទីពីកន្លែងមួយទៅកន្លែងមួយផ្សេងទៀត ដែលក្លាយជាទម្លាប់នៃការផ្លាស់ទីទៅរកកន្លែងផ្សេងៗ។ នៅពេលដែលគោលដៅរបស់ពួកគេពាក់ព័ន្ធនឹងការឆ្លងកាត់ព្រំដែនអន្តរជាតិ ពួកគេក្លាយជាផ្នែកមួយ នៃលំហូរប្រជាពលរដ្ឋជាលក្ខណៈអន្តរជាតិ។ ចរកជនខ្លះអាចជាជនដែលគ្មានរដ្ឋ ដោយសារកង្វះកន្លែងពិតប្រាកដសម្រាប់ការរស់នៅពួកគេអាចមិនបានការទទួលស្គាល់ថា ជាពលរដ្ឋពីសំណាក់ប្រទេសណាមួយ ដែលខ្លួនបានឆ្លងកាត់នោះឡើយ។ |
| Non-admission | ការមិនអនុញ្ញាតឱ្យ<br>ចូលក្នុងប្រទេសមួយ | N/A | N/A | ការបដិសេធមិនឱ្យចូលទៅក្នុងដែនដីនៃរដ្ឋណាមួយ។ |
| Non-degradable rights | សិទ្ធិដែលគេចផុតពី<br>ការរំលោភបំពាន | N/A | N/A | ទោះបីសិទ្ធិមនុស្សភាគច្រើនមិនមែនជាសិទ្ធិដាច់ខាត ហើយការអនុវត្តអាចមានកម្រិតកំណត់ក៏ដោយ សិទ្ធិខ្លះមិនបាត់បង់ឡើយ ពោលគឺពុំមានកំហិត ឬ ការលើកលែងនានានៅក្រោមលក្ខខណ្ឌនានាឡើយ ដែលរួមទាំងប្រការនានាដូចតទៅ : សិទ្ធិក្នុងការរស់នៅ សិទ្ធិរួចផុតពីទារុណកម្ម ឬ អំពើឃោរឃៅអមនុស្សធម៌ ឬ ការបាត់បង់នូវការយកចិត្តទុកដាក់ ឬ ការដាក់ទណ្ឌកម្ម សេរីភាពរួចផុតពីទាសភាព និងសេវភាព សេរីភាពលើការគិតសម្បជញ្ញៈ និងសាសនា។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Non-discrimination | ការមិនរើសអើង | N/A | N/A | ការបដិសេធក្នុងការបង្ហាញនូវភាពខុសគ្នានៃចរិតលក្ខណៈអវិជ្ជមានរបស់មនុស្ស គ្រាន់តែដោយសារពួកគេស្ថិតនៅក្នុងជំពូកណាមួយ ។ ច្បាប់អន្តរជាតិហាមឃាត់ការរើសអើង ឧទាៈ អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយឆ្នាំ ១៩៦៦ ចែងថា : បុគ្គលគ្រប់រូប មានសិទ្ធិស្មើគ្នានៅចំពោះមុខច្បាប់ និងមានសិទ្ធិទទួលបានកិច្ចការពារដោយច្បាប់ ដោយគ្មានការរើសអើងឡើយ ។ ក្នុងន័យនេះ ច្បាប់ត្រូវហាមឃាត់រាល់ការរើសអើង និងធានាឱ្យមានកិច្ចការពារដូចគ្នា និងប្រកបដោយប្រសិទ្ធិភាពដល់ជនគ្រប់រូបទល់នឹងការរើសអើង ដោយសារតែជាតិសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា នយោបាយ ឬទស្សនៈដទៃទៀត សញ្ជាតិដើម ឬ សង្គមពីកំណើត ទ្រព្យសម្បត្តិ ស្ថានភាពនៃកំណើត និងស្ថានភាពដទៃទៀត ។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Non-Governmental Organization (NGO) | អង្គការមិនមែនរដ្ឋាភិបាល<br>អង្គការក្រៅរដ្ឋាភិបាល | N/A | N/A | *អង្គភាពដែលមានការចាត់ចែងមួយ ដែលមានដំណើរការដាច់ដោយឡែកពី និងមិនតំណាងឱ្យរដ្ឋាភិបាល ឬរដ្ឋឡើយ ។ តាមធម្មតា ពាក្យនេះសំដៅលើអង្គការនានាដែលផ្តោតលើបុព្វហេតុនៃមនុស្សធម៌ និងសិទ្ធិមនុស្ស ក្នុងនោះភាគច្រើនអនុវត្តកម្មវិធីរបស់ខ្លួនដែលទាក់ទង នឹងជនរងគ្រោះជំនួយ ក្រោមភាពជាដៃគូជាមួយអ.ស.ប និងទីភ្នាក់ងារដទៃទៀត ។ អង្គការមិនមែនរដ្ឋាភិបាលគឺជាផ្នែកមួយនៃអង្គការសង្គមស៊ីវិល ហើយដែលអាចមានទំនាក់ទំនងការងារជាមួយក្រុមសង្គមផ្សេងទៀត ដូចជាស្ថាប័នរដ្ឋាភិបាល ផ្នែកឯកជន សហគមន៍ អ្នកសិក្សាស្រាវជ្រាវ និងប្រព័ន្ធផ្សព្វផ្សាយជាដើម ។* |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Obscene | អាសអាភាស/អាសគ្រាម | N/A | N/A | ដែលទាក់ទងនឹងភេទនៅក្នុងវិធីមួយដែលគួរឱ្យតក់ស្លុត និងបែបឈ្លានពាន ។ |
| Offender | ជនល្មើស | Offend | Delinquent, wrongdoer, trafficker | បុគ្គលដែលប្រព្រឹត្តអំពើល្មើសច្បាប់ ។ |
| Operational partners | ដៃគូប្រតិបត្តិ | N/A | N/A | ស្ថាប័នរដ្ឋាភិបាល អង្គការអន្តររដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល និងទីភ្នាក់ងារ អ.ស.ប ដែលធ្វើការដើម្បីការពារ និងជួយជនភៀសខ្លួន ឬជនមាតុភូមិនិវត្តន៍ជាដើម ដើម្បីសម្រេចឱ្យបាននូវដំណោះស្រាយសម្រាប់រយៈពេលយូរអង្វែង ។ |
| Organ transplant | ការដូរសរីរាង្គ | N/A | N/A | ជាការផ្ទេរសរីរាង្គពីមនុស្សម្នាក់ទៅម្នាក់ផ្សេងទៀត (ឬពីទីតាំងនៃអ្នកផ្តល់នៅលើរាងកាយរបស់អតិថិជនផ្ទាល់) ក្នុងបំណងជំនួសសរីរាង្គដែលខូចខាត ឬ មិនដំណើរការរបស់អ្នកទទួល ។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Organized crime | ឧក្រិដ្ឋកម្មដែលមានការចាត់តាំង | N/A | N/A | សកម្មភាពល្មើសច្បាប់ព្រហ្មទណ្ឌធ្ងន់ធ្ងរ និងស្មុគស្មាញធ្វើឡើងដោយក្រុមមនុស្ស ដែលមានរចនាសម្ព័ន្ធចាត់ចែងមិនច្បាស់លាស់ ឬ ជាក់លាក់សម្រាប់បង្កើនគុណភាពនៃអ្នកចូលរួម និងដោយមិនគិតអំពីការខូចខាតមកលើសហគមន៍ និងសមាជិករបស់ខ្លួនឡើយ ។ សកម្មភាពនេះ ច្រើនតែធ្វើឡើងតាមរយៈអំពើឃោរឃៅដោយមិនគិតពីច្បាប់ណាមួយ ដែលរួមទាំងបទល្មើសប្រឆាំងមនុស្សជាតិ និងជាញឹកញាប់ទាក់ទងជាមួយអំពើពុករលួយ ។ |
| Overstay | ការស្នាក់នៅហួសរយៈពេលកំណត់ | N/A | N/A | ការបន្តស្នាក់នៅក្នុងប្រទេសមួយហួសកាលកំណត់ ដូចមានចែងក្នុងទិដ្ឋាការ ។ ជួនកាលត្រូវបានប្រើប្រាស់ផងដែរជានាម ឧទាហរណ៍ : "ចំនួនពលរដ្ឋបរទេសដែលគ្មានឯកសារច្បាស់លាស់មានអត្រាស្មើគ្នារវាងអ្នកស្នាក់នៅហួសកាលកំណត់ និងអ្នកដែលចូលដោយល្មើសច្បាប់" ។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Palermo Protocols | ពិធីសារប៉ាឡឺម៉ូ | N/A | N/A | ពិធីសារបំពេញបន្ថែមលើអនុសញ្ញាប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែនដែលមានអង្គការចាត់តាំង (២000): ពិធីសារដើម្បីទប់ស្កាត់ បង្ក្រាប និងដាក់ទណ្ឌកម្មការជួញដូរមនុស្ស ជាពិសេស ស្ត្រី និងកុមារ ពិធីសារប្រឆាំងការរត់ពន្ធជនទេសន្តរប្រវេសន៍តាមផ្លូវគោក សមុទ្រ និង អាកាស, និងពិធីសារប្រឆាំងការផលិត និងការជួញ-ដូរអាវុធ សញ្ញាវុធ និងសម្ភារពាក់ព័ន្ធខុសច្បាប់។ |
| Participatory approach | វិធីសាស្ត្របែបចូលរួម | N/A | N/A | អភិក្រមនៃការអភិវឌ្ឍ និង/ឬ របស់រដ្ឋាភិបាល ដែលក្នុងនោះអ្នកពាក់ព័ន្ធសំខាន់ៗ (និងជាពិសេសអ្នកដែលត្រូវបានគ្រោងថាជាអ្នកទទួលផល) ខាងគោលនយោបាយ ឬ អន្តរាគមន៍មានការពាក់ព័ន្ធជិតស្និទ្ធនៅក្នុងដំណើរការនៃការកំណត់បញ្ហា និងអាទិភាពនានា និងមានអំណាចត្រួតត្រាជាច្រើនលើការវិភាគ និងការកសាងផែនការ ការអនុវត្ត និងការតាមដានលើដំណោះស្រាយ។ |
| Passport | លិខិតឆ្លងដែន | N/A | Travel document, Border Pass | ឯកសារផ្លូវការដែលបញ្ជាក់ពីអត្តសញ្ញាណរបស់បុគ្គលម្នាក់ថាជាពលរដ្ឋស្របច្បាប់ដែលមានលំនៅដ្ឋានអចិន្ត្រៃយ៍នៅក្នុងប្រទេសណាមួយ។ លិខិតឆ្លងដែននេះភាគច្រើនមានរូបរាងជាកូនសៀវភៅតូចមួយចេញដោយអាជ្ញាធរមានសមត្ថកិច្ចរបស់រដ្ឋសម្រាប់កាន់យកតាមខ្លួនពេលបុគ្គលនោះចេញឬចូលក្នុងប្រទេសណាមួយ។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Pedophilia | ការរួមភេទជាមួយកុមារ ឬអំពើប៉ះពាល់ផ្នែកភេទជាមួយកុមារ | N/A | N/A | ភាពច្របូកច្របល់ខាងចិត្តវិទ្យា ដែលក្នុងនោះជនពេញវ័យមួយរូបមានចំណង់ចំណូលចិត្តក្នុងការរួមភេទ ឬធ្វើអំពើផ្សេងៗទៀតទាក់ទងនឹងភេទជាមួយកុមារ ។ |
| Penal Code/Law | ក្រមឬច្បាប់ព្រហ្មទណ្ឌ | N/A | N/A | កម្រងច្បាប់ព្រហ្មទណ្ឌដែលមានកំណត់អំពីបទល្មើសផ្សេងៗ និងការដាក់ទណ្ឌកម្ម ដោយសារតែការមិនគោរពតាមច្បាប់ទាំងនោះ ។ |
| Penalty | ទោស | Penalize | Punishment | ការដាក់ទណ្ឌកម្ម ដោយសារតែការរំលោភច្បាប់ភាពធ្ងន់ធ្ងរនៃទណ្ឌកម្ម អាស្រ័យលើប្រភេទនៃបទល្មើសដែលត្រូវបានប្រព្រឹត្ត និងដូចមានចែងនៅក្នុងច្បាប់ដែលពាក់ព័ន្ធ ។ |
| Permanent residence | ការមានលំនៅអចិន្ត្រៃយ៍ | N/A | N/A | សិទ្ធិដែលរដ្ឋជាម្ចាស់ផ្ទះប្រគល់ទៅឱ្យបុគ្គល ដែលមិនមែនជាជនជាតិរបស់រដ្ឋនោះ ដើម្បីរស់នៅ និងធ្វើការជាអចិន្ត្រៃយ៍ (មិនកំណត់) ។ |
| Permanent settlers | អ្នកតាំងលំនៅអចិន្ត្រៃយ៍ | N/A | N/A | ជនអន្តោប្រវេសន៍ ដែលបានអនុញ្ញាតឱ្យចូលស្របតាមច្បាប់ ដែលត្រូវបានទទួលឱ្យស្នាក់នៅក្នុងប្រទេសនោះ ដែលរួមទាំងបុគ្គលនានាដែលត្រូវបានអនុញ្ញាតឱ្យចូលក្នុងបំណងជួបជុំជាមួយគ្រួសារ ។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Permit | លិខិតអនុញ្ញាត | N/A | License | ឯកសារដែលតាមធម្មតាដែលចេញដោយអាជ្ញាធររដ្ឋាភិបាលដែលអនុញ្ញាតឱ្យវត្ថុនានាមានអត្ថិភាព ឬ បុគ្គលខ្លះអនុវត្តសកម្មភាព ឬសេវាកម្មនានា ។ នៅក្នុងបរិបទនៃទេសន្តរប្រវេសន៍ វាសំដៅលើការអនុញ្ញាតឱ្យស្នាក់នៅ ឬ លិខិតអនុញ្ញាតឱ្យធ្វើការងារ ។ |
| Perpetrator | ចារី | Perpetrate | Criminal, felon, lawbreaker, offender | បុគ្គលម្នាក់ដែលបំពានលើក្រម ឬ ច្បាប់ព្រហ្មទណ្ឌ ឬ ច្បាប់រដ្ឋប្បវេណី ឬ ចូលរួមនៅក្នុងការប្រព្រឹត្តខុសឆ្គងណាមួយ ។ |
| Persecution | ការធ្វើទុក្ខបុកម្នេញ | Persecute | Maltreatment, oppression, torture | នៅក្នុងបរិបទនៃជនភៀសខ្លួន ការគំរាមកំហែងលើជីវិត ឬ សេរីភាព ដោយសារតែជាតិសាសន៍ សាសនា សញ្ជាតិ ទស្សនៈនយោបាយ ឬ សមាជិកនៃក្រុមសង្គមណាមួយជាក់លាក់ ។ |
| Persona non grata | បុគ្គលដែលត្រូវរដ្ឋាភិបាលម្ចាស់ផ្ទះបណ្តេញចេញ ឬ មិនទទួលស្គាល់ | N/A | N/A | "បុគ្គលមិនស្វាគមន៍" ។ បុគ្គលម្នាក់ដែលគេមិនស្វាគមន៍ ឬ មិនចង់ឃើញ ។ នៅក្នុងបរិបទនៃកិច្ចការទូត បុគ្គលម្នាក់ដែលរដ្ឋាភិបាលម្ចាស់ផ្ទះបណ្តេញចេញ ។ |
| Plaintiff | ដើមចោទ<br>ដើមបណ្តឹង | N/A | N/A | ភាគីមួយដែលដាក់ពាក្យបណ្តឹងរដ្ឋប្បវេណីទៅតុលាការ ។ ក្នុងរឿងព្រហ្មទណ្ឌ ដើមបណ្តឹងអាចសំដៅលើជនរងគ្រោះដែលដាក់ពាក្យប្តឹងតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដើម្បីទាមទារឱ្យមានការផ្តន្ទាទោសជនល្មើស និងទទួលបានសំណង ។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Pornography | រូបភាព ឬ សម្ភារអាសអាភាស | N/A | N/A | សម្ភារដែលអាចមើលឃើញនឹងភ្នែក ដូចជារូបថត ខ្សែវីដេអូ រួមទាំងសម្ភារអេឡិចត្រូនិច ដែលពិព័ណ៌នាអំពីកេរភេទ ឬភាពអាសអាភាសប្រហាក់ប្រហែលផ្សេងទៀតដែលធ្វើឱ្យរំភើបឬរំជួលដល់ចំណង់ផ្លូវភេទ (ដូចជាសម្ភារដែលបង្ហាញពីលិង្គ រន្ធយោនី រន្ធគូទ កំប៉េះគូទ ចុងដោះ ឬសកម្មភាពផ្លូវភេទជាដើម) ។ |
| Poverty migrant | ជនចំណាកស្រុកដោយសារតែភាពក្រីក្រ | N/A | N/A | បុគ្គលម្នាក់ ដែលត្រូវបានបង្ខំឱ្យធ្វើចំណាកស្រុក ដោយសារតែភាពចាំបាច់ខាងសេដ្ឋកិច្ច ។ |
| Poverty reduction | ការកាត់បន្ថយភាពក្រីក្រ | N/A | N/A | ជាដំណើរការណាមួយដែលប្រឹងប្រែងកាត់បន្ថយកម្រិតភាពក្រីក្រនៅក្នុងសហគមន៍មួយ ឬ ក្នុងចំណោមមនុស្សមួយក្រុម ឬ ប្រទេសនានា ។ កម្មវិធីកាត់បន្ថយភាពក្រីក្រ អាចផ្ដោតលើភាពក្រីក្រខាងសេដ្ឋកិច្ច និងមិនមែនសេដ្ឋកិច្ច ។ វិធីដែលពេញនិយមខ្លះៗដែលមានប្រើប្រាស់ គឺការអប់រំការអភិវឌ្ឍសេដ្ឋកិច្ច និងការបែងចែកប្រាក់ចំណូលឡើងវិញ ។ កិច្ចប្រឹងប្រែងកាត់បន្ថយភាពក្រីក្រក៏អាចមានគោលដៅកំចាត់ចោលរបាំងខាងសង្គម និងរបាំងច្បាប់ផងដែរ ដើម្បីធ្វើឱ្យមានកំណើនប្រាក់ចំណូលក្នុងចំណោមជនក្រីក្រ ។ នៅក្នុងបរិបទនៃការជួញដូរយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ អាចពាក់ព័ន្ធជាមួយការបណ្ដុះបណ្ដាលជំនាញ ។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Prevention of crime | ការបង្ការឬការទប់ស្កាត់បទល្មើស | Prevent | N/A | *ជាការប៉ុនប៉ងដើម្បីកាត់បន្ថយភាពក្លាយជាជនរងគ្រោះ និងដើម្បីរារាំងឧក្រិដ្ឋកម្ម និងឧក្រិដ្ឋជន។ វាមានការទាក់ទងជាពិសេស ជាមួយកិច្ចប្រឹងប្រែងរបស់រដ្ឋាភិបាល ដើម្បីកាត់បន្ថយឧក្រិដ្ឋកម្ម ពង្រឹងការប្រតិបត្តិច្បាប់ និងរក្សាយុត្តិធម៌ព្រហ្មទណ្ឌ។* |
| Proceedings | ដំណាក់កាលនៃនីតិវិធីតុលាការទម្រង់ការ | Proceed | Court process, series of actions | *ជាដំណាក់កាលតាមលំដាប់លំដោយនៃបណ្តឹងមួយដែលធ្វើឡើងនៅក្នុងប្រព័ន្ធតុលាការ។* |
| Procuring | សញ្ចារកម្ម | Procure | Pimping | *ការកេងយកផលចំណេញខាងហិរញ្ញវត្ថុពីពេស្យាចារលើអ្នកដទៃ។ ការជួយ ឬ ការពារអំពើពេស្យាចារលើអ្នកដទៃ។ ការជ្រើសរើស ការជំរុញ ឬ បណ្តុះបណ្តាលបុគ្គលណាម្នាក់ ក្នុងបំណងឱ្យប្រព្រឹត្តពេស្យាចារ។ ការបម្រើជាអន្តរការីរវាងស្ត្រីពេស្យា និងបុគ្គលណាម្នាក់ដែលធ្វើការកេងប្រវ័ញ្ច ឬ ការទទួលផលពីអំពើពេស្យាចាររបស់អ្នកដទៃ។ ការសម្រួល ឬ ការបិទបាំងធនធានដែលទទួលបានពីសញ្ចារកម្ម។ ការរារាំងអំពើទប់ស្កាត់ជំនួយ និងការអប់រំឡើងវិញ សម្រាប់ជាប្រយោជន៍របស់បុគ្គលនានា ដែលចូលរួមនៅក្នុងពេស្យាចារ ឬ ស្ថិតក្នុងគ្រោះថ្នាក់នៃពេស្យាចារ។ (និយមន័យស្រង់ចេញពីច្បាប់បង្ក្រាបអំពើជួញដូរមនុស្ស របស់ប្រទេសកម្ពុជា ឆ្នាំ ២០០៨)* |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Prohibition of torture | ការហាមឃាត់ការធ្វើទារុណកម្ម | N/A | N/A | ទារុណកម្មត្រូវហាមឃាត់ ដោយឯកសារអន្តរជាតិជាច្រើន ដូចជា សេចក្តីថ្លែងការណ៍ជាសកល អំពីសិទ្ធិមនុស្ស ឆ្នាំ ១៩៤៨។ ទារុណកម្ម គឺជាឧក្រិដ្ឋកម្មអន្តរជាតិ។ កិច្ចការពារទល់នឹងទារុណកម្ម គឺជាកាតព្វកិច្ចរបស់រដ្ឋ និងត្រូវបានគេមើលឃើញថាសិទ្ធិមនុស្សជាមូលដ្ឋាន។ ការហាមឃាត់អំពើទារុណកម្ម ជាទូទៅត្រូវបានមើលឃើញថា បានឈានដល់កម្រិតនៃ juscogens, ពោលគឺ និយាមដាច់ខាតនៃច្បាប់អន្តរជាតិ។ |
| Project-tied worker | ពលករចំណាកស្រុក សម្រាប់រយៈពេលជាក់លាក់នៃគម្រោងណាមួយ | N/A | N/A | ពលករចំណាកស្រុក ដែលរដ្ឋមួយបានអនុញ្ញាតឱ្យធ្វើការសម្រាប់រយៈពេលកំណត់មួយ ដើម្បីធ្វើការនៅក្នុងគម្រោងណាមួយជាក់លាក់ ដែលកំពុងអនុវត្តនៅក្នុងរដ្ឋនោះ ពីសំណាក់និយោជករបស់ជននោះ។ |
| Prosecution | ការចោទប្រកាន់<br>ការផ្តន្ទាទោស | Prosecute | N/A | ដំណើរការនៃនីតិវិធីព្រហ្មទណ្ឌ ដែលក្នុងនោះជនជាប់ចោទត្រូវបានកាត់ឱ្យជាប់ទោស។ |
| Prosecutor | ព្រះរាជអាជ្ញា | Prosecute | N/A | មន្ត្រីដែលធ្វើការនៅស្ថាប័នអយ្យការ ហើយមានតួនាទីចោទប្រកាន់និងបង្ហាញភ័ស្តុតាងនៅចំពោះមុខតុលាការថាជនណាម្នាក់ពិតជាមានពិរុទ្ធពីបទល្មើសព្រហ្មទណ្ឌណាមួយ ដើម្បីការពារសណ្តាប់ធ្នាប់/សន្តិសុខសាធារណៈ និងផលប្រយោជន៍ជាតិ។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សមិសព្ទ | និយមន័យ |
|---|---|---|---|---|
| Prostitution | អំពើពេស្យាចារ | N/A | N/A | ជាអំពើនៃការអនុវត្តសកម្មភាពខាងផ្លូវភេទ ដោយដោះដូរជាមួយប្រាក់ ឬ ទំនិញ។ ស្ថានភាពចំពោះមុខច្បាប់នៃពេស្យាចារមានភាពខុសគ្នាជាខ្លាំងរវាងយុត្តាធិការខុសគ្នា ដោយរាប់ចាប់ពីទោសប្រហារជីវិតដល់ភាពស្របច្បាប់ទាំងស្រុង។ |
| Prostitution of children | អំពើពេស្យាចារកុមារ | N/A | N/A | សំដៅលើអំពើរួមភេទឬអំពើគ្រប់រូបភាពផ្សេងទៀតដែលទាក់ទងនឹងភេទរវាងកុមារជាមួយជនដទៃ ដើម្បីផ្តោះប្តូរទៅនឹងវត្ថុមានតម្លៃអ្វីមួយ។ |
| Protection | ការការពារ<br>កិច្ចគាំពារ | Protect | N/A | គោលគំនិតមួយដែលទាក់ទងនឹងគ្រប់សកម្មភាព ដែលមានគោលដៅទទួលបានការគោរពសិទ្ធិបុគ្គលនោះ ស្របជាមួយគោលការណ៍ និងស្មារតីសិទ្ធិមនុស្ស ជនភៀសខ្លួន និងច្បាប់មនុស្សធម៌អន្តរជាតិ។ កិច្ចការពារទាក់ទងជាមួយការបង្កើតបរិយាកាសដែលមានអំណោយផល ដើម្បីគោរពសិទ្ធិមនុស្ស ការទប់ស្កាត់ និង/ឬ ការកាត់បន្ថយឥទ្ធិពលចំពោះមុខនៃទម្រង់ជាក់លាក់នៃការរំលោភបំពាន និងការស្តារឡើងវិញនូវលក្ខខណ្ឌថ្លៃថ្នូរនៃការរស់នៅតាមរយៈការជួសជុល ការធ្វើឱ្យដូចដើមវិញ និងការស្តារនីតិសម្បទាឡើងវិញ។ នៅក្នុងបរិបទជួញដូរមនុស្ស កិច្ចគាំពារគឺសំដៅលើដំណើរការដែលរាប់ចាប់ពីប្រតិបត្តិការសង្គ្រោះជនរងគ្រោះ, ការផ្តល់សេវាគាំទ្រភ្លាមៗ, ការផ្តល់ជម្រកបណ្តោះអាសន្ន, ការស្វែងរកគ្រួសារ, ការធ្វើមាតុភូមិ-និវត្តន៍, ការស្តារនីតិសម្បទា និង ការធ្វើសមាហរណកម្ម។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Protocol | ពិធីសារ | N/A | N/A | ការបន្ថែមលើអត្ថបទដើមនៃអនុសញ្ញាមួយ ។ វាអាចរាប់បញ្ចូលកិច្ចព្រមព្រៀងបន្ថែម ឬ ពាក់ព័ន្ធជាមួយវិសោធនកម្មលើអត្ថបទដើម ដោយសារតែកាលៈទេសៈថ្មីៗ ឬចំណុចបច្ចេកទេសផ្សេងៗ ។ វាអាចមានលក្ខណៈជានីតិវិធី ឬខ្លឹមសារ សារធាតុ ។ |
| Push-pull factors | កត្តារុញច្រាននិងកត្តាអូសទាញ | N/A | N/A | ទេសន្តរប្រវេសន៍ ច្រើនតែត្រូវបានវិភាគទៅលើ "គំរូរុញច្រាន និងអូសទាញ" ដែលពិនិត្យមើលកត្តារុញច្រាន ដែលជម្រុញប្រជាជនឱ្យចាកចេញពីប្រទេសខ្លួន និងកត្តាអូសទាញ ដែលទាក់ទាញពួកគេទៅប្រទេសថ្មីមួយ ។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Racial discrimination | ការរើសអើងពូជសាសន៍ | N/A | Racial prejudice | អាកប្បកិរិយារើសអើង ឬ រំលោភបំពាន លើសមាជិកនានាដែលមានជាតិសាសន៍ផ្សេង។ ការរើសអើងខាងជាតិសាសន៍ គឺជាការរាប់អាន ការបដិសេធ ការកំហិត ឬ ការយោគយល់ ដោយផ្អែកលើជាតិសាសន៍ ពណ៌សម្បុរ ដើមកំណើត ឬ សញ្ជាតិ ឬ ជនជាតិ ក្នុងបំណង ឬ មានគោលដៅទុកជាមោឃៈ ឬ ធ្វើឱ្យបាត់បង់ការទទួលស្គាល់ ការទទួលបាន ឬ ការអនុវត្ត ដោយផ្អែកលើហេតុផលដូចគ្នា អំពីសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានគ្រឹះនៅក្នុងជីវិត នយោបាយ សេដ្ឋកិច្ច សង្គម វប្បធម៌ ឬ វិស័យផ្សេងទៀតនៃជីវភាពសាធារណៈ។ |
| Racism | ជាតិសាសន៍និយម ឬ ពូជសាសន៍និយម | N/A | Apartheid, bigotry, sectarianism. See also Racial Discrimination | ទម្រង់នៃមនោគមន៍វិជ្ជាដែលចាត់ទុកក្រុមជាតិសាសន៍ និង/ឬ ក្រុមជនជាតិនៅក្នុងតំណែងប្រកបដោយអំណាចខ្ពស់ជាងក្រុមដទៃ ដោយផ្អែកលើលក្ខខណ្ឌរូបវន្ត និងវប្បធម៌ ក៏ដូចជាអំណាចលប់ខាងសេដ្ឋកិច្ច និងអំណាចត្រួតត្រាលើក្រុមដទៃ។ អ្នកជាតិសាសន៍និយមអាចឱ្យនិយមន័យថា ជាលទ្ធិ ឬ ជំនឿលើឧត្តមភាពនៃជាតិសាសន៍។ លទ្ធិនេះរាប់បញ្ចូលជំនឿ ដែលជាតិសាសន៍ គឺជាកត្តាកំណត់អំពីប្រាជ្ញា វប្បធម៌ និងឥរិយាបទខាងសីលធម៌។ ជាតិសាសន៍ និយម រួមមាន ការប្រកាន់ពូជសាសន៍ និងការរើសអើងខាងជាតិសាសន៍។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Rape | បទរំលោភសេពសន្ថវៈ | Rape | N/A | សំដៅលើគ្រប់អំពើបញ្ចូលអង្គជាតិ តាមបែបណាក៏ដោយ ឬ អំពើបញ្ចូលឧបករណ៍ណាមួយទៅក្នុងអង្គជាតិ ដែលប្រព្រឹត្តទៅលើអ្នកដទៃ ទោះបីមានភេទដូចគ្នាឬមិនដូចគ្នាក៏ដោយ ដោយការប្រើហិង្សា ការបង្ខិតបង្ខំ ការគំរាមកំហែង ឬ ដោយការឆ្លៀតឱកាស ។ |
| Ratification | ការផ្តល់សច្ចាប័ន | Ratify | Approval, authorization, confirmation, enactment, sanction. | ការផ្តល់សច្ចាប័ន សំដៅលើ "ការទទួលយក" ឬ "ការអនុម័តឯកភាព" លើសន្ធិសញ្ញាមួយ ។ នៅក្នុងបរិបទអន្តរជាតិ ការផ្តល់សច្ចាប័ន"គឺជាអំពើមានលក្ខណៈអន្តរជាតិ ដែលរដ្ឋមួយសំដែងអំពីការឯកភាពដែលជាប់ជាកាតព្វកិច្ចនៅក្នុងសន្ធិសញ្ញាមួយ" ។ ឧបករណ៍សច្ចាប័ន ដែលបង្ហាញពីការឯកភាពរបស់រដ្ឋត្រូវចូលជាធរមាននៅពេលដែលមានការផ្លាស់ប្តូររវាងរដ្ឋភាគី, ការតំកល់នៅកន្លែងរក្សាទុកឯកសារ ឬការជូនដំណឹងទៅរដ្ឋនានាជាភាគី ឬ ទៅកន្លែងរក្សាទុកឯកសារ ប្រសិនបើមានការឯកភាពគ្នាបែបនោះ ។ នៅក្នុងបរិបទនៃប្រទេសមួយ ពាក្យនេះសំដៅលើដំណើរការមួយ ដែលរដ្ឋមួយបញ្ជាក់ពីជំហររបស់ខ្លួន ដើម្បីបង្ហាញពីការទទួលយកនូវកាតព្វកិច្ចដែលមានចែងនៅក្នុងសន្ធិសញ្ញាអន្តរជាតិមួយ ។ រដ្ឋធម្មនុញ្ញរបស់រដ្ឋមួយចំនួនអាចកំណត់ថាសច្ចាប័នត្រូវធ្វើឡើងតាមរយៈការអនុម័តយល់ព្រមរបស់សភាជាមុន ។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Readmission | ការអនុញ្ញាតឱ្យជនណាម្នាក់ចូលក្នុងប្រទេសមួយសារជាថ្មី | Readmit | N/A | អំពើរបស់រដ្ឋមួយដែលអនុញ្ញាតឱ្យបុគ្គលម្នាក់ (សញ្ជាតិរបស់ខ្លួន សញ្ជាតិនៃប្រទេសទីបី ឬ ជនដែលគ្មានសញ្ជាតិ) ចូលមកក្នុងរដ្ឋរបស់ខ្លួនសារជាថ្មី ក្រោយពីមានការរកឃើញថា ជននោះបានចូល ឬ មានវត្តមានដោយល្មើសច្បាប់នៅក្នុងរដ្ឋមួយផ្សេងទៀត ។ |
| Receiving country | ប្រទេសទទួល | N/A | N/A | ប្រទេសជាទីដៅ ឬ ប្រទេសទីបី ។ នៅក្នុងករណីនៃការវិលត្រឡប់ ឬ មាតុភូមិនិវត្តន៍ នេះក៏ជាប្រទេសប្រភពដើមផងដែរ ។ ប្រទេសដែលឯកភាពទទួលយកប្រចាំឆ្នាំនូវជនភៀសខ្លួន និងជនអន្តោប្រវេសន៍មួយចំនួន តាមរយៈការសម្រេចរបស់ប្រធានាធិបតី នាយករដ្ឋមន្ត្រី ឬ សភា ។ |
| Reconstruction | ការកសាងឡើងវិញ | Reconstruct | N/A | អន្តរាគមន៍អភិវឌ្ឍន៍ ដែលមិនត្រឹមតែប៉ុនប៉ងកសាង ជួសជុលការខូចខាត ឬ វិលត្រឡប់មករកស្ថានភាពដូចមុនវិញ ប៉ុន្តែក៏ដោះស្រាយតម្រូវការសម្រាប់រយៈពេលមធ្យម និងរយៈពេលវែង និងតម្រូវការឱ្យមានកំណែលម្អគោលនយោបាយ កម្មវិធី ប្រព័ន្ធ និងសមត្ថភាពក្នុងការដោះស្រាយវិបត្តិដែលកើតឡើងវិញ និងដើម្បីឈានដល់កម្រិតខ្ពស់ជាងមុននៃការងារ និងបទដ្ឋាននៃការរស់នៅផងដែរ ។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Recovery | ការស្តារ | Recover | N/A | ដំណើរការធ្វើឱ្យជាសះស្បើយពីភាពដែលធ្លាប់រងនូវការប៉ះទង្គិចផ្លូវចិត្ត ឬផ្លូវកាយ ដែលធ្វើឱ្យជនរងគ្រោះគ្មានសមត្ថភាពសម្របខ្លួនជាប្រក្រតីក្នុងមជ្ឈដ្ឋានរបស់ខ្លួន ហើយក៏ជាការបញ្ចូលដំណើរការបង្កើតឡើងនូវសមត្ថភាព ជំនឿទុកចិត្ត ជំនាញ និងអាកប្បកិរិយាចាំបាច់ដើម្បីធ្វើឱ្យជនរងគ្រោះមានសមត្ថភាពប្រក្រតីក្នុងសង្គម ។ សកម្មភាពនៃការស្តាររួមមាន : ការពិគ្រោះយោបល់ បំណិនជីវិត ជំនួយវេជ្ជសាស្ត្រ និងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ជាដើម ។ |
| Recruitment | ការជ្រើសរើសមនុស្ស | Recruit | Selection | នៅក្នុងបរិបទជួញដូរមនុស្ស ការជ្រើសរើសសំដៅលើការបញ្ចុះ-បញ្ចូល ការជួល ឬការឱ្យជនណាមួយបម្រើការក្រោមទម្រង់នៃការកេងប្រវ័ញ្ចផ្សេងទៀត តាមមធ្យោបាយបោកបញ្ឆោត បំពានដោយអំណាច ការបង្ខាំងខ្លួន ការប្រើប្រាស់កម្លាំង ការគំរាមកំហែង ឬ មធ្យោបាយបង្ខិតបង្ខំផ្សេងទៀត ។ |
| Refer | បញ្ជូន | N/A | Transfer, hand over | ផ្ទេរ ឬណែនាំជនរងគ្រោះទៅរកសេវាគាំទ្រណាមួយ ។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Refugee | ជនភៀសខ្លួន | hand over | Displaced person | បុគ្គលម្នាក់ដែលស្ថិតនៅក្រៅប្រទេសនៃសញ្ជាតិរបស់ខ្លួន "ដោយសារតែមានការភ័យខ្លាចជាប់ជាប្រចាំអំពីការធ្វើទុក្ខបុកម្នេញ ខាងជាតិសាសន៍ សាសនា សញ្ជាតិ សមាជិកភាពនៃក្រុមណាមួយក្នុងសង្គម ឬ ទស្សនៈនយោបាយ ឬ ដោយសារតែការភ័យខ្លាចបែបនេះ ជននោះមិនមានឆន្ទៈ ដើម្បីទទួលកិច្ចការពារពីប្រទេសនោះឡើយ ។" |
| Refugee camp | ជំរំជនភៀសខ្លួន | N/A | N/A | ដីមួយកន្លែងដែលត្រូវបានផ្តល់ជាកន្លែងស្នាក់នៅបណ្តោះអាសន្ននៅនៃជនភៀសខ្លួនដែលគេចចេញពីជម្លោះប្រដាប់អាវុធ ។ |
| Refugees Sur Place | មនុស្សដែលក្លាយជាជនភៀសខ្លួនបន្ទាប់ពីចាកចេញពីប្រទេសកំណើតរបស់ខ្លួន | N/A | N/A | បុគ្គលនានាដែលមិនមែនជាជនភៀសខ្លួន នៅពេលដែលពួកគេបានចាកចេញពីប្រទេសដើមរបស់ខ្លួន ប៉ុន្តែបានក្លាយជាជនភៀសខ្លួននៅពេលក្រោយមក ដោយសារតែអន្តរាគមន៍នានា ។ |
| Regular migration | ចំណាកស្រុកដោយស្របច្បាប់ | N/A | N/A | ទេសន្តរប្រវេសន៍ដែលកើតឡើងតាមវិធីដែលមានការទទួលស្គាល់ថាស្របច្បាប់ ។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Rehabilitation | ការស្តារនីតិសម្បទា | Rehabilitate | Recovery | ដំណើការធ្វើឱ្យជាសះស្បើយពីភាពដែលធ្លាប់រងនូវការប៉ះទង្គិចផ្លូវចិត្ត ផ្លូវកាយ ដែលធ្វើឱ្យជនរងគ្រោះគ្មានសមត្ថភាពសម្រប ខ្លួនជាប្រក្រតីក្នុងមជ្ឈដ្ឋានរបស់ខ្លួន ហើយក៏ជាការបញ្ចូល ដំណើរការបង្កើតឡើងនូវសមត្ថភាព ជំនឿទុកចិត្ត ជំនាញ និង អាកប្បកិរិយាចាំបាច់ដើម្បីធ្វើឱ្យជនរងគ្រោះមានសមត្ថភាព ប្រក្រតីក្នុងសង្គម ។ សកម្មភាពនៃការស្តារនីតិសម្បទាមាន ដូចជាការពិគ្រោះយោបល់ ជំនាញបំណិនជីវិត ជំនួយវេជ្ជសាស្ត្រ និងជំនាញវិជ្ជាជីវៈជាដើម ។ |
| Reintegration | ការធ្វើសមាហរណកម្មឡើងវិញ | Reintegrate | N/A | ដំណើការបញ្ជូនត្រឡប់ជនរងគ្រោះទៅរួមរស់ក្នុងគ្រួសារ និង សហគមន៍ដើម ដោយយោងទៅតាមការសម្រេចចិត្តរបស់ជន រងគ្រោះ ។ |
| Relocation | ការផ្លាស់ប្តូរទីកន្លែងរស់នៅ | Relocate | Movement | ជាចលនានៃមនុស្សមួយក្រុមធំ ពីតំបន់មួយទៅតំបន់មួយផ្សេង ទៀត ដោយសារគោលនយោបាយរបស់រដ្ឋ ឬ អាជ្ញាធរ អន្តរជាតិ ដែលជាញឹកញាប់បំផុតបានផ្អែកលើជាតិពន្ធុ ឬ សាសនា ។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Remit | ផ្ញើឬផ្ទេរប្រាក់<br>ផ្ទេរសំណុំរឿង | N/A | Remittance | ផ្ទេរប្រាក់ទៅកាន់កន្លែងមួយទៀត ឬ ឱ្យទៅអ្នកណាម្នាក់។ នៅក្នុងនីតិវិធីតុលាការគឺសំដៅទៅលើការបញ្ជូនសំណុំរឿងទៅតុលាការជាន់ទាបវិញដើម្បីចាត់ការតាមនីតិវិធី។ |
| Remittance | ប្រាក់ចំណូលរបស់អ្នកផ្ញើ<br>ចំណាកស្រុកដែលត្រូវផ្ញើ<br>មកកាន់ប្រទេសកំណើត | Remit | Transfer | ប្រាក់ដែលជនចំណាកស្រុករកបាន ឬ ទទួលបានដែលត្រូវបានបញ្ជូនត្រឡប់មកប្រទេសដើមរបស់ខ្លួនវិញ។ |
| Removal | ការនាំយកចេញ | Remove | Taking away | ការធ្វើឱ្យមនុស្សម្នាក់ផ្លាស់ទីពីទីកន្លែងដែលគេកំពុងរស់នៅទៅកាន់ទីកន្លែងដទៃ ឬ ជាការនាំយកកុមារចេញពីការគ្រប់គ្រងស្របច្បាប់នៃឪពុកម្តាយ អ្នកថែរក្សា ឬអ្នកអាណាព្យាបាល ជាដើម។ |
| Repatriation | ការធ្វើមាតុភូមិនិវត្តន៍ | Repatriate | Return | សិទ្ធិផ្ទាល់ខ្លួនរបស់ជនភៀសខ្លួន ឬអ្នកទោសសង្គ្រាម ឬជនរងគ្រោះដើម្បីវិលត្រឡប់ទៅប្រទេសរបស់ខ្លួនវិញ នៅក្រោមលក្ខខណ្ឌជាក់លាក់ ដែលមានចែងនៅក្នុងបទដ្ឋាន អន្តរជាតិនានា។ បុគ្គលម្នាក់ៗមានសិទ្ធិជ្រើសរើសយកជម្រើសមាតុភូមិនិវត្តន៍។ មាតុភូមិនិវត្តន៍ក៏សំដៅផងដែរលើបេសកជនការទូត និងមន្ត្រីអន្តរជាតិក្នុងពេលមានវិបត្តិអន្តរជាតិ។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Rescue at sea | ការជួយសង្គ្រោះនៅដែនសមុទ្រ | N/A | N/A | ករណីយកិច្ច ដើម្បីសង្គ្រោះអ្នកដែលស្ថិតក្នុងស្ថានភាពគ្រោះអាសន្ននៅសមុទ្រ ត្រូវបានចែងច្បាស់នៅក្នុងសន្ធិសញ្ញា និងច្បាប់អន្តរជាតិដែលកើតចេញពីទំនៀមទម្លាប់។ រដ្ឋមួយដែលជនទទួលការសង្គ្រោះបានមកដល់អាចបដិសេធជននោះមិនឱ្យចុះពីនាវា និងតម្រូវឱ្យនាយនាវាយកពួកគេចេញពីដែនសមត្ថកិច្ចនោះ ឬ អាចចុះពីនាវានោះ ដោយមានលក្ខខណ្ឌនៃការធានាភាពពេញចិត្តក្នុងការតាំងទីលំនៅ ការយកចិត្តទុកដាក់ និងការថែរក្សាដែលត្រូវផ្តល់ដោយរដ្ឋម្ចាស់ទង់នាវា ឬរដ្ឋដទៃទៀត ឬដោយអង្គការអន្តរជាតិ។ |
| Resettlement | ការតាំងទីលំនៅជាថ្មី | Resettle | N/A | ការតាំងលំនៅថ្មី និងការធ្វើសមាហរណកម្មប្រជាពលរដ្ឋ (ជនភៀសខ្លួន ជនចំណាកស្រុកនៅក្នុងប្រទេស ។ល។) ទៅក្នុងតំបន់ភូមិសាស្ត្រ និងបរិស្ថានមួយផ្សេងទៀត ដែលតាមធម្មតាស្ថិតនៅក្នុងប្រទេសទីបី។ ការតាំងទីលំនៅរយៈពេលយូរអង្វែងនៃជនភៀសខ្លួននៅក្នុងប្រទេសមួយក្រៅពីប្រទេសរបស់ជនភៀសខ្លួននោះ។ ជាទូទៅ ពាក្យនេះសំដៅលើផ្នែកមួយ នៃដំណើរការដែលចាប់ផ្តើមដោយការជ្រើសរើសជនភៀសខ្លួនសម្រាប់ការតាំងទីលំនៅ និងដែលបញ្ចប់ដោយការដាក់ជនភៀសខ្លួននៅក្នុងសហគមន៍មួយនៅក្នុងប្រទេសតាំងទីលំនៅ។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Resettlement country | ប្រទេសដែលអនុញ្ញាតឱ្យមានការតាំងទីលំនៅជាថ្មី | N/A | N/A | ប្រទេសមួយដែលផ្ដល់ឱកាសសម្រាប់ការតាំងទីលំនៅអចិន្ត្រៃយ៍ដល់ជនភៀសខ្លួន។ នេះជាប្រទេសមួយក្រៅពីប្រទេសកំណើតរបស់ខ្លួន ឬ ក្រៅពីប្រទេសដែលមានការផ្ដល់ឱ្យជននោះ នូវឋានៈជាជនភៀសខ្លួនកាលពីដំបូង។ |
| Residence | និវេសនដ្ឋាន ឬ ទីសំណាក់ | Reside | N/A | ជាកន្លែងដែលជនណាម្នាក់ពិតជាបានរស់នៅខុសពីលំនៅឋាន។ តាមធម្មតា ទីសំណាក់មានន័យថាត្រឹមតែជាវត្តមានជាក់ស្ដែងក្នុងនាមជាអ្នករស់នៅក្នុងកន្លែងណាមួយ។ តាមធម្មតា ត្រូវមានវត្តមានជាក់ស្ដែងផ្ទាល់ខ្លួន និងក្នុងបំណងយកន្លែងនោះជាផ្ទះសំបែងរបស់ខ្លួន។ដូច្នេះ មនុស្សម្នាក់អាចមានទីសំណាក់ច្រើនជាងមួយនៅក្នុងពេលណាមួយ ប៉ុន្តែមានលំនៅឋានតែមួយទេ។ |
| Return migration | ការត្រឡប់មកប្រទេសកំណើតបន្ទាប់ពីការធ្វើចំណាកស្រុក | N/A | N/A | សំដៅលើបន្លាស់ទីរបស់មនុស្ស ដែលវិលត្រឡប់ទៅប្រទេសដើម ឬ លំនៅឋានរបស់ខ្លួនវិញក្រោយពីចំណាយពេលយ៉ាងហោចណាស់មួយឆ្នាំនៅក្នុងប្រទេសមួយផ្សេងទៀត។ ការត្រឡប់មកប្រទេសកំណើតអាចធ្វើឡើងដោយស្ម័គ្រចិត្ត ឬ ដោយសារការបង្ខំឱ្យចាកចេញ។ |
| Returnee | អ្នកដែលត្រឡប់មកប្រទេសកំណើតវិញ | Return, Returning, Returned | N/A | ជាអ្នកដែលវិលត្រឡប់ដោយស្ម័គ្រចិត្ត ឬ ដោយបង្ខំពីប្រទេសដែលខ្លួនធ្វើអន្តោប្រវេសន៍។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Safe areas | តំបន់មានសុវត្ថិភាព | N/A | Safe zones | ទីកន្លែង តំបន់ ឬ ទីតាំងដែលបានបង្កើតឡើងដើម្បីការពារជនរងគ្រោះនៅក្នុងពេលមានជម្លោះ ។ ពាក្យ និងលក្ខខណ្ឌនៃការបង្កើតទីសុវត្ថិភាព មានចែងនៅក្នុងច្បាប់ស្តីពីជម្លោះប្រដាប់អាវុធ ។ |
| Safe house | ជំរកឬផ្ទះសុវត្ថិភាព | N/A | Refuge, shelter | ទីកន្លែងមួយនៅជិតកន្លែងដើម និងដែលមនុស្សពេញវ័យ ឬ គ្រួសារ ឬ អង្គការសប្បុរស ដែលគួរឱ្យទុកចិត្ត បានឯកភាពផ្តល់កន្លែងសុវត្ថិភាពមួយសម្រាប់ស្ត្រី និងកុមារដើម្បីជ្រកកោណនៅពេលដែលពួកគេមានអារម្មណ៍ថាជីវិតរបស់ពួកគេស្ថិតក្រោមការគំរាមកំហែង ឬ ប្រសិនបើពួកគេបាននិងកំពុងរងការរំលោភបំពាន ឬជាជនរងគ្រោះពីការជួញដូរ ។ |
| Screen | ត្រួតពិនិត្យមើល ឬ ស្វែងរកមើល | N/A | Identify | កំណត់រកនូវសញ្ញាផ្សេងៗដោយផ្អែកលើលក្ខណវិនិច្ឆ័យជាក់-លាក់ ។ |
| Seafarer | កម្មករចំណាកស្រុកដែលធ្វើការនៅលើទូក | N/A | N/A | ពលករចំណាកស្រុកដែលត្រូវគេជួលឱ្យធ្វើការនៅលើនាវាដែលបានចុះបញ្ជីនៅក្នុងរដ្ឋបរទេសណាមួយ (ដែលរួមទាំងជាអ្នកនេសាទផងដែរ) ។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Seasonal workers | កម្មករធ្វើការតាមរដូវកាល | N/A | N/A | *ពលករចំណាកស្រុក ដែលការងាររបស់ពួកគេពឹងផ្អែកលើលក្ខខណ្ឌប្រចាំរដូវ និងអនុវត្តតែនៅក្នុងរដូវខ្លះតែប៉ុណ្ណោះ ( មាត្រា 2(2)(b), អនុសញ្ញាអន្តរជាតិស្តីពីកិច្ចការពារសិទ្ធិពលករ ចំណាកស្រុក និងសមាជិកនៃគ្រួសាររបស់ពួកគេទាំងអស់, ១៩៩០) ។* |
| Secondary migration | ការធ្វើចំណាកស្រុកបន្ត | N/A | N/A | *ការបន្លាស់ទីនៃជនចំណាកស្រុកនៅក្នុងប្រទេសផ្សេងណាមួយ ឆ្ងាយពីសហគមន៍ ដែលជាកន្លែងពួកគេធ្លាប់រស់នៅពីមុនមក ។* |
| Seizure | ការចាប់យក | Seize | Freezing | *សំដៅលើការកាន់កាប់ឬគ្រប់គ្រងជាបណ្តោះអាសន្ន លើទ្រព្យ-សម្បត្តិទាំងឡាយដោយផ្អែកលើដីកា ឬ សេចក្តីសម្រេចចេញដោយតុលាការ ឬអាជ្ញាធរមានសមត្ថកិច្ច ។* |
| Self-articulated needs | តម្រូវការផ្ទាល់ខ្លួន ដែលមានលក្ខណៈជាក់លាក់ និងច្បាស់លាស់ | N/A | N/A | *សំដៅលើតម្រូវការបុគ្គលដែលមានលក្ខណៈពិតប្រាកដ និងឆ្លើយតបទៅនឹងលក្ខខណ្ឌផ្សេងៗ ដែលបុគ្គលនោះចង់បាន ។* |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Self-employed worker | កម្មករចំណាកស្រុកដែលធ្វើការរកកម្រៃដោយខ្លួនឯង | N/A | N/A | ពលករចំណាកស្រុកដែលចូលរួមនៅក្នុងសកម្មភាពផ្ដល់កម្រៃ តែមិនមែននៅក្រោមកិច្ចសន្យាការងារ និងទទួលប្រាក់ចំណូលសម្រាប់ការរស់នៅរបស់ខ្លួនតាមរយៈសកម្មភាពនេះ ដែលជាធម្មតាត្រូវធ្វើការតែឯង ឬជាមួយសមាជិកដទៃទៀតនៅក្នុងគ្រួសាររបស់ខ្លួន និង សំដៅលើពលករចំណាកស្រុកផ្សេងទៀតដែលត្រូវបានទទួលស្គាល់ថា បានធ្វើការរកកម្រៃដោយខ្លួនឯងអនុលោមតាមច្បាប់ដែលនៅជាធរមានរបស់រដ្ឋណាមួយទាក់ទងនឹងកិច្ចព្រមព្រៀងការងារ ឬកិច្ចព្រមព្រៀងទ្វេភាគី ឬពហុភាគី ។ |
| Self-reliance | ការពឹងទៅលើខ្លួនឯង | Self-rely | Self-dependence | សមត្ថភាពរបស់បុគ្គល គ្រួសារ ឬ សហគមន៏ក្នុងការពឹងផ្អែកលើធនធានផ្ទាល់ខ្លួន (កម្លាំងកាយ មូលធនសង្គម និងធនធានធម្មជាតិ) ការវិនិច្ឆ័យ និងសមត្ថភាពដែលត្រូវការឱ្យមានជំនួយពីខាងក្រៅក្នុងកម្រិតអប្បបរមា ក្នុងការបំពេញតម្រូវការជាមូលដ្ឋានរបស់ខ្លួន និងដោយគ្មានពឹងផ្អែកលើសកម្មភាពនានាដែលធ្វើឱ្យបាត់បង់មូលដ្ឋានធនធានរបស់គ្រួសារ ឬ របស់សហគមន៏ដែលមិនអាចស្តារឡើងវិញបាននោះឡើយ ។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Sensitivity | ភាពរសើប<br>ភាពងាយនឹងទទួលឥទ្ធិពល | Sensitize | N/A | សំដៅលើភាពដែលងាយឆ្លើយតបទៅនឹងភ្នោចពីមជ្ឈដ្ឋានខាងក្រៅ ។ |
| Separated children | កុមារដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់អ្នកថែរក្សា | N/A | N/A | កុមារដែលស្ថិតក្រោមការឃុំគ្រងដោយមនុស្សពេញវ័យនៅក្នុងករណីអវត្តមានឪពុកម្តាយ ឬ អាណាព្យាបាលជាធម្មតារបស់ពួកគេ ។ |
| Service provider | អ្នកផ្តល់សេវា<br>ទីភ្នាក់ងារផ្តល់សេវា | N/A | N/A | សំដៅលើបុគ្គល ឬ ស្ថាប័នដែលផ្តល់សេវាគាំទ្រផ្សេងៗដើម្បីជួយថែរក្សា ទំនុកបម្រុង ឬ សម្របសម្រួលការផ្តល់ជំនួយនានាដល់ជនរងគ្រោះ ។ |
| Sex industry | ឧស្សាហកម្មផ្លូវភេទ | N/A | N/A | ផ្នែកមួយក្នុងវិស័យសេដ្ឋកិច្ចដែលក្នុងនោះសកម្មភាពខាងផ្លូវភេទ ការសំដែង និងរូបភាពនានាទាក់ទងផ្លូវភេទ ត្រូវបានធ្វើឡើងដើម្បីរកប្រាក់ចំណូល ។ |
| Sex offender | អ្នកប្រព្រឹត្តបទល្មើសផ្លូវភេទ | N/A | N/A | ជាបុគ្គលដែលរងការចោទប្រកាន់ និងជាប់ចោទពីបទព្រហ្មទណ្ឌ ឬ ដែលបានទទួលថាមានកំហុសដោយសារបទល្មើសទាក់ទងនឹងផ្លូវភេទ ។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Sex service | សេវាបម្រើផ្លូវភេទ | N/A | Sex industry | *សេវាកម្មខាងផ្លូវភេទដែលផ្តល់ទៅឱ្យអតិថិជន ។* |
| Sex tourism | ទេសចរណ៍ផ្លូវភេទ | N/A | N/A | *ការធ្វើដំណើរដែលចាត់ចែងឡើងនៅក្នុងវិស័យទេសចរណ៍ ឬមកពីក្រៅវិស័យនេះ ប៉ុន្តែប្រើប្រាស់រចនាសម្ព័ន្ធ និងបណ្តាញរបស់ខ្លួនក្នុងបំណងជាបឋមនៃការធ្វើឱ្យមានទំនាក់ទំនងខាងផ្លូវភេទជាលក្ខណៈពាណិជ្ជកម្មជាមួយប្រជាជនដែលរស់នៅក្នុងទីដៅទេសចរណ៍នោះ ។* |
| Sex worker | អ្នករកស៊ីផ្លូវភេទ<br>អ្នកប្រកបរបរពេស្យា | N/A | Sex provider, prostitute | *បុគ្គលដែលធ្វើការនៅក្នុងឧស្សាហកម្មខាងផ្លូវភេទ ជាពិសេសបុគ្គលដែលធ្វើពាណិជ្ជកម្មខាងផ្លូវភេទ ។* |
| Sexual abuse/ assault | ការឈ្លានពានខាងផ្លូវភេទ<br>ការបៀតបៀនផ្លូវភេទ | N/A | N/A | *រួមមានដូចជាការប្រើហិង្សាសេពសន្ថវៈ, ការបៀតបៀនកេរ្តិ៍ខ្មាស (ការប្រទូស្តកេរ្តិ៍ខ្មាស), ការធ្វើអាស្រូវភាស (ការបង្ហាញកេរភេទ) ។ (ស្រង់ចេញពីមាត្រា ៧ នៃច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ)* |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Sexual and gender-based violence | អំពើហិង្សាទាក់ទងនឹងផ្លូវភេទ និងយេនឌ័រ | N/A | N/A | អំពើដែលបង្កគ្រោះថ្នាក់ ឬ ការឈឺចាប់ខាងរាងកាយ ប្រាជ្ញាស្មារតី ឬ ខាងផ្លូវភេទ ការគំរាម កំហែងពីអំពើបែបនេះ ការបង្ខិតបង្ខំ និងសកម្មភាពដទៃទៀតដែលបំបាត់សេរីភាព និងដែលផ្តោតលើបុគ្គលនានា ឬ ក្រុមមនុស្សដោយផ្អែកលើភាពខុសគ្នានៃភេទ។ |
| Sexual harassment | ការរុកគួនខាងផ្លូវភេទ | N/A | N/A | គឺជាអំពើដែលបុគ្គលម្នាក់រំលោភអំណាចដែលមុខងាររបស់ខ្លួនប្រគល់ឱ្យធ្វើការគាបសង្កត់ម្តងហើយម្តងទៀតទៅលើអ្នកដទៃក្នុងគោលបំណងទទួលការអនុគ្រោះខាងផ្លូវភេទ។ (ស្រង់ចេញពីមាត្រា ២៥០ នៃក្រមព្រហ្មទណ្ឌ) |
| Sexual Intercourse | ការរួមភេទ ឬ ការរួមសមគ្គសង្វាស | N/A | N/A | ជាអំពើនៃការបង្កើតឱ្យមានការបន្តពូជតាមផ្លូវភេទ រវាងបុរស និងស្ត្រី។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Sexual slavery | ទាសភាពផ្លូវភេទ | N/A | N/A | សំដៅលើការបង្ខិតបង្ខំ ដែលមានការចាត់ចែងមកលើក្រុមមនុស្ស ដែលផ្ទុយពីឆន្ទៈរបស់ខ្លួនឱ្យចូលទៅក្នុងទង្វើនានាខាងផ្លូវភេទ។ ទាសភាពខាងផ្លូវភេទអាចរាប់បញ្ចូលទាសភាពខាងផ្លូវភេទដែលមានម្ចាស់តែម្នាក់ ទាសភាពនៅក្នុងពិធី តាមប្រពៃណីដែលជូនកាលទាក់ទងទៅនឹងទម្លាប់នៅក្នុងប្រពៃណីខាងសាសនា ទាសភាពសម្រាប់គោលបំណងជាបឋមមិនមែនខាងផ្លូវភេទដែលសកម្មភាពខាងផ្លូវភេទជាពេស្យាចារធម្មតា ឬពេស្យាចារដោយបង្ខំ។ |
| Shelter | មណ្ឌល ឬ មជ្ឈមណ្ឌល | N/A | N/A | សំដៅលើទីកន្លែងដែលបង្កើតឡើងស្របច្បាប់ ដើម្បីផ្តល់ការថែទាំ និង សេវាផ្សេងៗ ដល់ អតិថិជន ហើយដែលមានអ្នកគ្រប់គ្រង និងបុគ្គលិកទទួលខុសត្រូវច្បាស់លាស់ដែលមាន ដូចជា មជ្ឈមណ្ឌលជួយជនរងគ្រោះ មជ្ឈមណ្ឌលស្តារនីតិសម្បទា មជ្ឈមណ្ឌលសំចត មជ្ឈមណ្ឌលស្នាក់នៅ រយៈពេលខ្លី-វែង ឬ មជ្ឈមណ្ឌលទទួល ដែលមជ្ឈមណ្ឌលទាំងអស់នេះអាចស្ថិតនៅក្រោមការគ្រប់គ្រងរបស់ស្ថាប័ន រដ្ឋាភិបាល ឬអង្គការមិនមែនរដ្ឋាភិបាល។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Short-term migrant | ជនចំណាកស្រុករយៈពេលខ្លី | N/A | N/A | បុគ្គលដែលចូលទៅក្នុងប្រទេសមួយ ក្រៅពីប្រទេសជាលំនៅឋានប្រក្រតីរបស់ខ្លួនសម្រាប់ការស្នាក់នៅយ៉ាងហោចណាស់រយៈពេលបីខែ ប៉ុន្តែមិនហួសពីមួយឆ្នាំ) លើកលែងតែនៅក្នុងករណីដែលការចូលទៅក្នុងប្រទេសនោះ បានធ្វើឡើងក្នុងបំណងការកំសាន្ត ការសម្រាកកាយ ការទៅលេងមិត្តភក្តិ ឬ សាច់ញាតិ ធ្វើការងារ ឬ ការព្យាបាលជំងឺ ។ សម្រាប់កម្មវត្ថុនៃស្ថិតិ អំពីអន្តោប្រវេសន៍អន្តរជាតិ ប្រទេសដែលជាកន្លែងលំនៅឋានប្រក្រតីសម្រាប់ជនចំណាកស្រុកមួយរយៈខ្លី ត្រូវបានចាត់ទុកថា ជាប្រទេសជាទីដៅ នៅក្នុងអំឡុងពេលពួកគេស្នាក់នៅ ។ |
| Signatory to a convention | ប្រទេសហត្ថលេខីនៃអនុសញ្ញាណាមួយ | N/A | N/A | ប្រទេសដែលគាំទ្រដល់គោលបំណងនៃអនុសញ្ញានេះ ប៉ុន្តែមិនមានការប្តេជ្ញាតាមផ្លូវច្បាប់ ដើម្បីគោរពតាមមាត្រានានានៃអនុសញ្ញានេះឡើយ រហូតដល់ច្បាប់ក្នុងប្រទេសនោះផ្តល់សច្ចាប័នលើអនុសញ្ញានេះជាផ្លូវការ ។ នៅក្នុងករណីដែលការចុះហត្ថលេខាតម្រូវឱ្យមានការផ្តល់សច្ចាប័នការទទួលយកការអនុម័តឯកភាពការចុះហត្ថលេខានោះមិនបង្កើតឱ្យមានការឯកភាពមតិ ដែលត្រូវជាប់កាតព្វកិច្ចឡើយ ។ ទោះជាយ៉ាងណាក៏ដោយ នេះជាមធ្យោបាយក្នុងការបញ្ជាក់ភាពត្រឹមត្រូវ និងការសំដែងឆន្ទៈរបស់រដ្ឋហត្ថលេខីក្នុងការបន្តដំណើរការកសាងសន្ធិសញ្ញានោះ ។ ការចុះហត្ថលេខាគឺជាការបង្ហាញថា រដ្ឋហត្ថលេខីនឹងបន្តទៅផ្តល់សច្ចាប័ន ការទទួលយក ឬ អនុម័តឯកភាព ។ វាក៏បង្កើតឱ្យមានកាតព្វកិច្ចដោយស្មោះត្រង់ផងដែរដើម្បីរារាំងពីអំពើនានា ដែលអាចធ្វើឱ្យខូចកម្មវត្ថុ និងគោលបំណងនៃសន្ធិសញ្ញានោះ ។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Skilled migrant | ជនចំណាកស្រុកដែលមានជំនាញច្បាស់លាស់ | N/A | N/A | ពលករចំណាកស្រុក ដែលដោយសារតែជំនាញរបស់ខ្លួនតាមធម្មតាបានទទួលការអនុគ្រោះខុសៗគ្នា ដែលទាក់ទងនឹងការអនុញ្ញាតឱ្យចូលប្រទេសណាមួយ (អាស្រ័យហេតុនេះពួកគេអាចមានការកំហិតតិចតួច ដែលទាក់ទងនឹងរយៈពេលស្នាក់នៅការផ្លាស់ប្តូរការងារ និងការជួបជុំគ្រួសារ) ។ |
| Slavery | ទាសភាព | N/A | N/A | ស្ថានភាព ឬ លក្ខខណ្ឌរបស់បុគ្គលម្នាក់ដែលមិនមានសិទ្ធិអំណាចទាំងអស់ដែលទាក់ទងនឹងសិទ្ធិក្នុងការធ្វើជាម្ចាស់លើខ្លួនឯង (មាត្រា ១, អនុសញ្ញាស្តីពីទាសភាពឆ្នាំ ១៩២៦ ធ្វើវិសោធនកម្មតាមរយៈពិធីសារ ឆ្នាំ ១៩៥៣) ។ ទាសភាព ត្រូវបានកំណត់ដោយកត្តាមួយនៃភាពជាម្ចាស់ ឬ អំណាចត្រួតត្រាលើខ្សែជីវិតរបស់បុគ្គលម្នាក់ទៀត ការបង្ខិតបង្ខំ និងការដាក់កម្រិតលើបន្ទាស់ទី និងក្នុងលក្ខខណ្ឌដែលបុគ្គលណាម្នាក់មិនមានសេរីភាពក្នុងការចាកចេញ ឬ ក្នុងការផ្លាស់ប្តូរនិយោជក (ដូចជាទាសភាពបម្រើការក្នុងផ្ទះ ការបញ្ចាំខ្លួនដើម្បីដោះបំណុល ភាពជាខ្ញុំកញ្ជះពលកម្មដោយបង្ខំ និងទាសភាពសម្រាប់គោលបំណងខាងប្រពៃណី ឬ សាសនា) ។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Smuggler (of people) | អ្នករត់ពន្ធ (មនុស្ស) | Smuggle | N/A | អន្តរការីដែលបញ្ជូនមនុស្ស ដោយជ្រោមជ្រែងឱ្យឈានដល់កិច្ចសន្យាជាមួយពួកគេ ដើម្បីបញ្ជូនជននោះដោយល្មើសច្បាប់ឆ្លងព្រំដែនរបស់រដ្ឋ ។ |
| Smuggling (of people) | អំពើរត់ពន្ធ (មនុស្ស) | Smuggle | N/A | ការធ្វើលទ្ធកម្ម ដើម្បីបានដោយផ្ទាល់ ឬ ដោយប្រយោលនូវផលប្រយោជន៍ជាប្រាក់ ឬ ជាសម្ភារផ្សេងទៀតពីការចូលដោយល្មើសច្បាប់នូវបុគ្គលណាម្នាក់ទៅក្នុងរដ្ឋភាគីមួយ ដែលបុគ្គលនោះមិនមានសញ្ជាតិនោះ ឬ មិនមានទីសំណាក់អចិន្ត្រៃយ៍នៅទីនោះទេ ។ ការរត់ពន្ធខុសគ្នាពីការជួញដូរ ដោយពុំទាមទារឱ្យមានកត្តានៃការកេងប្រវ័ញ្ច ការបង្ខិតបង្ខំ ឬ ការរំលោភលើសិទ្ធិមនុស្សឡើយ ។ |
| Solicitation | អំពើអូសទាញឬហៅម៉ូយ | Solicit | Ask, call | ជាការទាក់ទង ឬ ចរចាជាមួយជនណាម្នាក់ ដើម្បីផ្ដល់សេវាផ្លូវភេទដោយផ្ដោះប្ដូរនឹងវត្ថុមានតម្លៃអ្វីមួយ ។ |
| Standard of proof | បទដ្ឋានគំរូនៃភស្តុតាង | N/A | N/A | កម្រិត ឬ លំដាប់នៃការផ្ដល់នូវភាពជឿជាក់ពីភស្តុតាងដែលចាំបាច់នៅក្នុងករណីជាក់លាក់ណាមួយ ។ ដូចជា នៅក្នុងបរិបទនៃជនភៀសខ្លួនដែរ "មូលដ្ឋានគ្រប់គ្រាន់" គឺជាបទដ្ឋាននៃបន្ទុកភស្តុតាងនៅពេលប៉ាន់ប្រមាណ អំពីការភ័យខ្លាចពីការធ្វើទុក្ខបុកម្នេញ ។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Standard Operating Procedure (SOP) | វិធីប្រតិបត្តិបទដ្ឋាន | N/A | Standing Operating Procedure | *សេចក្តីណែនាំលម្អិតជាលាយលក្ខណ៍អក្សរធ្វើឡើងដើម្បីសម្រេចឱ្យបាននូវឯកភាពតែមួយក្នុងការបំពេញមុខងារជាក់លាក់ណាមួយ ។ ពាក្យនេះត្រូវបានប្រើប្រាស់ក្នុងបរិបទផ្សេងៗគ្នា ជាច្រើនដូចជាក្នុងវិស័យច្បាប់ ការពារជាតិ សុខាភិបាល និង អប់រំជាដើម ។* |
| Stateless person | ជនដែលគ្មានប្រទេស<br>ជនដែលគ្មានសញ្ជាតិ | N/A | N/A | *បុគ្គលម្នាក់ដែលមិនត្រូវបានចាត់ទុកថា ជាពលរដ្ឋនៅក្នុងរដ្ឋណាមួយ នៅក្រោមច្បាប់របស់រដ្ឋនោះ (មាត្រា ១, អនុសញ្ញា អ.ស.ប ដែលទាក់ទងនឹងស្ថានភាពគ្មានរដ្ឋរបស់បុគ្គលណាម្នាក់ ឆ្នាំ ១៩៥៤) ។ ក្នុងន័យនេះ បុគ្គលដែលគ្មានរដ្ឋច្បាស់លាស់ ខ្វះសិទ្ធិ ដែលជាប់ទាក់ទងនឹងសញ្ជាតិ ពោលគឺ កិច្ចការពារពីរដ្ឋតាមផ្លូវការទូត គ្មានសិទ្ធិបន្តស្នាក់នៅក្នុងរដ្ឋជាទីសំណាក់ និងគ្មានសិទ្ធិក្នុងការវិលត្រលប់មកវិញឡើយ នៅក្នុងករណីគាត់ធ្វើដំណើរ ។* |
| Statelessness | ភាពគ្មានប្រទេស<br>ភាពគ្មានសញ្ជាតិ | N/A | N/A | *លក្ខខណ្ឌដែលមិនអាចបានចាត់ទុកថា ជាសញ្ជាតិណាមួយនៅក្រោមច្បាប់របស់រដ្ឋនានា ។* |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Street children | កុមារតាមចិញ្ចើមថ្នល់ | N/A | N/A | គឺកុមារដែលចូលរួមនៅក្នុងសកម្មភាពសេដ្ឋកិច្ចខ្លះៗ ដែលរាប់ចាប់ពីការសុំទានរហូតដល់លក់របស់របរ ។ កុមារទាំងនោះភាគច្រើនវិលមកផ្ទះនៅចុងនៃថ្ងៃនីមួយៗ និងផ្តល់ប្រាក់ដែលខ្លួនរកបានសម្រាប់គ្រួសារ ។ ពួកគេអាចបានទៅរៀន និងរក្សាភាពជាសមាជិកក្នុងគ្រួសារ ។ ដោយសារតែលក្ខណៈផុយស្រួយនៃសេដ្ឋកិច្ចគ្រួសារ នៅពេលណាមួយកុមារទាំងនេះ អាចជ្រើសយកការរស់នៅជាអចិន្ត្រៃយ៍ដោយពឹងផ្អែកលើចំណូលបែបនេះ ។ កុមារអនាថាអាចជាកុមារដែលរស់តាមចិញ្ចើមថ្នល់ ឬនៅក្រៅបរិយាកាសធម្មតារបស់គ្រួសារ ។ ទំនាក់ទំនងគ្រួសារអាចនៅមានប៉ុន្តែមានលក្ខណៈទន់ខ្សោយ និងអាចកើតមានតែម្តងម្កាល ឬទៅតាមករណីខ្លះតែប៉ុណ្ណោះ ។ |
| Supply | ការផ្គត់ផ្គង់ | Supply | Provide | ការផ្តល់ទំនិញឬសម្ភារទៅតាមតម្រូវការ ឬ ភាពចាំបាច់ ។ នៅក្នុងបរិបទនៃការជួញដូរ ទំនិញត្រូវបានសំដៅលើមនុស្ស ។ |
| Suspect | ជនសង្ស័យ | Suspect | Offender | បុគ្គលដែលត្រូវបានចាត់ទុកថាមានពិរុទ្ធពីបទបទល្មើសណាមួយ ។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Temporary protection | ការការពារបណ្តោះអាសន្ន | N/A | N/A | នីតិវិធីដែលមានលក្ខណៈលើកលែងក្នុងការផ្តល់នូវកិច្ចការពារបន្ទាន់ ឬ បណ្តោះអាសន្នដល់ជននានា នៅក្នុងករណីដែលមានការហូរចូលយ៉ាងច្រើន ឬ ការបង្ហាញពីលក្ខខណ្ឌជិតមានការហូរចូលមនុស្សយ៉ាងច្រើនមកពីប្រទេសទីបី ដែលមិនអាចវិលត្រលប់ទៅប្រទេសដើមរបស់ខ្លួនវិញ ជាពិសេស ប្រសិនបើគេឃើញមានហានិភ័យផងដែរ ដែលប្រព័ន្ធផ្តល់ការជ្រកកោណនឹងមិនអាចត្រួតត្រាការហូរចូលនេះ ដោយគ្មានឥទ្ធិពលអវិជ្ជមានមកលើប្រតិបត្តិការ ដែលមានប្រសិទ្ធិភាពរបស់ខ្លួន ដើម្បីជាប្រយោជន៏នៃជនពាក់ព័ន្ធ និងបុគ្គលដទៃទៀតដែលស្នើសុំកិច្ចការពារ ។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Threat | ការគំរាមកំហែង | Threaten | Menace | សំដៅទៅលើការគំរាមកំហែងជាក់ស្តែងនិងដោយប្រយោលដែលធ្វើឱ្យជនរងគ្រោះភ័យខ្លាចពីការធ្វើបាបរូបកាយឬផ្លូវចិត្ត ឬ ភ័យខ្លាចមានគ្រោះថ្នាក់ផ្សេងទៀតដល់ខ្លួនឬដល់ជនទីបី ។ ករណីនេះមិនចាំបាច់តម្រូវឱ្យជនល្មើសគំរាមជនរងគ្រោះ ឬ បុគ្គលទីបីដោយមានបង្កជារបួសលើរូបរាងកាយនោះទេ ពោលគឺវាមានលក្ខណៈគ្រប់គ្រាន់បង្កើតជា ការគំរាមកំហែងក្នុងករណីដែលជនល្មើសគំរាមថានឹងប្រព្រឹត្តបទឧក្រិដ្ឋឬបទមជ្ឈិមប្រឆាំងនឹងបុគ្គល ។ គេក៏អាចចាត់ទុកជាករណីគំរាមកំហែងផងដែរនៅពេលដែលជនល្មើសគំរាមថានឹងអនុវត្តសកម្មភាព តាមផ្លូវច្បាប់ណាមួយដើម្បីសម្រេចបាននូវការប្រព្រឹត្តអំពើល្មើសរបស់ខ្លួន។ ឧទាហរណ៍ ជនល្មើសឱ្យប្រាក់ទៅជនរងគ្រោះខ្ចីហើយគំរាមជនរងគ្រោះឱ្យបំពេញកាតព្វកិច្ចសងបំណុលដោយជនល្មើសធ្វើនេះក្នុងគោលដៅប្រព្រឹត្តបទល្មើសណាមួយដែលមានចែងក្នុងច្បាប់បង្ក្រាបអំពើជួញដូរមនុស្ស ឬ ជនល្មើសគំរាមប្តឹងទៅអាជ្ញាធរអំពីស្ថានភាពអន្តោប្រវេសន៍ខុសច្បាប់របស់ជនរងគ្រោះ ដោយជនល្មើសប្រើប្រាស់ការគំរាមនេះដើម្បីប្រព្រឹត្តបទល្មើសណាមួយ ដែលមានចែងក្នុងច្បាប់បង្ក្រាបអំពើជួញដូរមនុស្ស ។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Torture | អំពើទារុណកម្ម | Torture | Maltreat | ការធ្វើទុក្ខបុកម្នេញបង្កឱ្យមានការឈឺចុកចាប់ផ្លូវចិត្ត សតិអារម្មណ៍ បញ្ញាស្មារតីដល់រូបវន្តបុគ្គលក្នុងគ្រួសារ ឬ ការធ្វើឱ្យប៉ះទង្គិចលើផ្លូវចិត្ត និងលើរូបកាយដែលប្រព្រឹត្តហួសពីសីលធម៌ និងច្បាប់កំណត់ (មាត្រា ៦ នៃច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ) ។<br>អនុសញ្ញា ស្តីពី ការប្រឆាំងនឹងអំពើទារុណកម្ម និងការប្រព្រឹត្ត ឬការដាក់ទណ្ឌកម្មទាំងឡាយណាដែលមានលក្ខណៈឃោរឃៅ អមនុស្សធម៌ ឬបន្ទាបបន្ថោក បានកំណត់និយមន័យនៅក្នុងមាត្រា ១ ថា "អំពើទារុណកម្មសំដៅលើអំពើទាំងឡាយណា ដែលប្រព្រឹត្តឡើងដោយចេតនាទៅលើបុគ្គលណាម្នាក់ឱ្យទទួលរងរបួស ឬការឈឺចាប់ធ្ងន់ធ្ងរលើរូបរាងកាយឬផ្លូវចិត្ត ក្នុងគោលបំណងទទួលបានព័ត៌មានអំពីបុគ្គលនេះឬបុគ្គលទីបី ឬទទួលបានចម្លើយសារភាពដើម្បីផ្តន្ទាទោសបុគ្គលនេះដោយសារការប្រព្រឹត្តរបស់ខ្លួនឬរបស់បុគ្គលទីបីឬដោយសារការសង្ស័យថាបានប្រព្រឹត្តអំពើទាំងនេះ ឬ ដើម្បីបំភិតបំភ័យ ឬបង្ខិតបង្ខំទៅលើបុគ្គលនេះឬបុគ្គលទីបី ឬ ធ្វើឡើងដោយមូលហេតុផ្សេងៗផ្អែកលើការរើសអើងគ្រប់ប្រភេទ។ ការរងរបួសឬការឈឺចាប់ខាងលើត្រូវប្រព្រឹត្តឡើងដោយផ្ទាល់ ឬ តាមរយៈការញុះញង់ឬការព្រមព្រៀងឬការមិនព្រមចាត់វិធានការទប់ស្កាត់ណាមួយពីសំណាក់មន្ត្រីសាធារណៈ ឬ បុគ្គលណាម្នាក់ដែលបំពេញមុខងារសាធារណៈ" ។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Total migration/ net migration | ចំនួនសរុបនៃការធ្វើអន្តោប្រវេសន៍និងទេសន្តរប្រវេសន៍ ឬផលដករវាងចំនួនអន្តោប្រវេសន៍និងចំនួនទេសន្តរប្រវេសន៍ | N/A | N/A | ចំនួនសរុបនៃទេសន្តរប្រវេសន៍ គឺជាផលបូកចំនួននៃជនអន្តោប្រវេសន៍សរុប ដែលបានមកដល់ ឬ ចូលប្រទេសមួយ និងចំនួនជននិរប្រវេសន៍ ដែលបានចេញ ឬ ចាប់ផ្តើមចេញពីប្រទេសមួយ ហើយវាខុសគ្នាពីទេសន្តរប្រវេសន៍សុទ្ធ ឬ តុល្យភាពនៃទេសន្តរប្រវេសន៍ ដែលជាផលដករវាងចំនួនអ្នកមកដល់ និងអ្នកចេញដំណើរ ។ តុល្យភាពនេះត្រូវបានគេហៅថា អន្តោប្រវេសន៍សុទ្ធ នៅពេលដែលចំនួនអ្នកចាកចេញច្រើនជាងអ្នកមកដល់ ។ |
| Trade unions | សហជីព | N/A | N/A | គឺជាការរួបរួមគ្នានៃកម្មករ ដែលប្រមូលផ្តុំជាមួយគ្នាបង្កើតជាអង្គការវិជ្ជាជីវៈ ដើម្បីសម្រេចគោលដៅរួមនៅក្នុងវិស័យសំខាន់ៗដូចជា ប្រាក់កម្រៃ ម៉ោងធ្វើការ និងលក្ខខណ្ឌការងារ ។ |
| Trafficked child | កុមាររងគ្រោះដោយសារការជួញដូរ | N/A | N/A | គឺជាជនដែលមានអាយុក្រោម ១៨ ឆ្នាំ ហើយដែលត្រូវបានជ្រើសរើស ដឹកជញ្ជូន ផ្ទេរ ផ្តល់កន្លែងលាក់ខ្លួន ឬទទួលយកក្នុងគោលបំណងដើម្បីកេងប្រវ័ញ្ចនៅក្នុងឬក្រៅប្រទេស ។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Trafficker | អ្នកជួញដូរមនុស្ស<br>ជនជួញដូរមនុស្ស | N/A | N/A | ជនជួញដូរមនុស្សគឺជាជនដែលប្រព្រឹត្តបទល្មើសជួញដូរមនុស្ស។ ការិយាល័យនៃឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស បានឱ្យនិយមន័យនៅក្នុងគោលការណ៍និងសេចក្តីណែនាំស្តីពីសិទ្ធិមនុស្សនិងអំពើជួញដូរមនុស្សថា "ជនជួញដូរមនុស្ស សំដៅលើអ្នកជ្រើសរើស អ្នកដឹកជញ្ជូន អ្នកដែលត្រួតត្រាលើជនដែលត្រូវគេជួញដូរ អ្នកដែលផ្ទេរឬរក្សាទុកជនដែលត្រូវគេជួញដូរឱ្យស្ថិតនៅក្នុងស្ថានភាពកេងប្រវ័ញ្ច អ្នកដែលចូលរួមប្រព្រឹត្តបទល្មើសពាក់ព័ន្ធនឹងការជួញដូរមនុស្ស និងអ្នកទាំងឡាយណាដែលកេងយកប្រយោជន៍ដោយផ្ទាល់ក្តីឬមិនផ្ទាល់ក្តីពីអំពើជួញដូរមនុស្ស អំពើរួមផ្សំ និងបទល្មើសពាក់ព័ន្ធ"។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Trafficking in person | ការជួញដូរមនុស្ស | Traffic | Human trafficking | ការជ្រើសរើស ការបញ្ជូន ការផ្ទេរ ការផ្តល់កន្លែងស្នាក់នៅ ឬ ការទទួលយកបុគ្គលនានាតាមរយៈ ការគំរាមកំហែង ឬការប្រើកម្លាំង ឬ ទម្រង់ផ្សេងទៀតនៃការបង្ខិតបង្ខំ ដោយសារការចាប់ពង្រត់ ឬ ការឆបោក ការបញ្ឆោត ការបំពានដោយអំណាច ឬភាពទន់ខ្សោយ ឬ ការផ្តល់ ឬ ការទទួលកម្រៃ ឬ ផលប្រយោជន៍ដើម្បីធ្វើឱ្យមានការឯកភាពពីបុគ្គលណាម្នាក់ ដែលមានអំណាចត្រួតត្រាលើបុគ្គលផ្សេងទៀត ក្នុងគោលបំណងកេងប្រវ័ញ្ច។ និយមន័យ នៅក្នុងពិធីសារ អ.ស.ប ស្តីពីការរត់ពន្ធមនុស្សដែលបំពេញបន្ថែមនៃអនុសញ្ញា ស្តីពី ឧក្រិដ្ឋកម្មឆ្លងដែនដែលមានអង្គការចាត់តាំង ក៏តម្រូវឱ្យមានគោលបំណងពីខាងអ្នកជួញដូរផងដែរ។ ប្រសិនបើបុគ្គលណាម្នាក់រងការរត់ពន្ធ ហើយអ្នករត់ពន្ធមានចេតនាខ្លះៗក្នុងការកេងប្រវ័ញ្ចលើបុគ្គលនោះ ក្នុងករណីនេះមានសញ្ញានៃការជួញដូរហើយ។ ប្រសិនបើអ្នករត់ពន្ធមានបំណងត្រឹមតែជួយបុគ្គលម្នាក់ក្នុងការគេចចេញពីអំណាចត្រួតត្រានៃច្បាប់អន្តោប្រវេសន៍របស់ប្រទេសមួយ ក្នុងករណីនោះពុំមានសញ្ញានៃការជួញដូរឡើយ។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Trajectory | គន្លង ឬ ចំណារ ឬ ដំណើររឿង | N/A | Path, line, course | សំដៅលើគន្លងឬដំណើររឿងដែលជួបប្រទះដោយជនណាម្នាក់។ |
| Transient | កម្មករជំនាញធ្វើការក្នុងរយៈពេលខ្លី | N/A | N/A | កម្មករឯកទេស ឬ កម្មករជំនាញ ដែលផ្លាស់ទីពីប្រទេសមួយទៅប្រទេសមួយផ្សេងទៀត ហើយជាញឹកញាប់ក្នុងនាមជានិយោជិតអន្តរជាតិ និង/ឬចូលរួមនៅក្នុងក្រុមហ៊ុនរក់ស៊ីរួមគ្នា។ ជាអ្នកដែលស្នាក់នៅតែក្នុងរយៈពេលខ្លី។ "ពលករគោចរ"។ |
| Transit | សំចតពេលឆ្លងកាត់ប្រទេសណាមួយ | N/A | N/A | ការឈប់បណ្តោះអាសន្ននៅក្នុងដំណើរមួយក្នុងរយៈពេលខុសៗគ្នានៅក្នុងពេលកំពុងធ្វើដំណើររវាងប្រទេសចំនួនពីរ ឬ ច្រើន ដោយចៃដន្យ ដើម្បីបន្តដំណើររបស់ខ្លួន ឬ ដោយចេតនាក្នុងការប្តូរជើងយន្តហោះ ឬ ចូលរួមនៅក្នុងជើងយន្តហោះដដែល ឬ មធ្យោបាយដឹកជញ្ជូនផ្សេងទៀត។ |
| Transit camp | ទីសំចត | N/A | N/A | កន្លែងមួយ ដែលយ៉ាងហោចណាស់មានសម្ភារសម្រាប់ការស្នាក់នៅពេលយប់ជាកន្លែង ដែលជនភៀសខ្លួនត្រូវបានប្រមូលផ្តុំមុននឹងបញ្ជូនទៅរកកន្លែងតាំងទីលំនៅអចិន្ត្រៃយ៍។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Transit passengers | អ្នកដំណើរដែលធ្វើសំចត រង់ចាំធ្វើដំណើរបន្តទៅប្រទេសទីបី | N/A | N/A | បុគ្គលនានាដែលមកដល់រដ្ឋមួយ ពីប្រទេសផ្សេងទៀតនៅក្នុងពេលឈប់សំចតមុននឹងទៅដល់ទីដៅមួយផ្សេងទៀត (ទីបី) និងនៅទូទាំងអំឡុងពេលសំចតទាំងមូល(រហូតដល់រយៈពេលអតិបរមា ២៤ ម៉ោង គិតពីពេលមកដល់) ឬ នៅតាមកំពង់ផែ ឬ ព្រលានយន្តហោះ កន្លែងដែលមានសន្តិសុខមួយ ឬ នៅក្នុងកន្លែងឃុំគ្រងរបស់នគរបាល ។ |
| Transition | អន្តរកាល | N/A | N/A | រយៈពេលមួយនៅក្នុងវិបត្តិនៅពេលដែលជំនួយការពីខាងក្រៅមានតួនាទីសំខាន់ក្នុងការគាំទ្រ ឬ គូសបញ្ជាក់អំពីបទឈប់បាញ់ ឬ ដំណើរការសន្តិភាពដែលនៅផុយស្រួយនៅឡើយ ដោយជួយបង្កើតលក្ខខណ្ឌនានា ដើម្បីធ្វើឱ្យមានស្ថិរភាពនយោបាយ សន្តិសុខ យុត្តិធម៌ និងសមធម៌សង្គម ។ |
| Transnational crime | ឧក្រិដ្ឋកម្មឆ្លងដែន | N/A | N/A | សំដៅលើឧក្រិដ្ឋកម្មឆ្លងដែនពីប្រទេសមួយទៅប្រទេសមួយទៀត ឬត្រូវបានប្រព្រឹត្តឡើងក្នុងប្រទេសមួយ និងផ្តល់ផលប៉ះពាល់ទៅលើប្រទេសមួយទៀត ។ |
| Transnational marriage | អាពាហ៍ពិពាហ៍ឆ្លងដែន | N/A | N/A | គឺជាអាពាហ៍ពិពាហ៍រវាងមនុស្សមកពីប្រទេសខុសគ្នា ។ បញ្ហាពិសេសដែលមានលក្ខណៈខុសៗគ្នា ដែលកើតឡើងនៅក្នុងអាពាហ៍ពិពាហ៍រវាងមនុស្សមកពីប្រទេសខុសគ្នា ដែលរួមទាំងអ្នកដែលមានសញ្ជាតិ ឬ វប្បធម៌ប្រហាក់ប្រហែលគ្នា ដែលបន្ថែមភាពសាំញ៉ាំ និងការលំបាកនៅក្នុងទំនាក់ទំនងទាំងនេះផងដែរ ។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Transportation | ការដឹកជញ្ជូន | Transport | N/A | ការបញ្ជូនទំនិញ ឬ មនុស្សពីកន្លែងមួយទៅកន្លែងមួយទៀត ដោយមានអ្នកដឹកជញ្ជូន ។ |
| Travel document | ឯកសារធ្វើដំណើរ | N/A | N/A | ពាក្យទូទៅមួយដែលសំដៅលើឯកសារទាំងអស់ ដែលត្រូវបានចាត់ទុកថា ជាភស្តុតាងបញ្ជាក់អំពីអត្តសញ្ញាណក្នុងបំណងនៃការចូលទៅក្នុងប្រទេសណាមួយផ្សេង ។ លិខិតឆ្លងដែន និងទិដ្ឋាការគឺជាទម្រង់ឯកសារដែលត្រូវបានប្រើប្រាស់ជាទូទៅបំផុតសម្រាប់ជាឯកសារធ្វើដំណើរ ។ រដ្ឋខ្លះក៏ទទួលស្គាល់អត្តសញ្ញាណប័ណ្ណ ឬឯកសារផ្សេងទៀតផងដែរ ។ |
| Treaty | សន្ធិសញ្ញា | N/A | N/A | កិច្ចព្រមព្រៀងផ្លូវការមួយ ជាពិសេសរវាងរដ្ឋនានា ដែលបង្កើតឱ្យមានកាតព្វកិច្ចតាមផ្លូវច្បាប់ រវាងភាគីនៅក្នុងកិច្ចព្រមព្រៀងនោះ ។ សន្ធិសញ្ញា គឺជាប្រភពមួយនៃច្បាប់អន្តរជាតិ ។ |
| T-Visa | ទិដ្ឋាការបណ្តោះអាសន្ន | N/A | N/A | ទិដ្ឋាការបណ្តោះអាសន្នមួយ ដែលជនរងគ្រោះពីការជួញដូរអាចដាក់ពាក្យសុំបាន ។ អ្នកកាន់ទិដ្ឋាការបណ្តោះអាសន្នបែបនេះ អាចដាក់ពាក្យសុំសិទ្ធិស្នាក់នៅជាអចិន្ត្រៃយ៍សម្រាប់រយៈពេលបីឆ្នាំ ។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Unaccompanied minors | អនីតិជនដែលធ្វើដំណើរតែម្នាក់ឯង ឬ អនីតិជនគ្មានអ្នកអមដំណើរ | N/A | N/A | *កុមារដែលមិនស្ថិតក្រោមការគ្រប់គ្រងដោយ ឪពុក ម្តាយ អាណាព្យាបាល ឬមនុស្សពេញវ័យផ្សេងទៀត ។ អនិតិជនដែលគ្មានអាណាព្យាបាលប្រឈមនឹងបញ្ហាជាច្រើន សម្រាប់មន្ត្រីត្រួតពិនិត្យតាមច្រកព្រំដែន ដោយសារតែការឃុំឃាំង និង វិធានការដទៃទៀតដែលត្រូវអនុវត្តជាមួយជនបរទេសពេញវ័យដែលគ្មានឯកសារសំគាល់ខ្លួន ហើយដែលអាចមិនមានលក្ខណៈសមស្របសម្រាប់អនីតិជន ។* |
| Undocumented alien | ជនបរទេសដែលឆ្លងដែន ឬ ស្នាក់ក្នុងប្រទេសណាមួយ ដោយពុំមានឯកសារស្របច្បាប់ | N/A | N/A | *ជនបរទេសដែលចូល ឬ ស្នាក់នៅក្នុងប្រទេសមួយ ដោយគ្មានឯកសារសំគាល់ខ្លួនសមស្រប ។ ជនបែបនេះរាប់បញ្ចូល : ក) ជនដែលគ្មានឯកសារស្របច្បាប់សម្រាប់ចូលក្នុងប្រទេសមួយ ប៉ុន្តែព្យាយាមចូលដោយអាថិកំបាំង ខ) ជនដែលចូលក្នុងប្រទេសមួយដោយប្រើប្រាស់ឯកសារក្លែងបន្លំ គ) ជនដែលក្រោយពីបានចូលដោយប្រើប្រាស់ឯកសារស្របច្បាប់ ហើយបានបន្តស្នាក់នៅហួសកាលកំណត់ដែលអនុញ្ញាតឱ្យ ឬ បើពុំនោះទេបានប្រព្រឹត្តរំលោភលើលក្ខខណ្ឌនៃការអនុញ្ញាតឱ្យចូល និងបន្តស្នាក់នៅដោយគ្មានការអនុញ្ញាត ។* |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Undocumented migrant | ជនចំណាកស្រុកដែលមិនមានលិខិតស្នាមត្រឹមត្រូវក្នុងការចូលស្នាក់នៅ ឬ ធ្វើការក្នុងប្រទេសមួយ | N/A | Irregular migrant | *កម្មករចំណាកស្រុក ឬ សមាជិកគ្រួសាររបស់ពួកគេ ដែលពុំបានទទួលការអនុញ្ញាតឱ្យចូលស្នាក់នៅ ឬ បានចូលរួមនៅក្នុងការងារក្រោមស្ថានភាពមិនស្របច្បាប់នៅក្នុងរដ្ឋមួយ ។* |
| Unemployment | ភាពអត់ការងារធ្វើ | N/A | Joblessness | *គឺនៅក្នុងពេលដែលបុគ្គលម្នាក់អាចធ្វើការ និងសព្វថ្ងៃកំពុងស្វែងរកការងារ ប៉ុន្តែបុគ្គលនោះ ពុំមានការងារធ្វើនៅឡើយ ។ តាមធម្មតា វត្តមាននៃភាពគ្មានការងារធ្វើត្រូវបានវាស់ដោយប្រើប្រាស់អត្រាភាពគ្មានការងារធ្វើ ដែលត្រូវបានឱ្យនិយមន័យថាជាភាគរយនៃចំនួនកម្លាំងពលករ ដែលជាអ្នកគ្មានការងារធ្វើ ។* |
| United Nations Convention on the Rights of the Child | អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ | N/A | N/A | *សំដៅលើ CRC ឬ UNCRC, គឺជាអនុសញ្ញាអន្តរជាតិ ដែលកំណត់អំពីសិទ្ធិពលរដ្ឋនយោបាយ និងសិទ្ធិសេដ្ឋកិច្ច និងវប្បធម៌របស់កុមារ ។ ប្រទេសដែលផ្តល់សច្ចាប័នលើអនុសញ្ញាអន្តរជាតិនេះត្រូវជាប់កាតព្វកិច្ចក្រោមអនុសញ្ញាអន្តរជាតិក្នុងការទទួលស្គាល់សិទ្ធិទាំងនេះ ។* |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Uprooted people | ជនដែលត្រូវបង្ខំឱ្យចាកចេញពីលំនៅឋាន | N/A | N/A | អ្នកដែលត្រូវបានបង្ខំឱ្យចាកចេញពីសហគមន៍របស់ខ្លួន អ្នកដែលភៀសខ្លួនចេញដោយសារតែការធ្វើទុកបុកម្នេញ និងសង្គ្រាម អ្នកដែលបានធ្វើចំណាកស្រុក ដោយសារការបង្ខំពីព្រោះតែមហន្តរាយចំពោះបរិស្ថាន និងអ្នកដែលត្រូវបានបង្ខំឱ្យស្វែងរកការទ្រទ្រង់នៅក្នុងទីក្រុងមួយ ឬ នៅក្រៅប្រទេស ដោយសារតែពួកគេមិនអាចរស់នៅបានក្នុងប្រទេស។ |
| Use of force | ការប្រើកម្លាំង | N/A | N/A | សំដៅលើការប្រើប្រាស់កម្លាំងរាងកាយ (កម្លាំងបាយ) ឬ កម្លាំងផ្នែកស្មារតី ដើម្បីប្រឆាំងទៅនឹងឆន្ទៈរបស់ជនរងគ្រោះ។ ការប្រើកម្លាំងនៅក្នុងអំពើជួញដូរមនុស្សមិនចាំបាច់តម្រូវថា ទាល់តែជនល្មើសប្រើប្រាស់ហិង្សា ឬ ជនរងគ្រោះត្រូវទទួលរងរបួសដោយសារការប្រើកម្លាំងនោះទេ។ ឧទាហរណ៍ ករណីជនល្មើសចាប់បុគ្គលណាម្នាក់ ហើយច្រាន ឬ ទាញបុគ្គលនោះ។ ករណីនេះ អាចចាត់ទុកថា ជាការប្រើកម្លាំងទោះបីជាជនរងគ្រោះមិនមានការឈឺចាប់ និងរងរបួសដោយសារអំពើនេះក៏ដោយ។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Vessel | កប៉ាល់<br>នាវាធំៗ | N/A | Water craft, boat | មធ្យោបាយបែបណាមួយសម្រាប់ធ្វើដំណើរនៅលើទឹក ដែលរួមទាំងមធ្យោបាយអចល័ត និងយន្តហោះដែលប្រើប្រាស់ ឬដែលត្រូវបានប្រើប្រាស់ជាមធ្យោបាយសម្រាប់ការដឹកជញ្ជូននៅលើទឹក លើកលែងតែនាវាចំបាំង កងនាវាជំនួយ ឬ នាវាផ្សេងទៀតដែលជារបស់ ឬ ប្រតិបត្តិការ ដោយរដ្ឋាភិបាល និងត្រូវបានប្រើប្រាស់សម្រាប់សេវាកម្មមិនមែនពាណិជ្ជកម្មពីសំណាក់រដ្ឋាភិបាលនៅក្នុងខណៈនេះ ។ |
| Victim<br>(of criminal offense) | ជនរងគ្រោះ<br>(ដោយសារបទល្មើសព្រហ្មទណ្ឌ) | Victimize | N/A | គឺជាជនដែលទទួលការឈឺចាប់ដោយអំពើបំពារបំពាន រួមមានការទទួលរងរបួសទាំងផ្លូវកាយ ឬផ្លូវចិត្ត ការឈឺចាប់ខាងអារម្មណ៍ ការខូចខាតដល់សិទ្ធិជាមូលដ្ឋាន ឬការបាត់បង់នូវសិទ្ធិសេដ្ឋកិច្ចតាមរយៈអំពើ ឬការខកខានមិនបានបំពេញកាតព្វកិច្ចដែលឈានដល់ការ រំលោភច្បាប់ព្រហ្មទណ្ឌ ។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Victim-friendly approach | វិធីសាស្ត្រជនរងគ្រោះមេត្រី<br>វិធីសាស្ត្រអនុគ្រោះដល់ជនរងគ្រោះ<br>វិធីសាស្ត្រដែលផ្ដោតការយកចិត្តទុកដាក់ដល់ជនរងគ្រោះ | N/A | N/A | *វិធីដែលយកជនរងគ្រោះចេញពីដំណើរការនៃការឃាត់ខ្លួន ការឃុំឃាំង ការនិរទេស ឬ ការបណ្ដេញចេញ និងបញ្ជូនពួកគេទៅក្នុងបរិយាកាសមួយក្រោមកិច្ចការពារ និងជំនួយដែលធានាសុវត្ថិភាព និងផ្ដល់ដល់ពួកគេនូវការស្ដារស្ថានភាពឡើងវិញ ។* |
| Victim identification | ការកំណត់អត្តសញ្ញាណជនរងគ្រោះ | N/A | N/A | *សំដៅលើដំណើរការនៃការធ្វើអត្តសញ្ញាណជនរងគ្រោះ ដោយការជួញដូរពីការធ្វើចំណាកស្រុកដោយបង្ខំ ឬកាលៈទេសៈជួញដូរ ឬរត់ពន្ធមនុស្សផ្សេងៗ ។* |
| Victim of human trafficking | ជនរងគ្រោះដោយអំពើជួញដូរមនុស្ស | Victimize | Trafficked person | *គឺជាបុគ្គលទាំងឡាយណាដែលទទួលរងការបំពាន ឬការកេង-ប្រវ័ញ្ចដោយបុគ្គលម្នាក់ទៀត ឬដោយក្រុមមនុស្ស ដោយផ្ទាល់ ឬ ដោយប្រយោលសម្រាប់គោលដៅជួញដូរមនុស្ស ។* |
| Victim services | សេវាជួយដល់ជនរងគ្រោះ | N/A | N/A | *សំដៅលើសេវាកម្មជួយជនរងគ្រោះពីការជួញដូរមនុស្ស ។ សេវាកម្មនេះ អាចរាប់បញ្ចូលការផ្ដល់ទីជម្រក ការផ្ដល់នូវការប្រឹក្សាយោបល់ អភិវឌ្ឍន៍ជំនាញ និងការទប់ស្កាត់ និងសកម្មភាពការពារដទៃទៀតដែលពាក់ព័ន្ធ ។* |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Violence against women | អំពើហិង្សាលើស្ត្រី | N/A | N/A | សកម្មភាពណាមួយនៃអំពើហិង្សាដែលទាក់ទងនឹងភេទខុសគ្នា ដែលនាំឱ្យ ឬ ទំនងជានឹងនាំឱ្យមានគ្រោះថ្នាក់មកលើរាងកាយ ផ្លូវភេទ ឬ ចិត្តសាស្ត្រ ឬ ការឈឺចាប់មកលើស្ត្រី ដែលរួមទាំងការគំរាមកំហែងពីអំពើបែបនោះ ការបង្ខិតបង្ខំ ឬ ការបំបិទសេរីភាពដោយបំពាន បើទោះជាកើតឡើងនៅក្នុងជីវភាពសាធារណៈ ឬ ជីវិតឯកជនក៏ដោយ ។ |
| Visa | ទិដ្ឋាការ | N/A | N/A | ការបញ្ជាក់ដោយមន្ត្រីស្ថានកុងស៊ុល នៅលើលិខិតឆ្លងដែន ឬវិញ្ញាបនប័ត្របញ្ជាក់អត្តសញ្ញាណ ដែលបង្ហាញថានៅក្នុងពេលចេញការបញ្ជាក់នេះ មន្ត្រីនោះជឿថាអ្នកកាន់លិខិតឆ្លងដែននោះ ស្ថិតក្នុងជំពូកជនបរទេសដែលអាចអនុញ្ញាតតាមច្បាប់ដើម្បីចូលក្នុងប្រទេស ។ ទិដ្ឋាការមួយកំណត់អំពីលក្ខណវិនិច្ឆ័យអំពីការអនុញ្ញាតឱ្យចូលទៅក្នុងរដ្ឋណាមួយ ។ បទពិសោធជាអន្តរជាតិកំពុងឈានទៅរកទិដ្ឋាការដែលម៉ាស៊ីន អាចអានបានដែលស្របគ្នាជាមួយបទដ្ឋានរបស់ ICAO (អង្គការអាកាសចរណ៍ស៊ីវិលអន្តរជាតិ) ដែលបោះត្រានៅលើស្លាកសញ្ញាដោយបង្ហាញពីរូបភាពបញ្ជាក់អំពីសន្តិសុខ ។ |
| Voluntary migration | ចំណាកស្រុកដោយស្ម័គ្រចិត្ត | N/A | N/A | បន្លាស់ទីដោយចេតនានៃបុគ្គលម្នាក់ពីកន្លែងមួយទៅកន្លែងមួយផ្សេងទៀត ។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Voluntary repatriation | ការធ្វើមាតុភូមិនិវត្តន៍ដោយស្ម័គ្រចិត្ត | N/A | N/A | ការវិលត្រឡប់នៃបុគ្គលម្នាក់ទៅប្រទេសដើមវិញ ដោយសារតែសេរីភាពក្នុងការសំដែងមតិឆន្ទៈវិលត្រឡប់ដោយខ្លួនឯង។ |
| Voluntary return | ការវិលត្រឡប់មកប្រទេសដើមវិញដោយស្ម័គ្រចិត្ត | N/A | N/A | ការវិលត្រលប់ក្រោមជំនួយ ឬ ដោយខ្លួនឯងទៅកាន់ប្រទេសដើមវិញប្រទេសសំចត ឬ ទៅប្រទេសទីបី ដោយផ្អែកលើសេរីភាពក្នុងការជ្រើសរើសដើម្បីវិលត្រឡប់។ |
| Vulnerable | ដែលងាយរងគ្រោះ | N/A | N/A | ភាពទន់ខ្សោយនៃបុគ្គលម្នាក់ខាងរាងកាយ ប្រាជ្ញា ឬ សង្គម ដោយមិនអាចបំពេញតម្រូវការចាំបាច់ជាមូលដ្ឋានរបស់ខ្លួន ហើយក្នុងន័យនេះ ត្រូវការឱ្យមានជំនួយជាក់លាក់។ |
| Vulnerable group | ក្រុមដែលងាយរងគ្រោះ | N/A | N/A | ក្រុម ឬ វិស័យណាមួយនៅក្នុងសង្គម ដែលប្រឈមមហានិភ័យខ្ពស់ក្នុងការស្ថិតក្រោមអំពើរើសអើង អំពើហិង្សា គ្រោះមហន្តរាយធម្មជាតិ ឬ គ្រោះមហន្តរាយខាងបរិស្ថាន ឬ ការលំបាកខាងសេដ្ឋកិច្ចជាងក្រុមដទៃទៀតនៅក្នុងរដ្ឋនោះ។<br>ក្រុមណាមួយ ឬ វិស័យណាមួយក្នុងសង្គម (ដូចជា ស្ត្រី កុមារ និងមនុស្សចាស់) ដែលប្រឈមមហានិភ័យខ្ពស់នៅក្នុងពេលមានជម្លោះ ឬវិបត្តិ។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Waiver | ការលះបង់ដោយស្ម័គ្រចិត្ត (ជាពិសេសសិទ្ធិ) | N/A | Relinquishment, abandonment | ការលះបង់ ឬ ការបោះបង់ចោលដោយស្ម័គ្រចិត្ត (ការសំដែង ឬ បង្ហាញន័យច្បាស់លាស់) នូវសិទ្ធិស្របច្បាប់ ឬ ផលប្រយោជន៍។ |
| Well-being | សុខុមាលភាព | N/A | Welfare, comfort | សំដៅលើការមានសេចក្តីសុខ សុខភាពល្អ និងសុវត្ថិភាព។ |
| Witness | សាក្សី | Witness | N/A | អ្នកដែលមានចំណេះដឹងផ្ទាល់ខ្លួនអំពីព្រឹត្តិការណ៍ជាក់លាក់ ឬ ស្ថានភាពខ្លះ ដោយសារតែបទពិសោធផ្ទាល់ខ្លួន។ នៅក្នុងបរិបទខាងផ្នែកច្បាប់ បុគ្គលម្នាក់ដែលមានចំណេះដឹងបែបនេះដែលមានគុណវុឌ្ឍិស្របច្បាប់ ដើម្បីបង្ហាញអំពីចំណេះដឹងនេះនៅក្នុងតុលាការ។ ក្នុងផ្នែកកិច្ចសន្យា សាក្សីសំដៅលើភាគីទីបីដែលជាអ្នកសង្កេតមើលលើការព្រមព្រៀងរបស់ភាគីទាំងពីរនៃកិច្ចសន្យា។ |
| Work permit | លិខិតអនុញ្ញាតឱ្យធ្វើការងារ | N/A | N/A | ឯកសារច្បាប់មួយដែលផ្តល់ការអនុញ្ញាតដែលចាំបាច់ ដើម្បីអាចឱ្យពលករចំណាកស្រុកធ្វើការបាន។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Worst forms of child labor | ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ | N/A | N/A | គ្រប់ទម្រង់នៃទាសភាព ឬការប្រព្រឹត្តដែលដូចគ្នានឹងទាសភាព (ដូចជា ការលក់ និងការជួញដូរកុមារ ការលក់ខ្លួនដើម្បីដោះបំណុល និងការងារដោយបង្ខំ ឬជាប់កាតព្វកិច្ចដែលរួមទាំងការកេណ្ឌកុមារដោយបង្ខំ ឬដែលជាប់កាតព្វកិច្ចសម្រាប់ប្រើប្រាស់នៅក្នុងជម្លោះប្រដាប់អាវុធ) ការប្រើប្រាស់កុមារក្នុងសញ្ញារកម្ម ឬការផ្តល់កុមារសម្រាប់បម្រើក្នុងពេស្យាចារ ដើម្បីផលិតរូបភាពអាសអាភាស ឬសម្រាប់ការសំដែងទិដ្ឋភាព អាសអាភាស ការប្រើប្រាស់ ការធ្វើលទ្ធកម្ម ឬ ការផ្តល់កុមារ សម្រាប់សកម្មភាពល្មើសច្បាប់ ជាពិសេស សម្រាប់ការផលិត និងការជួញដូរគ្រឿងញៀន ដូចមានចែងនៅក្នុងសន្ធិសញ្ញា អន្តរជាតិដែលពាក់ព័ន្ធ ឬកិច្ចការដទៃផ្សេងទៀត ដែលតាមលក្ខណៈ ឬកាលៈទេសៈរបស់វា កិច្ចការនោះអាចទំនងជាបង្កគ្រោះថ្នាក់ចំពោះសុខភាព សុវត្ថិភាព និង សីលធម៌របស់កុមារ ។ |

# សទ្ទានុក្រម ចិត្តវិទ្យា

# GLOSSARY ON PSYCHOLOGY



| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Acute stress | ការតានតឹងចិត្តស្រួចស្រាវ | N/A | N/A | គឺជាអារម្មណ៍រំជើបរំជួលក្នុងមួយរយៈពេល ហើយវាមានលំនាំកើតមានឡើងនិងបាត់ទៅវិញក្នុងលក្ខណៈច្បាស់លាស់ ។ |
| Addiction | ការញៀន | N/A | N/A | គឺជាស្ថានភាពមួយដែលបុគ្គលម្នាក់ត្រូវការគ្រឿងញៀនដើម្បីការពារខ្លួនគាត់កុំឱ្យមានប្រតិកម្មផ្លូវកាយ និងផ្លូវចិត្ត នៅពេលដែលគាត់មិនបានប្រើប្រាស់វា ។ ការញៀនគឺជាសញ្ញាណនៃការពឹងផ្អែកលើគ្រឿងញៀន ។ |
| Aggression | អាកប្បកិរិយាបំពារបំពាន | N/A | N/A | គឺជាអាកប្បកិរិយាដែលអាចបង្កជារបួសផ្លូវចិត្ត ឬ ផ្លូវកាយទៅលើបុគ្គលផ្សេងទៀត ។ |
| Agoraphobia | ជំងឺខ្លាចទីសាធារណៈ ឬ ទីវាលធំទូលាយ | N/A | N/A | គឺជាការខ្លាចនៅពេលដែលកំពុងនៅទីសាធារណៈ ឬទីវាលដែលពិបាកនឹងគេចចេញ ឬដែលនឹងអាចនាំឱ្យអាម៉ាស់មុខ ។ |
| Amnesia | បញ្ហាភ្លេចភ្លាំង | N/A | N/A | គឺជាការបាត់បង់ការចងចាំ ដែលបណ្តាលមកពីរបួសផ្លូវកាយ ជំងឺផ្សេងៗ ការប្រើប្រាស់គ្រឿងញៀន ឬ ការប៉ះទង្គិចផ្លូវចិត្ត ។ |
| Anxiety | ការថប់បារម្ភ | N/A | N/A | គឺជាប្រតិកម្មអារម្មណ៍ ដែលបណ្តាលមកពីការទទួលដឹងជាមុនថាមានទំនាស់កើតមានឡើង ហើយដែលវាទំនងជានឹងត្រូវបានដឹង ។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Attachment | ការជំពាក់ចិត្ត | N/A | N/A | ជាអារម្មណ៍ភ្ជាប់គ្នារវាងកូន និងអាណាព្យាបាលដែលមើលថែគេជាប្រចាំ ។ |
| Attention | បម្រុងប្រយ័ត្ន | N/A | N/A | ការផ្តោតការរព្ធកដឹងលើព័ត៌មានណាមួយ ។ |
| Attitude | ឥរិយាបថ | N/A | N/A | គឺជាបែបបទដែលបានរៀន ហើយមានភាពស្ថិតស្ថេរមិនប្រតិកម្មទៅនឹងមនុស្ស ទស្សនៈ និងព្រឹត្តិការណ៍តាមការវាយតម្លៃ ។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Behavior | អាកប្បកិរិយា | N/A | N/A | គឺជាសកម្មភាពដែលអង្គសរីរាង្គមានជីវិតមួយ ដែលបត់បែនទៅតាមមជ្ឈដ្ឋានរស់នៅរបស់ខ្លួន។ |
| Behavior modification | កំណែប្រែអាកប្បកិរិយា | N/A | N/A | គឺជាប្រព័ន្ធគោលការណ៍នៃការរៀនសូត្រដែលបានប្រើ ដើម្បីបង្កើននូវអាកប្បកិរិយាដែលចង់បាន និង/កាត់បន្ថយនូវអាកប្បកិរិយាដែលមានបញ្ហា។ |
| Bipolar disorder | ជំងឺបាយប៉ូឡា | N/A | N/A | គឺជាជំងឺផ្លូវអារម្មណ៍ ដែលធ្វើឱ្យអារម្មណ៍មានការផ្លាស់ប្តូរឆ្លាស់គ្នារវាងអារម្មណ៍ ធ្លាក់ទឹកចិត្ត និងសប្បាយរីករាយជ្រុលដោយមិនមានមូលហេតុច្បាស់លាស់ (mania)។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Catharsis | ការជម្រះចិត្ត | N/A | N/A | គឺជាការបញ្ចេញនូវអារម្មណ៍ដែលមានខ្លាំង ប៉ុន្តែជាការទប់មិនឱ្យមានការរំជួលចិត្ត ។ |
| Clinical psychologist | ចិត្តវិទូផ្នែកព្យាបាលជំងឺផ្លូវចិត្ត | N/A | N/A | គឺជាបុគ្គលដែលមានសញ្ញាប័ត្របណ្ឌិតផ្នែកចិត្តវិទ្យា ហើយដែលបានទទួលការបណ្តុះបណ្តាលអំពីរបៀបធ្វើការប៉ាន់ប្រមាណ និងព្យាបាលបញ្ហាផ្លូវចិត្ត ។ |
| Clinical social worker | បុគ្គលិកសង្គមកិច្ច<br>ផ្នែកព្យាបាលជំងឺផ្លូវចិត្ត | N/A | N/A | គឺជាអ្នកវិជ្ជាជីវៈសុខភាពផ្លូវចិត្ត ដែលទទួលបានការបណ្តុះបណ្តាលជំនាញជាពិសេសមួយដោយផ្តោតលើបរិបទសង្គមនៃបញ្ហារបស់មនុស្ស ។ |
| Cognition | ពុទ្ធិ | N/A | N/A | គឺជាដំណើរការនៃការយល់ដឹងរួមមាន ការចូលរួម ការនឹកឃើញឡើងវិញ និងភាពសមហេតុផលរួមទាំងអត្ថន័យនៃដំណើរការ ដូចជាទស្សនាទាន និងលំនឹក ។ |
| Cognitive behavior modification | វិធីសាស្ត្រកែតម្រូវ<br>អាកប្បកិរិយា និងពុទ្ធិ | N/A | N/A | គឺជាវិធីសាស្ត្រព្យាបាលមួយ ដែលបានដាក់បញ្ចូលពុទ្ធិដែលផ្តោតទៅលើការគិតជាមួយនឹងអត្តចរិតដែលមានឥទ្ធិពលទៅដល់ទឹកចិត្ត និងប្រតិកម្មជាមួយឥរិយាបថ ដោយផ្តោតលើការផ្លាស់ប្តូរការប្រព្រឹត្តតាមរយៈការកែតម្រូវការពង្រឹងកត្តាដែលជាប់ពាក់ព័ន្ធ ។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សមសព្ទ | និយមន័យ |
|---|---|---|---|---|
| Cognitive development | ការវិវត្តន៍នៃពុទ្ធិ | N/A | N/A | គឺជាដំណើរនៃការវិវត្តន៍នៃការដឹងរួមមាន : ការស្រមើស្រមៃ ប្រក្បក្សារម្មណ៍ ភាពសមហេតុផល និងការដោះស្រាយបញ្ហា ។ |
| Cognitive dissonance | ការមិនចុះសម្រុងគ្នានៃពុទ្ធិ | N/A | N/A | វាជាទ្រឹស្ដី ដែលភាពតានតឹងបង្កើតឱ្យមានផលមិនចុះសម្រុងគ្នានៃពុទ្ធិ ។ |
| Cognitive therapy | ការព្យាបាលតាមបែបពុទ្ធិ | N/A | N/A | គឺជាវិធីសាស្ត្រក្នុងការព្យាបាលផ្លូវចិត្តមួយ ដែលមានគោលបំណងផ្លាស់ប្ដូរអារម្មណ៍ និងអាកប្បកិរិយា ដោយការផ្លាស់ប្ដូររបៀបដែលអតិថិជនគិត ឬយល់ឃើញអំពីបទពិសោធន៍សំខាន់ៗក្នុងជីវិតរបស់ពួកគេ ។ |
| Comorbidity | ជំងឺពីរ ឬ ច្រើនរួមគ្នា | N/A | N/A | គឺជាបទពិសោធន៍មួយដែលកើតមានជំងឺច្រើនលើសពីមួយក្នុងពេលដំណាលគ្នា ។ |
| Compliance | ការប្រព្រឹត្តតាម | N/A | N/A | គឺជាការផ្លាស់ប្ដូរអាកប្បកិរិយាឱ្យទៅតាមការស្នើសុំរបស់ដៃគូពិភាក្សា ។ |
| Contingency management | ការគ្រប់គ្រងតាមបែបព្រមព្រៀង | N/A | N/A | គឺជាវិធីសាស្ត្រនៃការព្យាបាលមួយដែលបានផ្លាស់ប្ដូរអាកប្បកិរិយា ដោយការកែតម្រូវផលវិបាករបស់វា ។ |
| Coping | វិធីសាស្ត្រដោះស្រាយ | N/A | N/A | គឺជាដំណើរការនៃការដោះស្រាយជាមួយនឹងតំរូវការផ្ទៃកខាងក្នុង ឬ ខាងក្រៅ ដែលត្រូវបានយល់ឃើញថា កំពុងតែបានគំរាមគំហែង ឬ សន្ទប់ខ្លាំង ។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Delusions | ការភាន់គំនិត | N/A | N/A | ការដែលនៅតែមានជំនឿមិនត្រឹមត្រូវ ឬ មិនសមហេតុផល ទោះបីជាមានភ័ស្ដុតាងច្បាស់លាស់ដើម្បីជំទាស់ក៏ដោយ ។ |
| Dissociative amnesia | ការភ្លេចភ្លាំងដុំៗ | N/A | N/A | គឺជាអសមត្ថភាពក្នុងការចងចាំនូវបទពិសោធផ្ទាល់ខ្លួនសំខាន់ៗ ដោយមិនរាប់បញ្ចូលការមិនអាចបំពេញមុខងារផ្សេងៗរបស់ផ្នែកនៃសរីរាង្គកាយ ។ |
| Dissociative disorder | ជំងឺបំណែងចែក បុគ្គលិកលក្ខណៈ | N/A | N/A | គឺជាជំងឺបុគ្គលិកលក្ខណៈមួយដែលកត់សម្គាល់តាមរយៈបុគ្គលមានការរំខានក្នុងការដាក់បញ្ចូលគ្នានូវអត្តសញ្ញាណលំនឹក ឬ ញាណ ។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Emotion | ការរំជួលចិត្ត | N/A | N/A | គឺជាលំនាំនៃការផ្លាស់ប្តូរដ៏ស្មុគស្មាញមួយ រួមមានការរំជើបរំជួលផ្នែករាងកាយ អារម្មណ៍ ដំណើរការពុទ្ធិ និង ប្រតិកម្មរបស់អាកប្បកិរិយា ហើយដែលកើតមានដើម្បីឆ្លើយតបទៅនឹងស្ថានភាព ដែលបុគ្គលនោះយល់ឃើញថាមានសារៈសំខាន់ចំពោះគាត់ ។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Fear | ការភ័យខ្លាច | N/A | N/A | គឺជាប្រតិកម្មសមហេតុផលមួយ ទៅនឹងកត្តាគ្រោះថ្នាក់នៅខាងក្រៅខ្លួនមនុស្ស ដែលភ្ញោចឱ្យបុគ្គលគេចចេញ ឬ ប្រឆាំងតបតវិញដើម្បីការពារខ្លួន ។ |
| Fight-or-flight response | ប្រតិកម្មដោយការប្រឆាំងតបត ឬ រត់គេចចេញ | N/A | N/A | គឺជាសកម្មភាពបន្តបន្ទាប់គ្នា ដែលភ្ញោចឡើងនៅពេល ដែលអង្គសរីរាង្គមានជីវិតមួយបានជួបប្រទេះនឹងការគំរាមគំហែង ហើយត្រៀមខ្លួន ដើម្បីប្រឆាំង និងតស៊ូ ឬ ដើម្បីគេចចេញទៅរកទីសុវត្ថិភាព ។ តាមការស្រាវជ្រាវពេលថ្មីៗបានបង្ហាញថាប្រតិកម្មនេះ គឺជាប្រតិកម្មតែរបស់ភេទឈ្មោលតែប៉ុណ្ណោះ ។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Generalized anxiety disorder | ជំងឺថប់បារម្ភទូទៅ | N/A | N/A | គឺជាប្រភេទជំងឺថប់បារម្ភមួយ ដែលបុគ្គលមានអារម្មណ៍ថប់ៗ និងព្រួយបារម្ភស្ទើរគ្រប់ពេល យ៉ាងហោចណាស់ នៅក្នុងកំឡុងរយៈពេល ៦ ខែ ពេលណាមិនត្រូវបានគំរាមគំហែងពីអ្វីមួយជាក់លាក់ ដែលជាការគ្រោះថ្នាក់ចំពោះគាត់ ។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Hallucinations | មមាល | N/A | N/A | គឺជាប្រក្រត្យារម្មណ៍មិនពិត ដែលកើតឡើងដោយមិនមានកត្តាភ្ញោច។ ការមមាលបែបនេះដោយឮសំឡេង ប៉ុន្តែក៏អាចឃើញជារូបភាព មានអារម្មណ៍ ឬជាការធុំក្លិនផងដែរ។ អ្នកជំងឺយល់ឃើញដូចជាការពិតណាស់ ប៉ុន្តែវាមិនមែនជាការពិតដែលបានកើតឡើងទេ។ |
| Hormones | អ័រម៉ូន | N/A | N/A | គឺជាធាតុដែលនាំសារធាតុគីមី ដែលត្រូវបានផលិត និង បញ្ចេញដោយក្រពេញអង់ដូគ្រីន ដែលបង្កើតជាមេតាប៉ូលីស និងមានឥទ្ធិពលដល់ការរីកលូតលាស់សរីរាង្គ អារម្មណ៍ និង ផ្លូវភេទ ។ |
| Hypnosis | ការសណ្ដំ | N/A | N/A | គឺជាសភាពនៃការរឭកដឹងត្រូវបានផ្លាស់ប្ដូរ ដែលត្រូវបានកត់សម្គាល់តាមរយៈចិត្តកាយមានការសម្រាក ងាយនឹងធ្វើតាមការណែនាំ និងផ្លាស់ប្ដូរប្រក្រត្យារម្មណ៍លំនឹក។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Job burnout | ការនឿយណាយនឹងការងារ | N/A | N/A | គឺជាបណ្តុំនៃរោគសញ្ញានឿយហត់អារម្មណ៍ ការប៉ះពាល់ទៅដល់បុគ្គលិកលក្ខណៈ និងសមិទ្ធិផលការងារផ្ទាល់ខ្លួនថយចុះ ដែលទាំងអស់នេះកើតមានចំពោះបុគ្គលិកទាំងឡាយណាដែលធ្វើការក្នុងតួនាទីប្រឈមនឹងភាពតានតឹងខ្ពស់ ។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Major depressive disorder | ជំងឺធ្លាក់ទឹកចិត្តធ្ងន់ធ្ងរ | N/A | N/A | គឺជាជំងឺផ្លូវអារម្មណ៍ ដែលកំណត់ដោយអារម្មណ៍ធ្លាក់ទឹកចិត្តខ្លាំងក្នុងរយៈពេលមួយរយៈ ដោយពុំមានការកើនឡើងខ្ពស់នៃជំងឺម៉ែនៀនៃជំងឺធ្លាក់ទឹកចិត្តបាយប៉ូឡា ។ |
| Mania | ការរីករាយជ្រុល | N/A | N/A | គឺផ្ទុយទៅនឹងធ្លាក់ទឹកចិត្ត ។ អ្នកដែលមានម៉ានៀអាចនឹងមានទំនុកចិត្តច្រើនជ្រុល និងមានកំលាំងថាមពលខ្លាំង ។ ពួកគេអាចនិងនិយាយច្រើនពេក មានគំនិតច្រើន មិនសូវសំរាន្ត និង ប្រថុយគ្រោះថ្នាក់ ដែលពួកគេជាធម្មតាមិនដែលហ៊ានប្រថុយ ។ ទោះបីស្តាប់មើលទៅ ម៉ានៀ ដូចជាកំប្លុកកំប្លែង តែវាតែងតែធ្វើឱ្យមនុស្សធ្លាក់ចូលទៅក្នុងស្ថានភាពលំបាក ។ |
| Manic episode | អំឡុងពេលនៃការសប្បាយចិត្តជ្រុល | N/A | N/A | គឺជាផ្នែកមួយនៃជំងឺបាយប៉ូឡាដែលគេកត់សម្គាល់តាមរយៈការសប្បាយហួសហេតុ រីករាយ ដោយមិនមានហេតុផលច្បាស់លាស់ ហើយមានការគិត ឬបារម្ភអំពីសមត្ថភាពរបស់ខ្លួនឯង យ៉ាងច្រើនសន្ធឹកសន្ធាប់ ។ |
| Mental retardation | ការលូតលាស់យឺតនៃបញ្ញា | N/A | N/A | គឺជាស្ថានភាពមួយ ដែលបុគ្គលមានពិន្ទុ IQចំនួន ៧០ ទៅ ៧៥ ឬ តិចជាងនេះ ហើយមានការពិបាកក្នុងការប្រើប្រាស់នូវជំនាញរបស់ខ្លួនក្នុងកិច្ចការងារប្រចាំជីវិត ។ |
| Mood disorders | វិបល្លាសអារម្មណ៍ | N/A | N/A | គឺជាលក្ខខណ្ឌដែលប៉ះពាល់ទៅដល់អារម្មណ៍របស់បុគ្គល ។ វាធ្វើឱ្យមនុស្សមានអារម្មណ៍លើសលុបពីកំរិតអារម្មណ៍របស់មនុស្សទូទៅ ហើយដែលប៉ះពាល់ទៅដល់ការបំពេញមុខងារ និងទំនាក់ទំនងជាមួយមនុស្សផ្សេងទៀត ។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Obsessive-compulsive disorder (OCD) | ជំងឺគិត និង ធ្វើដដែលៗ | N/A | N/A | គឺជាជំងឺផ្លូវចិត្ត ដែលគេកត់សម្គាល់នៅពេលបុគ្គលមាន ការគិត ការស្រមៃរំពៃ ឬ សន្ទះចិត្តដដែលៗ ម្តងហើយម្តងទៀតៗ ទោះបីជាបុគ្គលខិតខំប្រឹងប្រែងដើម្បីទប់ស្កាត់កុំឱ្យកើតមានក៏ដោយ ហើយទង្វើដដែលៗ និងមានគោលបំណងទាំងនោះ កើតឡើងដោយសារការមានជាច្បាប់ ឬ ទំលាប់ជាក់លាក់ណាមួយ ។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Panic disorder | ស្លន់វិបល្លាស | N/A | N/A | គឺជាប្រភេទជំងឺថប់បារម្ភ ម្យ៉ាងដែលជនរងគ្រោះទទួលរងបទពិសោធនៃការភ័យតក់ស្លុត ( panic attacks )ធ្ងន់ធ្ងរដែលមិនបានស្មានទុកមុន ហើយដែលធ្វើឱ្យជនរងគ្រោះមានការរំខានផ្នែកអារម្មណ៍ ។ |
| Personality disorder | បុគ្គលិកលក្ខណៈវិបល្លាស | N/A | N/A | គឺជាភាពរាំរ៉ៃ និងមិនចុះសម្រុងនៃការយល់ឃើញ ការគិត និងអាកប្បកិរិយា ហើយដែលនាំឱ្យបុគ្គលបាត់បង់សមត្ថភាព ក្នុងការបំពេញមុខងារ ឬ សកម្មភាពផ្សេងៗក្នុងសង្គម ។ |
| Phobia | ការភ័យខ្លាច | N/A | N/A | គឺជាការភ័យខ្លាចជាបន្តបន្ទាប់ ហើយដោយមិនមានហេតុផលច្បាស់លាស់ ចំពោះវត្ថុ សកម្មភាព ឬ ស្ថានភាពណាមួយយ៉ាងខ្លាំង ដោយមិនសមហេតុផល និងហួសហេតុ ។ |
| Postpartum psychosis | ចិត្តវិកលក្រោយសំរាលកូន | N/A | N/A | អាចកើតជំងឺចិត្តវិកលដោយកម្របន្ទាប់ពីសំរាលកូនហើយ ។ ប្រភេទចិត្តវិកលនេះមានឈ្មោះថាចិត្តវិកលក្រោយសម្រាលកូន ។ ស្ត្រីអាចនឹងមមាល ភាន់គំនិត និង មានគំនិតមិនសមហេតុផល ។ គ្រោះថ្នាក់នៅក្នុងករណីនេះកើតឡើងដោយសារតែស្ត្រីខ្វះការវិនិច្ឆ័យដែលអាចបង្កជាគ្រោះថ្នាក់ដល់ខ្លួនគាត់ ឬកូនរបស់គាត់ ។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Post traumatic stress disorder (PTSD) | ជំងឺបាក់ស្បាត (PTSD) | N/A | N/A | គឺជាជំងឺថប់បារម្ភមួយប្រភេទ ដែលបុគ្គលទទួលរងបទពិសោធនៃព្រឹត្តិការណ៍ប៉ះទង្គិចផ្លូវចិត្ត ម្តងហើយម្តងទៀតដោយរួមទាំងមានការពិបាកចិត្តយល់សប្តិមមាល ឬការនឹកឃើញឡើងវិញដដែលៗ ដែលការណ៍នេះ កើតឡើងដោយសារការរំលោភផ្លូវភេទ ព្រឹត្តិការណ៍ដែលគំរាមគំហែងដល់អាយុជីវិត រងរបួសធ្ងន់ធ្ងរ និងគ្រោះធម្មជាតិ ។ |
| Psychiatrist | វេជ្ជបណ្ឌិតឯកទេសវិកលវិទ្យា | N/A | N/A | គឺជាបុគ្គលដែលបានទទួលបានសញ្ញាប័ត្រជាពេទ្យ (M.D) ហើយបានបញ្ចប់ការសិក្សាថ្នាក់ក្រោយបណ្ឌិតជំនាញឯកទេសជំងឺផ្លូវចិត្ត ។ វេជ្ជបណ្ឌិតឯកទេសចិត្តវិកលអាចផ្តល់ថ្នាំដើម្បីប្រើប្រាស់ក្នុងការព្យាបាលជំងឺផ្លូវចិត្ត ។ |
| Psychological assessment | ការប៉ាន់ប្រម៉ាណលើកត្តាផ្លូវចិត្ត | N/A | N/A | គឺជាការប្រើប្រាស់នូវនីតិវិធីជាក់លាក់ណាមួយ ដើម្បីវាយតម្លៃសមត្ថភាព អាកប្បកិរិយា និងគុណភាពផ្ទាល់ខ្លួនរបស់មនុស្ស ។ |
| Psychological dependence | ភាពពឹងផ្អែកផ្នែកផ្លូវចិត្ត | N/A | N/A | គឺជាតម្រូវការផ្លូវចិត្ត ឬ គឺជាការត្រូវការការប្រើប្រាស់ឱសថ ។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Psychological trauma | ការប៉ះទង្គិចផ្លូវចិត្ត របួសផ្លូវចិត្ត | N/A | N/A | ជាជំពូកមួយនៃការខូចខាតចិត្តវិជ្ជា ដែលកើតឡើងដោយសារតែព្រឹត្តិការណ៍គួរឱ្យតក់ស្លុត។ នៅពេលដែលភាពតក់ស្លុតនោះនាំទៅរកវិបល្លាសនៃការប៉ះទង្គិច ការខូចខាតអាចពាក់ព័ន្ធនឹងការប្រែប្រួលរូបវ័ន្តនៅក្នុងខួរក្បាល និងប្រតិកម្មគីមីក្នុងខួរក្បាលដែលមានឥទ្ធិពលលើសមត្ថភាពរបស់បុគ្គលនោះក្នុងការតទល់នឹងការប៉ះទង្គិចផ្សេងៗ។ |
| Psychologist | ចិត្តវិទូ | N/A | N/A | គឺជាបុគ្គលម្នាក់ ដែលមានសញ្ញាបត្របណ្ឌិតផ្នែកចិត្តវិទ្យាពីកម្មវិធីសិក្សាដែលត្រូវបានរៀបចំឡើងដោយសាកលវិទ្យាល័យ ឬសាលាដែលមាននីតិសម្បទា។ |
| Psychology | ចិត្តវិទ្យា | N/A | N/A | គឺជាការសិក្សាបែបវិទ្យាសាស្ត្រទៅលើអាកប្បកិរិយា និងដំណើរការផ្លូវចិត្តរបស់បុគ្គលណាម្នាក់។ |
| Psychopharma-cology | ចិត្តឱសថវិទ្យា | N/A | N/A | គឺជាមែកធាងមួយរបស់ចិត្តវិទ្យា ដែលបានធ្វើការអង្កេតអំពីឥទ្ធិពលរបស់ថ្នាំមកលើអាកប្បកិរិយា។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Psychosis | ជំងឺចិត្តវិកល | N/A | N/A | គឺជាពាក្យសំរាប់ហៅប្រភេទបញ្ហាសុខភាពផ្លូវចិត្តមួយដែលបុគ្គលបាត់បង់ទំនាក់ទំនងជាមួយនឹងភាពពិត ។ ជាងនេះទៅទៀត បុគ្គលមានការរំខានយ៉ាងខ្លាំងទៅដល់ការគិតអារម្មណ៍ និងអាកប្បកិរិយារបស់គាត់ ។ |
| Psychosomatic disorders | ជំងឺចិត្តកាយវិបល្លាស | N/A | N/A | គឺជាជំងឺផ្លូវកាយ ដែលបណ្តាលមកពីការតានតឹងចិត្ត ឬ បញ្ហាផ្លូវចិត្តរ៉ាំរ៉ៃ ។ |
| Psychotherapy | ការព្យាបាលផ្លូវចិត្ត<br>ដោយប្រើពាក្យសម្តី | N/A | N/A | គឺជាវិធីសាស្ត្រនៃការព្យាបាលមួយបែបដែលត្រូវបានប្រើដើម្បីព្យាបាលជំងឺផ្លូវចិត្ត ហើយដែលបានផ្តោតលើការផ្លាស់ប្តូរអាកប្បកិរិយា ការគិត ទស្សនៈ និងអារម្មណ៍ ដែលមិនត្រឹមត្រូវដែលជាប់ទាក់ទងទៅនឹងជំងឺផ្លូវចិត្តជាក់លាក់ណាមួយ ។ |
| Psychotic disorders | ចិត្តវិកលវិបល្លាស | N/A | N/A | គឺជាជំងឺផ្លូវចិត្តធ្ងន់ធ្ងរដែលបុគ្គលមិនអាចមានលទ្ធភាពក្នុងការដឹងពីតថភាពជុំវិញខ្លួនដោយសារ តែមានការពិបាកក្នុងការគិត ការមានអារម្មណ៍ ឬការយល់ឃើញ ។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Schizophrenia | ការបែកធ្លាយចិត្តគំនិត | N/A | N/A | *សំដៅទៅលើការផ្លាស់ប្តូរមុខងារផ្លូវចិត្តដែលការគិត និងការយល់ដឹងក្លាយទៅជាវិបល្លាស ។* |
| Social phobia | ជំងឺខ្លាចសាធារណជន ឬ សង្គម | N/A | N/A | *គឺជាការភ័យខ្លាចមិនសមហេតុផលជាប្រចាំមួយ ដែលកើតឡើងដោយសារការរំពឹងទុកថាត្រូវបានគេសង្កេតមើលនៅពេលខ្លួននៅទីកន្លែងសាធារណៈ ។ ជាធម្មតា ការភ័យខ្លាចទាំងនោះមានដូចជាខ្លាចខ្លួនឯងមានអាកប្បកិរិយាណាមួយធ្វើឱ្យខ្មាសគេ ឬធ្វើឱ្យខ្លួនឯងអាម៉ាស់មុខ ។ កត្តាចម្បងជាងគេគឺខ្លាចអ្នកដទៃគិតអាក្រក់មកលើខ្លួន ។ ជាទូទៅ ជំងឺនេះកើតមានឡើងចំពោះកុមារដែលមានការអៀនខ្មាសច្រើននៅពេលដែលគេឈានចូលវ័យជំទង់ ។* |
| Specific phobias | ជំងឺខ្លាចស្ថានភាព ឬ វត្ថុជាក់លាក់ | N/A | N/A | *គឺជាជំងឺភ័យខ្លាចដែលកើតឡើងដោយសារការប្រតិកម្មទៅនឹងវត្ថុ ឬ ស្ថានភាពជាក់លាក់ណាមួយ ។* |
| Stigma | ភាពអាម៉ាស់ | Stigmatize | N/A | *គឺជាប្រតិកម្មអវិជ្ជមានរបស់មនុស្សដែលមានចំពោះបុគ្គលណាម្នាក់ ឬក្រុមមនុស្សណាមួយ ដោយសារតែត្រូវបានគេសន្និដ្ឋានថាមានឋានៈតូចទាប ឬខុសប្លែកផ្សេងពីគេហើយដែលមិនត្រូវបានផ្តល់តម្លៃ ។* |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Stress | ភាពតានតឹងចិត្ត | N/A | N/A | គឺជាលំនាំប្រតិកម្មជាក់លាក់ និងមិនជាក់លាក់ណាមួយរបស់អង្គសរីរាង្គមានជីវិតចំពោះព្រឹត្តិការណ៍ភ្ញោច ហើយដែលរំខានទៅដល់ភាពលំនឹងនៃផ្លូវចិត្ត និងហួសពីសមត្ថភាពរបស់បុគ្គលក្នុងការដោះស្រាយ ។ |
| Stressor | កត្តានាំឱ្យតានតឹងចិត្ត | N/A | N/A | គឺជាព្រឹត្តិការណ៍ ឬ កត្តាភ្ញោចខាងក្នុង ឬ ខាងក្រៅដែលនាំឱ្យមានការតានតឹងចិត្ត ។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Trauma | ការប៉ះទង្គិចផ្លូវចិត្ត | Traumatize | N/A | ជាបទពិសោធប៉ះពាល់ជាអវិជ្ជមានដល់ផ្លូវចិត្ត ហើយដែលបង្កជាភាពច្របូកច្របល់ផ្លូវចិត្ត ឬ ធ្វើឱ្យបុគ្គលណាម្នាក់បន្តទទួលផលប៉ះពាល់ជាអវិជ្ជមានទៅលើគំនិត អារម្មណ៍ និងអាកប្បកិរិយា ។ |

| ពាក្យ | ខ្មែរ | កិរិយាសព្ទ | សទិសន័យ | និយមន័យ |
|---|---|---|---|---|
| Wellness | សុខភាពល្អ | N/A | N/A | ការមានសុខភាពពេញលេញ ដែលអាចធ្វើឱ្យបំពេញការងារបានពេញលេញ និងមានភាពសកម្មលើផ្នែករាងកាយ បញ្ញា អារម្មណ៍ ជំនឿ សង្គម និងមជ្ឈដ្ឋានជុំវិញសុខភាព។ |

# ឯកសារយោង

១- ក្រមរដ្ឋប្បវេណី, ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៧ និងព្រះរាជក្រមលេខ នស/រកម/០៥១១/០០៧ ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី

២- ក្រមព្រហ្មទណ្ឌ, ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១១០៩/០២២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩

៣- ច្បាប់ ស្តីពីការអប់រំ, ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៧

៤- ច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ, ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២០៨/០០៥ ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០៨ និងកំណត់ពន្យល់មាត្រានីមួយៗនៃច្បាប់នេះ ដែលត្រូវបានបោះពុម្ពឱ្យប្រើប្រាស់ជាផ្លូវការនៅថ្ងៃទី ០៤ ខែមេសា ឆ្នាំ២០១៣

៥- ច្បាប់ ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ, ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១០០៥/០៣១ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០០៥

៦- អនុសញ្ញារបស់អង្គការសហប្រជាជាតិស្តីពីការប្រឆាំងបទឧក្រិដ្ឋកម្មឆ្លងដែនដែលមានអង្គការចាត់តាំង និង ពិធីសារស្តីពីការទប់ស្កាត់ បង្ក្រាប និងដាក់ទណ្ឌកម្មការជួញដូរមនុស្ស ជាពិសេសស្ត្រីនិងកុមារដែលបំពេញបន្ថែមលើអនុសញ្ញា

របស់អង្គការសហប្រជាជាតិស្តីពីការប្រឆាំងបទឧក្រិដ្ឋកម្មឆ្លងដែនដែលមានអង្គការចាត់តាំង, សេចក្តីសម្រេចរបស់មហាសន្និបាតលេខ ៥៥/២៥ ចុះថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០០០ និងដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១០៦/០០៤ ចុះថ្ងៃទី១៨ ខែ មករា ឆ្នាំ ២០០៦

៧- អនុសញ្ញាស្តីពីការប្រឆាំងនឹងអំពើទារុណកម្ម និង ការប្រព្រឹត្តឬការដាក់ទណ្ឌកម្មទាំងឡាយណាដែលមានលក្ខណៈឃោរឃៅ អមនុស្សធម៌ ឬ បន្ទាបបន្ថោក, អនុម័តដោយសេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិលេខ ៣៩/៤៦ ចុះថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ១៩៨៤ និងដែលប្រទេសកម្ពុជាចូលជាសមាជិកនៃអនុសញ្ញានេះនៅថ្ងៃទី១៥ ខែ តុលា ឆ្នាំ ១៩៩២

៨- លក្ខន្តិកៈក្រុមរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ អនុម័តនៅថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ១៩៩៨ និងដែលប្រកាសអនុម័តយល់ព្រមដោយព្រះរាជក្រមលេខ នស/រកម/០១០២/០០២ ចុះថ្ងៃទី៧ ខែ មករា ឆ្នាំ ២០០២

៩- គោលនយោបាយស្តីពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដែលដាក់ឱ្យអនុវត្តតាមរយៈប្រកាសលេខ ៨៥២ ស.អ.យ. ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០៩ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

១០-សេចក្តីសម្រេច ស្តីពី គោលការណ៍ការពារសិទ្ធិកុមាររងគ្រោះដោយសារការជួញដូរ នៃព្រះរាជាណាចក្រកម្ពុជា ដែលចេញដោយក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ នៅថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០០៧

១១- សេចក្តីណែនាំអំពីការអនុវត្តគោលការណ៍នានាក្នុងច្បាប់ជាតិ និងអន្តរជាតិដែលកំពុងនៅជាធរមានទាក់ទងនឹងការការពារជនរងគ្រោះនៃបទល្មើសព្រហ្មទណ្ឌ ដែលចេញដោយក្រសួងយុត្តិធម៌ នៅថ្ងៃទី ១៩ ខែសីហា ឆ្នាំ២០០៥

១២-គោលការណ៍ និងសេចក្តីណែនាំ ស្តីពីសិទ្ធិមនុស្សនិងការជួញដូរមនុស្ស ដែលរៀបចំដោយការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស សម្រាប់កិច្ចប្រជុំរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ចនិងសង្គមនៃអង្គការសហប្រជាជាតិ នៅថ្ងៃទី១-២៦ ខែកក្កដា ឆ្នាំ២០០២

១៣- *Planète Enfants, 2005, Guidelines for the Operation of Care Facilities for Victims of Trafficking and Violence against Women and Girls*

១៤- *English-Khmer Law Dictionary, 1997*

១៥- *International Organization for Migration (IOM), 2004, Glossary on Migration*

១៦- *Black's Law Dictionary, eighth edition, 2004*

១៧- *Longman Essential Activator, 1997*

១៨- *American Psycological Association, Psychological Glossary*

១៩- *Mental Health First Aid Singapore, Psychological Glossary*

# COMMIT

## Coordinated Mekong Ministerial Intiative Against Trafficking



UNIAP

United Nations Inter-Agency
Project on Human Trafficking

**United Nations Inter-Agency Project on Human Trafficking**

No 164 Pasteur Street, Boeung Keng Kang
P.O. Box 877, Phnom Penh, Cambodia
Tel: +855 23 216 167/216 217
Fax: +855 23 996 122/216257
http://www.no-trafficking.org